ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ សព្វព្រះរាជហឫទ័យ ប្រសិទ្ធនាមឈ្មោះអគារដែលជាសាខា «ព្រះរាជបណ្ណាល័យហ្លួងម៉ែ» ជា «អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)»

◆ ជនជាតិភាគតិចស្ទៀង នៅក្នុងភូមិក្អូលលើ រៀបចំពិធីបុណ្យផ្ដាច់វេនព្រះសង្ឃ គង់ចាំព្រះវស្សា នៅផ្ទះសហគមន៍ភូមិក្អូលលើ នៃមជ្ឈមណ្ឌលឯកសារកោះថ្ម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៩៨ ខែតុលា ឆ្នាំ២០២៤

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា



កងយោធាខ្មែរក្រហមកំពុងបោចស្មៅនៅវាលស្រែ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## មាតិកា

### សំបុត្រ

◆ ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ សព្វព្រះរាជហឫទ័យប្រសិទ្ធនាមឈ្មោះអគារដែលជាសាខា «ព្រះរាជ............ ១

### ផ្នែកឯកសារ

◆ ទី អេង ៖ អនុលេខាវរសេនាតូច៨០៥........... ៣

### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

◆ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ចាក់បញ្ចាំងខ្សែភាពយន្តឯកសារ ............................ ៦
◆ គរុសិស្សមកពីមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម ទស្សនាពិព័រណ៍ស្តីពី........... ៨
◆ ជនជាតិភាគតិចស្មៀង នៅក្នុងភូមិក្តុលលើរៀបចំពិធីបុណ្យផ្កាប់វេនព្រះសង្ឃគង់ចាំព្រះវស្សា ... ១១
◆ មជ្ឈមណ្ឌលផ្សះផ្សាវាលវែងបញ្ចាំងខ្សែភាពយន្តឯកសាររឿង «កុំស្មានបងភ្លេច» ................ ១៤
◆ មជ្ឈមណ្ឌលផ្សះផ្សាវាលវែង ផ្តល់វេទិកាដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ...... ១៧
◆ សិស្សវិទ្យាល័យចម្រើនវិជ្ជា សិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) .. ២៣
◆ ប្រវត្តិតំបន់ «ទន្លេចាម» ........................ ២៦
◆ គាង សុខន ៖ បងប្រុសខ្ញុំពីរនាក់ ត្រូវខ្មែរ .... ២៨
◆ ជា អ៊ា ៖ អន្តការផ្តាច់របបអាហារ ព្រោះខ្ញុំ.... ៣០
◆ ឈាន កុប ៖ អតីតទាហានការពារព្រំដែន ... ៣២
◆ នុត ពិច ៖ ខ្ញុំពិការក៏ត្រូវធ្វើការជូនអង្គការ .... ៣៤
◆ ជាន់ ចាន់ថា ៖ កងចល័តតាមភូមិ............. ៣៦
◆ មាច ប៉ោង ៖ ត្រូវធ្វើការទាំងបង្ខំ និងមើលថែ... ៣៧
◆ រស់ យ៉ាន ៖ អ្នកភូមិខ្ញុំត្រូវចោទជាជនក្បត់... ៣៨
◆ រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចេញពីស្រុកអន្លង់វែង ................ ៣៩

### ផ្នែកវេទិកាពិភាក្សាសាធារណៈ

◆ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង រៀបចំវេទិកាថ្នាក់រៀនស្តីពី «ជីវិតរស់នៅប្រចាំថ្ងៃរបស់ ......... ៥៦

### ផ្នែកស្រាវជ្រាវរកគ្រួសារ

◆ ជីវិតកូនប្រុសពុកក្នុងគុកខ្មែរក្រហម (តចប់).. ៥៩

**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឱ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ ៖** ឡុង ដានី, ឈុំ រ៉ា, សាំង ចាន់ធូ, ធី គីមហុង, ឡាំ ស្រីនីត, មឿន ស្រីណុច, ចាន់ ណារិទ្ធ, ភា រស្មី, ថុន ស្រីពេជ្រ, ហាក់ គីមលីង, វី ស៊ីថា, មុត សុខបុប្ផា, ឆោយ កុម្ភៈ, ដាប់ ដារ៉ា, យ៉ម ស្រីមុំ, សុខ សីហា, សែ សារ៉ិន, លេន វីរ៉ា, ផូវ ដានុន, សាត់ ស្រីនិត, ស៊ុយ គីមសួរ, សុខ វ៉ាន់ណៃត, ណៃម ចាន់រ៉ា, អឿន អូដី, ខៀវ សុខា, ហាប់ នៀត, សុង សេងហ៊ង, ឡា សុឃៀយ សួត វិចិត្រ, និង ហង្ស ឆាំឆាន
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** មីន សាណាស់ **អ្នកបកប្រែ៖** លីម អ៊ីភីង និង ជ័យ ចាន់ស៊ីណៃត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនី ឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ សព្វព្រះរាជហឫទ័យ

## ប្រសិទ្ធនាមឈ្មោះអគារដែលជាសាខា «ព្រះរាជបណ្ណាល័យហ្លួងម៉ែ» ជា «អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)»

សោម ប៊ុនថន

មជ្ឈមណ្ឌលឯកសារកម្ពុជា បានសាងសង់អគារដែលជាសាខា «ព្រះរាជបណ្ណាល័យ ហ្លួងម៉ែ» នៅស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង ដែលនឹងហើយរួចរាល់នៅអំឡុងខែវិច្ឆិកា ឆ្នាំ២០២៤ ខាងមុខ។

តបតាមលិខិតដែលលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិក «ព្រះរាជបណ្ណាល័យ ហ្លួងម៉ែ» សរសេរទូលថ្វាយ ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ អំពីការសុំប្រសិទ្ធនាមឈ្មោះអគារ នៃសាខា «ព្រះរាជបណ្ណាល័យ ហ្លួងម៉ែ» ស្ថិតក្នុងទឹកដីប្រវត្តិសាស្ត្របុរីអូរស្វាយ ខេត្តស្ទឹងត្រែង ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៤។ ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ សព្វព្រះរាជហឫទ័យរីករាយអបអរសាទរនូវសមិទ្ធផលថ្មីអគារ ដែលជាមរតកបន្សល់ពីសម័យសង្គមរាស្ត្រនិយមដ៏រុងរឿង ដែលមានទីតាំងស្ថិតនៅក្នុងភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង ដោយទ្រង់ប្រសិទ្ធនាមជា «អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ- សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)»។

បុរីអូរស្វាយ ត្រូវបានបង្កើតឡើងដោយព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ «ព្រះបរមរតនកោដ្ឋ» អំឡុងទសវត្សរ៍ទី៦០ ក្នុងគោលបំណងការពារបូរណភាពទឹកដីប្រទេសកម្ពុជានៅភាគខាងជើង ជាប់នឹងប្រទេសឡាវ។ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ «ព្រះបរមរតនកោដ្ឋ» បានផ្តល់ដីសម្រាប់ធ្វើកសិកម្ម និងសាងសង់ផ្ទះឱ្យប្រជាជនខ្មែរដែលស្ម័គ្រចិត្តមករស់នៅតំបន់នេះ និងផ្តល់សត្វពាហនៈឱ្យប្រជាជនចិញ្ចឹមដើម្បីទ្រទ្រង់ជីវភាពគ្រួសារ។ ព្រះអង្គបានសាងសង់សាលារៀន មណ្ឌលសុខភាព ប៉ុស្តិ៍នគរបាល មន្ទីរកសិកម្ម និងវត្តអារាម សម្រាប់បម្រើជាប្រយោជន៍សហគមន៍បុរីអូរស្វាយ។ ទន្ទឹមនេះ ព្រះអង្គបានរៀបចំសួនច្បារ និងសាងសង់ស្តូបតំណាងឱ្យតំបន់បុរីអូរស្វាយនៅជាប់មាត់ទន្លេមេគង្គ។ ស្តូបនោះមានចម្លាក់បែរទៅទិសធំៗទាំង៤ ដោយនៅទិសខាងត្បូង មានចម្លាក់ព្រះអង្គឡើងគ្រងរាជ្យសម្បត្តិលើកទី១ ជាមួយរូបវិមានឯករាជ្យ។ រូបចម្លាក់នៅទិសខាងកើត ព្រះអង្គកំពុងកាន់ញញួរដំដែកគោលលើជញ្ជាំងផ្ទះសង់ពីឈើ។ រូបចម្លាក់នៅទិសខាងជើង គឺជាព្រះរាជសកម្មភាពពេលដែលព្រះអង្គកំពុងតែរត់ហាត់កីឡា។ រីឯរូបចម្លាក់នៅទិសខាងលិច គឺជាព្រះរាជសកម្មភាពរបស់ព្រះអង្គកំពុងកើបដី។ នៅមានសំណង់ប្រវត្តិសាស្ត្រជាច្រើនទៀត ដែលត្រូវបានសាងសង់ឡើងហើយបាក់បែកទៅវិញ និងត្រូវបានវាយកម្ទេចចោលនៅក្នុងសម័យសង្គ្រាម ជាពិសេសក្នុងរបបខ្មែរក្រហម (ពីឆ្នាំ១៩៧៥-១៩៧៩)។ ជាក់

ស្តែង វត្តអារាមមួយស្ថិតនៅទល់មុខសាលាស្រុកបុរីអូរស្វាយសែនជ័យ ត្រូវបានខ្មែរក្រហមយកមកធ្វើជាទីស្នាក់ការ និងជាកន្លែងសម្លាប់មនុស្ស។

ទោះបីយ៉ាងណា បន្ទាប់ពី «អគារមរតកសង្គមរាស្រ្តនិយម សម្តេចឪ- សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)» សាងសង់រួចរាល់ នឹងចូលរួមចំណែកយ៉ាងសកម្មក្នុងការអប់រំប្រវត្តិសាស្រ្តខ្មែរក្រហមក្នុងសហគមន៍ នឹងជួយលើកកម្ពស់ដល់វិស័យផលផលកសិកម្ម និងទាក់ទាញភ្ញៀវទេសចរណ៍មកទស្សនាតំបន់នេះ។



**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតា**
**នរោត្តម មុនិនាថ សីហនុ**
**នៃព្រះរាជាណាចក្រកម្ពុជា**

ជូន លោក យុ ឆាង
នាយក នៃមជ្ឈមណ្ឌលឯកសារកម្ពុជា
និងជាស្ថាបនិកវិទ្យាស្ថានស្លឹករឹត

លោកនាយក

ខ្ញុំ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះលិខិតទូលថ្វាយចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៤ ស្តី អំពីការសុំប្រសិទ្ធនាមឈ្មោះអគារ នៃសាខា **ព្រះរាជបណ្ណាល័យឈូកម៉ំ** ស្ថិតក្នុងទីកដីប្រវត្តិសាស្រ្ត បុរីអូរស្វាយ ខេត្តស្ទឹងត្រែង។

ខ្ញុំ មានហឫទ័យរីករាយអបអរសាទរ នូវសមិទ្ធិផលថ្មីអគារដែលជាមរតកបន្សល់ពីសម័យសង្គមរាស្រ្តនិយមដ៏រុងរឿង ដែលមានទីតាំងស្ថិតក្នុងភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង សាងសង់រួចរាល់នៅខែ វិច្ឆិកា ខាងមុខនេះ សូមប្រសិទ្ធនាម **អគារមរតកសង្គមរាស្រ្តនិយម សម្តេចឪ_សម្តេចម៉ែ** (បុរីអូរស្វាយ-សែនជ័យ)។

សូមលោកនាយក បានប្រកបតែនឹងព្រះពុទ្ធពរគ្រប់ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងទទួលនូវសេចក្តីរាប់អាន អំពី ខ្ញុំ។

**នរោត្តម មុនិនាថ សីហនុ**

ភ្នំពេញ ថ្ងៃទី ១១ ខែតុលា ឆ្នាំ២០២៤

# ទី អេង ៖ អនុលេខាវរសេនាតូច៨០៥ ឯករាជ្យ របស់កងពល ៨០១

**ដារ៉ារដ្ឋ មេត្តា**



កងទ័ពខ្មែរក្រហមនៅពហុកីឡដ្ឋានអូឡាំពិក។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ទី អេង និងមានឈ្មោះបដិវត្តន៍ ទី សិទ្ធ ភេទប្រុស ជនជាតិខ្មែរ អាយុ៣៥ឆ្នាំ (នៅក្នុងឆ្នាំ១៩៧៧)។ ខ្ញុំមានទីលំនៅភូមិដើមជ្រៃ ឃុំក្រូចឆ្មារ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។ ខ្ញុំមានឪពុកឈ្មោះ អ៊ុន ទី និងម្ដាយឈ្មោះ ឌួង ម៉ុត ហើយមានប្អូនឈ្មោះ ទី ស៊ូ។

នៅពេលខ្ញុំអាយុ១២ឆ្នាំ ឪពុកម្ដាយខ្ញុំបានបញ្ជូនខ្ញុំឱ្យទៅសាលារាជការ ឈ្មោះហៅថាសាលាបឋមសិក្សាបំពេញវិជ្ជាស្រុកក្រូចឆ្មារ។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី៧ ក៏ឈប់រៀន មកជួយធ្វើចម្ការឪពុកម្ដាយវិញ។ នៅឆ្នាំ១៩៦២ ខ្ញុំមានអាយុ១៩ឆ្នាំ កាលនោះមេឃុំឈ្មោះ ឡុង បានចាត់តាំងខ្ញុំឱ្យធ្វើជាកងអាសាស្ម័គ្រជង និងធ្វើគិញជង។ ក្រោយពីចាត់តាំងហើយមេឃុំ ឡុង បានបំពាក់បំប៉នស្មារតីអប់រំខ្ញុំឱ្យចេះស្រឡាញ់ជាតិ ស្នេហាការពារទឹកដីកុំឱ្យពួកកុម្មុយនីស្ត ឬខ្មែរក្រហមដណ្ដើមយកទឹកដីជាតិមាតុភូមិជាទីស្នេហារបស់យើងបានជាដាច់ខាត។ ក្រោយពីការអប់រំហើយ មេឃុំ ឡុង បានពន្យល់ណែនាំភារកិច្ចឱ្យខ្ញុំអនុវត្តមានជាអាទិ៍ ពិនិត្យតាមដានរកក្រុមខ្មែរក្រហម និងដើរយកការណ៍ពីខ្មែរក្រហមតាម ស្រុក ឃុំ ភូមិរបស់ខ្ញុំ។

នៅឆ្នាំ១៩៦៣ ខ្ញុំបួសរៀននៅវត្តបុស្សកែវ ស្ថិតនៅក្នុងស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។ ពេលនៅជាព្រះសង្ឃ ខ្ញុំបានបំផុសលោកទាំង៦អង្គឱ្យចងកំហឹងជាមួយនឹងខ្មែរក្រហម បុជនណាឱ្យតែប្រឆាំងនឹងប្រជាជន សង្គមរាស្ត្រនិយម ត្រូវតែប្រឆាំងជាដាច់ខាត។ ម្យ៉ាងទៀត ខ្ញុំបានបំផុសថា ខ្មែរក្រហមឃោរឃៅណាស់សម្លាប់ប្រជាជនយ៉ាងព្រៃផ្សៃបំផុត។ ខ្មែរក្រហមនេះគឺជាអ្នកប្រឆាំងនឹងព្រះពុទ្ធសាសនា គ្មានជំនឿបុណ្យបាបអ្វីទាំងអស់។

នៅចន្លោះពីឆ្នាំ១៩៦៤ ដល់ឆ្នាំ១៩៦៥ ក្រោយពីខ្ញុំបានសឹករួច ក៏បានរួមកម្លាំងជាមួយខ្សែរយៈរបស់ខ្ញុំដដែល ហើយបានធ្វើសកម្មភាពនៅតាមមូលដ្ឋាន ភូមិ ឃុំ ស្រុក តទៅទៀត។ នៅចន្លោះពីឆ្នាំ១៩៦៦ ដល់ឆ្នាំ១៩៦៧ ខ្ញុំចេញពីស្រុករបស់ខ្ញុំមករស់នៅក្រុងភ្នំពេញ ធ្វើជាកម្មករសង់ផ្ទះថ្ម តាមរយៈឈ្មោះ អ៊ុំ សយ (នារី) គឺជាអ្នករកស៊ីយកបន្លែបោះឱ្យឈ្មួញលក់បន្ត។ ខ្ញុំធ្វើកម្មករផ្ទះថ្មមួយរយៈ ក្រោយមក ខ្ញុំបានស្គាល់ឈ្មោះ សារិន, សុខា, ថា និង ថាច ដែលធ្វើគូលីសង់ផ្ទះថ្មដូចគ្នា។ ក្រោយមកឈ្មោះ សារិន ក៏មានការស្រឡាញ់រាប់អានជិតស្និទ្ធជឿទុកចិត្តមកលើរូបខ្ញុំ។ សារិន ក៏បាននាំខ្ញុំឱ្យស្គាល់ឈ្មោះ នាង គឺជាមេរបស់ សារិន ពាក់ស័ក្តិ២កន្ទះ។ នាងបានអប់រំខ្ញុំអំពីខ្លឹមសាររបស់សក្តិភូមិ កម្មសិទ្ធិ សម្ភារ សិទ្ធិអំណាច សំខាន់ឱ្យខ្ញុំនិងប្រជាជន ចេះស្នេហាទឹកដីមាតុប្រទេសរបស់យើង។ នៅខែមីនា ឆ្នាំ១៩៦៩ ខ្ញុំបានសុំឈ្មោះ សារិន ឈ្មោះនាងវិលត្រឡប់មកស្រុកកំណើតវិញ ដោយឃើញថា ជីវភាពនៅក្នុងទីក្រុងមានការលំបាកតឹងតែង មូលហេតុសំខាន់ថៅកែផ្ទះថ្មជំពាក់លុយគូលីពុំព្រមឱ្យ។ ខ្ញុំមកស្រុកវិញ ហើយឈ្មោះ នាង ក៏បានផ្តាំខ្ញុំឱ្យទាក់ទងឈ្មោះ ធន រស់នៅស្រុកក្រូចឆ្មារស្រាប់ ដែលត្រូវជាមិត្តរបស់គាត់ដែលចូលសេ-អ៊ី-អា តាំងពីឆ្នាំ១៩៦៤ម្ល៉េះ។

ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ គឺជាថ្ងៃរដ្ឋប្រហារ ឈ្មោះ ធន ក៏បានចូលបង្កប់ខ្លួនក្នុងជួរបដិវត្តន៍មុន ដោយចូលនៅវត្តទួលសំបូរ ភូមិភាគ៣០៤ (ឧត្តរ) ខេត្តកំពង់ចាម។ ពេលនោះ ធន ទទួលខុសត្រូវផ្នែកយោធាមួយអនុសេនាធំ។ ក្រោយមកដោយសារខ្ញុំបានដំណឹងពីឈ្មោះធនបានចូលបដិវត្តន៍មុន ដូច្នេះនៅខែកក្កដា ឆ្នាំ១៩៧០ ខ្ញុំបានបបួលឈ្មោះ ឡា, សារិន, ឆាង, សារី ចូលមកនៅជាមួយឈ្មោះ ធន តែម្តង។

នៅឆ្នាំ១៩៧១ អង្គការចាត់តាំងខ្ញុំឱ្យរៀនពេទ្យនៅក្នុងព្រៃច្រកបង្គង ដោយមានអ្នកទទួលខុសត្រូវឈ្មោះ ទេព, ថន និង សើ។ ការរៀននេះខ្ញុំបានធ្វើសកម្មភាពដោយបានបំផុសទំនាស់ផ្សេងៗសំខាន់បំផុតអំពីបញ្ហាជំងឺគ្រុនចាញ់ច្រើន ដែលធ្វើឱ្យគ្រោះថ្នាក់ជាងគេ។ ដោយសារខ្វះថ្នាំពេទ្យ ធ្វើឱ្យសិក្ខាកាមធ្លាក់ខ្លួនឈឺ ចំណែកថ្នាំបុរាណមិនសូវមានប្រសិទ្ធភាពឡើយ។ ខ្ញុំរៀនបានរយៈពេល១ខែទើបអង្គការឱ្យមកបម្រើប្រជាជននៅគីឡូលេខ៣ នៅភូមិភាគ៣០៤ ខេត្តកំពង់ចាម។

នៅឆ្នាំ១៩៧២ អង្គការបង្កើតជាអង្គភាពថ្មីមួយ ឈ្មោះ ហៅថាអង្គភាព(ក៣៩) គឺមានឈ្មោះ ជ័យ, ស៊ុន ទទួលជាកងវរសេនាតូច។ អង្គភាពនេះដំបូងតាំងនៅភូមិដងក្តា និង ភូមិក្រវាន់។ អង្គការចាត់តាំងខ្ញុំ និង ព្រិល ទៅធ្វើពេទ្យក្នុងអង្គភាពនេះក្រោមការដឹកនាំឈ្មោះ ជ័យ និង ស៊ុន។ នៅឆ្នាំ១៩៧២ អង្គការបានបើកយុទ្ធនាការវាយចេនឡាទី២ នៅតាមផ្លូវចាទាង, កំពង់ថ្ម, តាំងក្រសាំង, វាយរហូតដល់ ចុងដា, បញ្ញាជី, ប៉ូខាវ និងពុកយុក ខេត្តកំពង់ធំ។

នៅឆ្នាំ១៩៧៣ អង្គការបើកយុទ្ធនាការវាយនៅត្រពាំងវែង។ ចំណែកខ្ញុំពេលនោះ បានបោះទីតាំងនៅពេទ្យស្ថិតនៅភូមិព្រាំនម៉ា (ខេត្តកំពង់ធំ)។ ខ្ញុំបានទាក់ទងខ្សែចាស់របស់ខ្ញុំទាំងនៅក្នុងសមរភូមិមុខនិងសមរភូមិក្រោយ ដើម្បីប្រជុំដកពិសោធន៍ផែនការចាស់ ដាក់ផែនការថ្មីគឺ ៖ ១) ត្រូវឈ្លបកម្ទេចកម្មាភិបាលនៅតាមសមរភូមិ ពេលដែលកំពុងប្រយុទ្ធជាប់ដៃគ្នាក៏ដូចជា លបកម្ទេចដោយសម្ងាត់, ២) ត្រូវបំផុសយុទ្ធជនកម្មាភិបាលឱ្យប្រឆាំងទំនាស់បដិវត្តន៍ដូចជា ទំនាស់រវាងកងទ័ពប្រជាជន, ៣) ត្រូវបំផ្លើសបំភ្លៃមាគ៌ារបស់បក្សជាបន្តបន្ទាប់។

នៅឆ្នាំ១៩៧៤ អង្គការចាត់តាំងអង្គភាពខ្ញុំឱ្យមកនៅអង្គភាពពិសេសតំបន់១៥។ មកនៅដំបូង អង្គការចាត់តាំងខ្ញុំជាពេទ្យសង្គ្រោះ ដែលពេទ្យនេះ

មានបុគ្គលិកចំនួន១០នាក់ប៉ុណ្ណោះ។ ពេទ្យសង្គ្រោះនេះ គឺជាពេទ្យសម្រាប់ចល័តទៅតាមសមរភូមិពេលវាយ ក៏ដូចជាពេលសម្រាក គឺមិនអាចកំណត់បាន ហើយត្រូវធ្វើតាមបក្សត្រូវការ។ មកដល់ពាក់កណ្ដាលឆ្នាំ១៩៧៤ អង្គការបានបើកយុទ្ធនាការវាយនៅសមរភូមិ៩៩០ ដោយអង្គការចាត់តាំងបុគ្គលិកបន្ថែមចំនួនមួយកងអនុសេនាតូច ដើម្បីងាយស្រួលក្នុងការព្យាបាល។ នៅចុងឆ្នាំ១៩៧៤ អង្គការបន្ថែមបុគ្គលិកមួយអនុសេនាធំទៀតព្រោះពេលនោះអង្គការតម្រូវឱ្យអ្នកជំងឺ អ្នករបួសមកព្យាបាលនៅមន្ទីរពេទ្យព-៥នេះ។ ពេលនោះពេទ្យព-៥ មិនទាន់ចាត់តាំងទៅអង្គភាពយោធាទេដោយស្ថិតនៅក្រោមការដឹកនាំរបស់ភូមិភាគពិសេសតំបន់១៥។

នៅខែឧសភា ឆ្នាំ១៩៧៥ អង្គការចាត់តាំងអង្គភាពពេទ្យមកនៅក្រុងភ្នំពេញ គឺមន្ទីរពេទ្យព្រះសង្ឃ។ ក្រោយមក ទើបអង្គការបញ្ចូលពេទ្យព-៥ ទៅក្នុងអង្គភាពយោធាកងពល៨០១។ នៅក្នុងឆ្នាំ១៩៧៦ អង្គការចាត់តាំងអង្គភាពពេទ្យទៅខេត្តរតនគិរី។ លុះដល់ខែកុម្ភៈ ឆ្នាំ១៩៧៦ ខ្ញុំបានរៀបចំកសាងមន្ទីរពេទ្យនៅក្រុងបានលុង។ បងសារីម, ខ្ញុំ និង ព្រិល ក៏រួមធ្វើសកម្មភាព និងបានបំផុសថា ខេត្តរតនគិរីនេះ គឺជាកន្លែងគ្រុនចាញ់បំផុត។ កាលពីសង្គមចាស់ កន្លែងនេះនៅបានតែអ្នកមានបុណ្យស័ក្តិ ប្រាក់ខែច្រើន អ្នកក្រពុំអាចរស់នៅបានទេ គឺគ្រុនចាញ់ស្លាប់អស់គ្មានសល់។ ខ្ញុំនៅបានមួយរយៈ ជំងឺគ្រុនចាញ់ក៏កើតមានជាបន្តបន្ទាប់ ឯអ្នកស្លាប់ក៏មានជាបន្តបន្ទាប់ដែរ។ ក្រោយពីមានការបំផុស ខ្ញុំក៏ទាក់ទងខ្សែចាស់ឡើងវិញមានបងកែវ សារឿន, សារីម, សិទ្ធិ និង ព្រិល។

ចាប់ពីខែមករា ដល់ខែកុម្ភៈ ឆ្នាំ១៩៧៧ ខ្ញុំបានចូលរួមធ្វើសកម្មភាពដោយបានផ្សាយផែនការជាបន្តបន្ទាប់ គឺបានចុះទៅ ទាក់ទងតាមគ្រប់អង្គភាព ដើម្បីផ្សព្វផ្សាយណែនាំអនុវត្តតាមជាដាច់ខាត ដូចជាផែនការចាក់ថ្នាំ និងដាក់ថ្នាំពុល។ ដោយឡែក ខ្ញុំក៏បានចូលរួមធ្វើសកម្មភាព និងចាត់តាំងឱ្យចាក់ថ្នាំធ្វើឱ្យស្លាប់មនុស្សចំនួន២នាក់។ ចំណែកការអនុវត្តផែនការមួយចំនួនទៀត រួមមាន ដាក់ដែកគោល, ម្ជុល, ផ្លែសន្ទូច និងខ្សែលួស នៅក្នុងចានបាយ បុសម្ល នៅតាមផ្ទះអ្នកជំងឺ ក៏ដូចជាបុគ្គលិកដែរ។ រហូតដល់ថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៧៧ អង្គការចាប់ខ្លួនខ្ញុំមកឃុំឃាំងតែម្ដង។

***កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពឯកសារJ០០២២៥។ រាល់ចម្លើយសារភាពរបស់អ្នកទោស ទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់ ទី អេង ហៅ សិទ្ធ ពិតប្ យ៉ាងណានោះទេ?***



កងទ័ពខ្មែរក្រហមនៅពហុកីឡដ្ឋានអូឡាំពិក។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ចាក់បញ្ចាំងខ្សែភាពយន្តឯកសារ មានចំណងជើងថា «កុំស្មានបងភ្លេច» ជូនអ្នកភូមិនៅសហគមន៍ភូមិក្តុលលើទស្សនា

ឈុំ រ៉ា



យាយ តា អ៊ំ ពូ មីង យុវជន និង កុមារ នៅក្នុងភូមិក្តុលលើទស្សនាខ្សែភាពយន្តឯកសារ «កុំស្មានបងភ្លេច» នៅផ្ទះសហគមន៍ភូមិក្តុលលើ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

តាមការស្នើសុំពីអាជ្ញាធរភូមិក្តុលលើ លោកតា លោកយាយ អ៊ំ ពូ មីង និងយុវជននៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មនៅវេលាម៉ោង៧:១៥នាទីរសៀល ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៤ បានចាក់បញ្ចាំងខ្សែភាពយន្តឯកសារដែលមានចំណងជើងថា «កុំស្មានបងភ្លេច» មានរយៈពេលចំនួន ១ម៉ោង ៤៦នាទី និង៥៧វិនាទី នៅផ្ទះសហគមន៍ភូមិក្តុលលើ ឬសាលាគុរុកណ្ឌស្មៀង ឱ្យអ្នកភូមិទស្សនា។

ជាកិច្ចចាប់ផ្តើម លោក ឈុំ រ៉ា បុគ្គលិកមជ្ឈមណ្ឌលឯកសារកោះថ្មបានធ្វើការណែនាំខ្លួន និងក្រុមការងារ។ លោក ឈុំ រ៉ា បានលើកឡើងដោយសង្ខេបថា ខ្សែភាពយន្តឯកសារដែលមានចំណងជើងថា «កុំស្មានបងភ្លេច» នេះ ឆ្លុះបញ្ចាំងពីប្រវត្តិសាស្ត្រកម្ពុជាតាំងសម័យសង្គមរាស្ត្រនិយម របបសាធារណរដ្ឋខ្មែរ របបខ្មែរក្រហម និងសម័យក្រោយឆ្នាំ១៩៧៩ ជាពិសេសទាក់ទងនឹងការរីកចម្រើនវិស័យសិល្បៈចម្រៀង តន្ត្រី និងការបាត់បង់ក្នុងពេលមានសង្គ្រាម

និងអំពើប្រល័យពូជសាសន៍ និងការកកើតឡើងវិញនៅក្រោយឆ្នាំ១៩៧៩។ ការចាក់បញ្ចាំងខ្សែភាពយន្ត «កុំស្មានបងភ្លេច» មានគោលបំណង៖

- ចង់ឱ្យប្រជាជនយល់ដឹងអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រខ្មែរដែលមាននៅក្នុងខ្សែភាពយន្ត
- បង្ហាញទៅកាន់យុវជន និងក្មេងៗជំនាន់ក្រោយដែលពុំធ្លាប់ទស្សនាខ្សែភាពយន្តឯកសារនេះ
- អប់រំកុំឱ្យមានសង្គ្រាមនៅក្នុងប្រទេសជាតិ និងទប់ស្កាត់អំពើប្រល័យពូជសាសន៍តាមរយៈខ្សែភាពយន្ត
- បង្កើនចំណេះដឹងតាមរយៈទស្សនាខ្សែភាពយន្ត និងឱ្យប្រជាជនចេះត្រិះរិះពិចារណា។

ជាកិច្ចបញ្ចប់ លោក ឡុង ដានី នាយកមជ្ឈ-មណ្ឌលឯកសារកោះថ្ម ធ្វើការសំណេះសំណាលជាមួយ លោកតា លោកយាយ អ៊ំ ពូមីង និងប្អូនៗ ដែលបានចូលរួមទស្សនា។ លោក ដានី បានសួរនាំ និងការយល់ឃើញក្រោយពីលោកតា យាយ អ៊ំ ទស្សនាខ្សែភាពយន្តឯកសារនេះចប់ ព្រោះលោកតា លោកយាយធ្លាប់បានឆ្លងកាត់ពីសម័យកាលសង្គ្រាម និងសម័យខ្មែរក្រហម ថាតើមានអារម្មណ៍បែបណាពេលឃើញព្រឹត្តិការណ៍ទាំងនេះម្តងទៀត? ក្រោយពីសំណេះសំណាល និងពិភាក្សាចប់ លោក ដានី បានថ្លែងអំណរគុណដល់ លោកយាយ លោកតា អ៊ំ ពូមីង និងប្អូនៗ ដែលបានចំណាយពេលចូលរួមទស្សនារហូតដល់ចប់។






យាយ តា អ៊ំ ពូមីង យុវជន និង កុមារ នៅក្នុងភូមិក្តុលលើទស្សនាខ្សែភាពយន្តឯកសារ «កុំស្មានបងភ្លេច» នៅផ្ទះសហគមន៍ភូមិក្តុលលើ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# គរុសិស្សមកពីមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម ទស្សនាពិព័រណ៍ស្តីពី

## វត្ថុប្រើប្រាស់ប្រចាំថ្ងៃរបស់អ្នករស់រានមានជីវិត នៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម

**សាំង ចាន់ធូ**



គរុសិស្សមកពីមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម ទស្សនាពិព័រណ៍ស្តីពីវត្ថុប្រើប្រាស់ប្រចាំថ្ងៃរបស់អ្នករស់រានមានជីវិត នៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានរៀបចំពិព័រណ៍អំពីវត្ថុប្រើប្រាស់ប្រចាំថ្ងៃរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ជូនដល់សិស្សានុសិស្ស អ្នកសិក្សាស្រាវជ្រាវ និងសាធារណៈជន។ ពិព័រណ៍អំពីវត្ថុប្រើប្រាស់ប្រចាំថ្ងៃរបស់អ្នករស់រានមានជីវិតរួមមាន កាមែល (ប្រអប់ដាក់អាហារ), ដែកកេះ, គុម្ពកំបោរ និងផ្តិលទឹក ត្រូវបានប្រមូលដោយអ្នកស្ម័គ្រចិត្តកម្ពុជានៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ ជាមួយគ្នានេះ មានគរុសិស្សជំនាន់ទី៣២ ឆ្នាំទី១ នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាមចំនួន១៥នាក់ បានធ្វើដំណើរមកទស្សនាពិព័រណ៍អំពីវត្ថុប្រើប្រាស់ប្រចាំថ្ងៃរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

លោក ទូច វណ្ណេត បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមបានទទួលស្វាគមន៍និងដឹកនាំគរុសិស្សទស្សនាពិព័រណ៍រូបថតចំនួន១០ផ្ទាំងធំៗដែលបង្ហាញអំពីប្រវត្តិមេដឹកនាំខ្មែរក្រហម, ព្រឹត្តិការណ៍



គរុសិស្សមកពីមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម ទស្សនាពិព័រណ៌ស្តីពីវត្ថុប្រើប្រាស់ប្រចាំថ្ងៃរបស់អ្នករស់រានមានជីវិត នៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ការជម្លៀសប្រជាជនដោយបង្ខំ, ការបង្ខំប្រជាជនឱ្យធ្វើការនៅទំនប់ជាទម្ងន់ និងការដួលរលំរបបខ្មែរក្រហមនៅដើមឆ្នាំ១៩៧៩។ បន្ទាប់មក លោក សាំង ចាន់ធូ បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បន្តដឹកនាំគរុសិស្ស ចូលទៅកាន់បណ្ណាល័យខ្មែរក្រហម និងបន្ទប់តម្កល់ឯកសារខ្មែរក្រហមដើម្បីឈ្វេងយល់អំពីធនធានឯកសារដើម និងឯកសារបន្ទាប់បន្សំដែលមាននៅក្នុងមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។

ឱកាសនោះ គរុសិស្សទាំងអស់បានទៅកាន់សាលពិព័រណ៌ ដែលមានការដាក់តាំងបង្ហាញវត្ថុប្រើប្រាស់ប្រចាំថ្ងៃរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានធ្វើបទបង្ហាញដល់គរុសិស្ស អំពីពិព័រណ៍វត្ថុប្រើប្រាស់ប្រចាំថ្ងៃរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ លោក ស៊ាង ចិន្តា បន្ថែមថា វត្ថុប្រើប្រាស់ប្រចាំថ្ងៃទាំងនេះគឺជាសក្ខីកម្មឆ្លុះបញ្ចាំងអំពីជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជាក្នុងរបបខ្មែរក្រហម និងបញ្ហាប្រឈមដែលអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបានជួបប្រទះ។ លោក ស៊ាង ចិន្តា ពន្យល់បន្ថែមអំពី «កាមែល» ដែលជាប្រអប់សម្រាប់ដាក់អាហាររបស់អ៊ំស្រី ងិន ទូច អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមរស់នៅឃុំល្អាង ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ អ៊ំស្រី ងិន ទូច បានប្រគល់ជូនដល់អ្នកស្ម័គ្រចិត្តកម្ពុជាដើម្បីថែរក្សា ពីព្រោះកាមែលនេះ គឺជាការរំឭកដល់សេចក្តីអត់ឃ្លានដែលអ៊ំស្រីរស់នៅឆ្លងកាត់របបខ្មែរក្រហម។ នៅឆ្នាំ១៩៧៧ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីចូលមកគ្រប់គ្រង និងធ្វើទុក្ខបុកម្នេញទៅលើប្រជាជនមូលដ្ឋាន។ ចាប់ពីពេលនោះមក ប្រជាជននៅមូលដ្ឋានឃុំល្អាង ទទួលរងទុក្ខលំបាក ដូចជា ការបង្ខំឱ្យធ្វើការងារជាទម្ងន់, ការបង្អត់អាហារ, ការធ្វើទារុណកម្ម និងការចាប់យកទៅសម្លាប់។ នៅថ្ងៃមួយក្នុងឆ្នាំ១៩៧៧ ដដែល ដោយសារតែអត់ទ្រាំការអត់ឃ្លានមិនបាន អ៊ំស្រី ងិន ទូច បានលួចដាំបាយក្នុងកាមែលដើម្បីហូប ប៉ុន្តែជាអកុសល សកម្មភាពដាំបាយរបស់អ៊ំស្រីត្រូវបានខ្មែរក្រហមចាប់បាន។ អ៊ំស្រី ងិន ទូច ត្រូវបានខ្មែរក្រហមយកទៅវាយធ្វើបាបយ៉ាងដំណំ និងព្រមានមិនឱ្យធ្វើខុសបែបនេះទៀត។ បន្ទាប់ពីត្រូវបានដោះលែងមកផ្ទះវិញ អ៊ំស្រី ងិន ទូច បានបោះបោល





គរុសិស្សមកពីមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម ទស្សនាពិព័រណ៍ស្តីពីវត្ថុប្រើប្រាស់ប្រចាំថ្ងៃរបស់អ្នករស់រានមានជីវិត នៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



កាមែលនេះទៅក្រោយផ្ទះ។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ អ៊ំស្រី ងិន ទូច បន្តរស់នៅ និងប្រកបរបរជាកសិករ។ នៅថ្ងៃមួយ ស្របពេលដែលអ៊ំស្រីកំពុងតែធ្វើការដាំដុះដំណាំនៅជុំវិញផ្ទះ អ៊ំស្រី ងិន ទូច បានប្រទះឃើញកាមែលរបស់ខ្លួនដែលត្រូវបានបោះបោល នៅក្នុងរបបខ្មែរក្រហម។ នៅពេលដែលឃើញកាមែលនេះភ្លាម អ៊ំស្រី ងិន ទូច នឹកឃើញពីការរស់នៅអត់ឃ្លាន និងព្រឹត្តិការណ៍ដែលខ្មែរក្រហមចាប់ខ្លួនយកទៅវាយយ៉ាងដំណំ និងមានអារម្មណ៍បាក់ស្បាតរហូតមកដល់សព្វថ្ងៃនេះ។

បន្ទាប់ពីការទស្សនាពិព័រណ៍នេះរួច គរុសិស្សបង្ហាញអំពីចំណាប់អារម្មណ៍របស់ខ្លួនដូចខាងក្រោម៖

គរុសិស្ស **សុវណ្ណា រម្យនា** ឯកទេសគណិតវិទ្យា ជំនាន់ទី៣២ ឆ្នាំទី១ នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម លើកឡើងថា ៖ «នេះគឺជាលើកទី១ ដែលខ្ញុំបានមកដល់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមនេះ។ ខ្ញុំទើបតែដឹងអំពីភាពសម្បូរបែបរបស់មជ្ឈមណ្ឌល ឯកសារខេត្តកំពង់ចាម។ បន្ថែមលើនេះទៅទៀត ខ្ញុំបានឃើញការដាក់តាំងវត្ថុប្រើប្រាស់ប្រចាំថ្ងៃរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលវត្ថុទាំងនេះបង្កប់នូវរឿងរ៉ាវដែលប្រជាជនកម្ពុជាបានរស់នៅឆ្លងក្នុងរបបខ្មែរក្រហម។ ខ្ញុំចាប់អារម្មណ៍ចំពោះដែកកេះ ដែលខ្ញុំដឹងថា ការបង្កាត់ភ្លើងសម្រាប់ចម្អិនអាហារហូប ពិតជាពិបាក ដោយសារតែខ្លាចត្រូវបានខ្មែរក្រហមចាប់ខ្លួន និងយកទៅសម្លាប់ចោល។ នៅមានចំណេះដឹងជាច្រើនទៀតដែលខ្ញុំនៅមិនទាន់ដឹង។ ខ្ញុំនឹងមកមជ្ឈមណ្ឌល ឯកសារខេត្តកំពង់ចាមនេះម្តងទៀត ពីព្រោះទីតាំងនេះមានអំណោយផលល្អសម្រាប់ការសិក្សាស្រាវជ្រាវ និងស្ថិតនៅក្បែរមជ្ឈមណ្ឌលគរុកោសល្យភូមិភាគដែលខ្ញុំកំពុងតែសិក្សា»។

គរុសិស្ស **វឿម សុជាតិ** ឯកទេសប្រវត្តិវិទ្យា ជំនាន់ទី៣២ ឆ្នាំទី១ នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម យល់ឃើញថា៖ «មជ្ឈមណ្ឌលឯកសារនេះ មានលក្ខណៈដូចជាសារមន្ទីរប្រវត្តិសាស្ត្រ ដែលមានការដាក់បង្ហាញរូបភាព សម្ភារប្រើប្រាស់ប្រចាំថ្ងៃ សៀវភៅ និងឯកសារទាក់ទងទៅនឹងប្រវត្តិសាស្ត្រខ្មែរក្រហម។ នៅពេលដែលខ្ញុំមានការស្រាវជ្រាវបន្ថែមលើអ្វីដែលខ្ញុំរៀននៅសាលា ខ្ញុំនឹងធ្វើការស្នើសុំមជ្ឈមណ្ឌល ឯកសារខេត្តកំពង់ចាម ផ្តល់ជាទីតាំងសម្រាប់អាន និងស្រាវជ្រាវ»។

# ជនជាតិភាគតិចស្ទៀង នៅភូមិក្អុលលើរៀបចំពិធីបុណ្យផ្កាប់វេនព្រះសង្ឃគង់ចាំព្រះវស្សា

## នៅផ្ទះសហគមន៍ភូមិក្អុលលើ នៃមជ្ឈមណ្ឌលឯកសារកោះថ្ម

ឈុំ រ៉ា



ជនជាតិភាគតិចស្ទៀងនៅក្នុងភូមិក្អុលលើ រៀបចំពិធីបុណ្យផ្កាប់វេនព្រះសង្ឃគង់ចាំព្រះវស្សា នៅផ្ទះសហគមន៍ភូមិក្អុលលើ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៤ អាដ្ឋាធរ ព្រះសង្ឃ អាចារ្យ គណៈកម្មការ និងប្រជាជនភូមិក្អុលលើទាំងមូល បានរួមមតិគ្នាធ្វើកម្មវិធីបុណ្យឆ្លងផ្កាប់វេនព្រះសង្ឃគង់ចាំព្រះវស្សា នៅផ្ទះសហគមន៍ភូមិក្អុលលើ បុសាលាគរុភណ្ឌស្ទៀង នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ ជារៀងរាល់ឆ្នាំប្រជាជននៅក្នុងភូមិក្អុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ តែងតែផ្គត់ផ្គង់ចង្ហាន់ព្រះសង្ឃដែលគង់ចាំព្រះវស្សា។

នៅក្នុងឃុំទន្លូង មានភូមិចំនួន១៣ និងប្រជាជនសរុបចំនួន១៧,៣០០នាក់ ស្មើនឹង ១,៣៣៦ គ្រួសារ។ ប្រជាជនបានចែកវេនគ្នាដើម្បីផ្គត់ផ្គង់ចង្ហាន់ដល់ព្រះសង្ឃគង់ចាំព្រះវស្សា នៅវត្តហត្ថិវនារាមក្អុល ហៅវត្តក្អុល។ ក្នុងចំណោមភូមិទាំង១៣ ភូមិក្អុលលើ មានប្រជាជនចំនួន១៥១គ្រួសារ ស្មើនឹង៧ ៣៨ នាក់ បានរៀបចំកម្មវិធីបុណ្យផ្កាប់វេនព្រះសង្ឃគង់ចាំព្រះវស្សានៅផ្ទះសហគមន៍ភូមិក្អុលលើ បុសាលាគរុភណ្ឌស្ទៀង នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។

យោងទៅតាមអាចារ្យម៉ែនញឹមមានប្រសាសន៍ថា ក្នុងព្រះវិន័យដែលព្រះសម្មាសម្ពុទ្ធបញ្ញត្តិឱ្យភិក្ខុសង្ឃគង់ចាំព្រះវស្សារយៈពេល៣ខែក្នុងរដូវ

វស្សា។ ពិធីផ្តាច់វេន ឬឆ្លងវេន នៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ មានគោលបំណង៖

១) បង្ហាញពីការសាមគ្គីរបស់ប្រជាជនភូមិក្តុលលើ ដែលផ្គត់ផ្គង់ចង្ហាន់ព្រះសង្ឃគង់ចាំព្រះវស្សា អស់រយៈពេល៣ខែ ក្នុងរដូវវស្សា។

២) សូមខមាទោសនូវរាល់កំហុសឆ្គងដែលបានប្រព្រឹត្តកន្លងមកចំពោះភិក្ខុសង្ឃ

៣) បង្កើតការជួបជុំគ្រួសារ សាច់ញាតិ និងបងប្អូន

៤) បង្កើនទំនាក់ទំនងល្អ និងការស្និទ្ធស្នាល

៥) បណ្តុះគំនិតឱ្យចេះធ្វើបុណ្យ និងសាងអំពើល្អ

លោកអាចារ្យ ម៉ែន ញឹម បន្ថែមថា ចំពោះពិធីចេញព្រះវស្សា គឺមានគោលបំណងធំៗចំនួនពីរគឺ៖

១) ឱ្យភិក្ខុសង្ឃ ទាំងអស់អង្គចេះកែខ្លួនពេលដែលប្រណិប័តន៍ខុសពីឱវាទព្រះពុទ្ធដោយឱ្យព្រះសង្ឃផ្សេងទៀតជួយណែនាំ, ជួយបង្ហាញផ្លូវប្រណិប័តន៍ឱ្យបានត្រឹមត្រូវតាមពុទ្ធឱវាទ។ ២) ឱ្យពុទ្ធបរិស័ទទូទៅអាចរៀនសូត្រ និងឈ្វេងយល់អំពីការរៀបចំពិធីចេញព្រះវស្សារបស់ព្រះភិក្ខុសង្ឃ ដោយបង្កើតឱ្យមានការជួបជុំក្នុងគ្រួសារ, សហគមន៍, ស្ថាប័នឬអង្គភាពរបស់ខ្លួនដើម្បីផ្លាស់ប្តូរយោបល់ល្អៗពីគ្នាទៅវិញទៅមក កែប្រែរាល់កំហុសឆ្គងទាំងឡាយ ដើម្បីការរស់នៅសុខសាន្ត។

ប្រជាជននៅក្នុងសហគមន៍ភូមិក្តុលលើដែលបានចូលរួមនៅក្នុងពិធីបុណ្យនេះ សម្តែងនូវសេចក្តីរីករាយ និងលើកឡើងនូវការយល់ឃើញដូចខាងក្រោម៖

១) ខ្ញុំឈ្មោះ **ជា គីមហ៊ីម** អាយុ៦៨ឆ្នាំ កើតនៅភូមិជាំទ្រៀក ឃុំត្រមូង ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំសប្បាយចិត្តណាស់ពេលគណៈកម្មាធិការនៅក្នុងភូមិក្តុលលើ បានស្រុះស្រួលមូលមតិគ្នារៀបចំកម្មវិធីធ្វើបុណ្យក្នុងថ្ងៃនេះ។ ជាពិសេសពិធីបុណ្យផ្តាច់វេនចុងក្រោយនេះ ដើម្បីរៀបចំចង្ហាន់សម្រាប់ប្រគេនដល់ព្រះសង្ឃនៅក្នុងវត្តហត្ថិវនារាមក្តុល។ ខ្ញុំពិតជារំភើបរីករាយពេលឃើញបងប្អូនជនជាតិភាគតិចស្ទៀងរួមទាំងប្រជាជនខ្មែរ នៅក្នុងភូមិក្តុលលើរួបរួមគ្នាធ្វើបុណ្យធំបែបនេះ។ ខ្ញុំក៏សូមអរគុណដល់ម្ចាស់ជំនួយដែលបានសាងសង់សាលាបុណ្យ (ផ្ទះសហគមន៍ភូមិក្តុលលើ) ជូនបងប្អូនជនជាតិដើមភាគតិចស្ទៀងនៅក្នុងភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំនេះ។


កូនចៅជនជាតិភាគតិចស្ទៀងនៅក្នុងភូមិក្តុលលើ រៀបចំពិធីបុណ្យផ្តាច់វេនព្រះសង្ឃគង់ចាំព្រះវស្សា នៅផ្ទះសហគមន៍ភូមិក្តុលលើ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំមានម្តាយឈ្មោះ សាំង ស៊ីម ស្លាប់នៅពេលថ្មីៗនេះ និងឪពុកឈ្មោះ ជា ស្លាប់ពេលនៅឆ្នាំ១៩៩៣។ ខ្ញុំមានប្រពន្ធពីរនាក់ គឺប្រពន្ធមុនឈ្មោះ ឆ្លាំង ហេង និងមានកូន៦នាក់ គឺប្រុស៥នាក់ និងស្រី១នាក់។ ប្រពន្ធមុនរបស់ខ្ញុំបានស្លាប់ហើយ។ ខ្ញុំយកប្រពន្ធក្រោយឈ្មោះ ឈ្នាង ថេ ប៉ុន្តែយើងគ្មានកូនទេ។ ខ្ញុំមានបងប្អូន២នាក់ គឺប្រុសទាំងពីរ។ បងប្រុសរបស់ខ្ញុំធ្វើគ្រូបង្រៀន ពេលនោះកងទ័ពខ្មែរក្រហមបានទិតៀនគាត់ថា គាត់គឺជាមនុស្សបាតសង្គមមិនជួយធ្វើការងារ គឺចាំតែស៊ីស្រាប់។ ព្រោះដូច្នេះបងប្រុសខ្ញុំក៏ឈប់ធ្វើជាគ្រូបង្រៀន រួចហើយចូលបម្រើកងទ័ពខ្មែរក្រហម ដើម្បីវាយផ្តួលរំលំរបបលន់នល់។ ចាប់តាំងពីថ្ងៃនោះមក បងប្រុសខ្ញុំក៏បាត់ខ្លួនរហូត។

២) ខ្ញុំឈ្មោះ **សាមុត មៅរ៉េត** ភេទស្រី អាយុ៣៥ឆ្នាំ មានប្តីឈ្មោះ សុខ សឿង អាយុ៣៧ឆ្នាំ និងមានកូនចំនួន២នាក់។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ថ្ងៃនេះ ខ្ញុំមាន



ជនជាតិភាគតិចស្ទៀងនៅក្នុងភូមិក្តុលលើ រៀបចំពិធីបុណ្យផ្កាប់វេនព្រះសង្ឃគង់ចាំព្រះវស្សា នៅផ្ទះសហគមន៍ភូមិក្តុលលើ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





អារម្មណ៍សប្បាយរីករាយ ដែលបានចូលរួមពិធីបុណ្យផ្កាប់វេននៅរោងបុណ្យថ្មីដ៏ធំស្កឹមស្កៃដែលក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា បានចំណាយថវិកាសាងសង់ជូនប្រជាជននៅក្នុងភូមិក្តុលលើ ក៏ដូចប្រជាជននៅក្នុងឃុំទន្លូងទាំងមូល សម្រាប់ធ្វើបុណ្យទាន ជួបជុំគ្នា និងពិភាក្សារឿងរ៉ាវផ្សេងៗដែលកើតមាននៅក្នុងភូមិដើម្បីដោះស្រាយ និងអភិវឌ្ឍន៍ភូមិឃុំឱ្យកាន់តែរីកចម្រើន។ ខ្ញុំមានអារម្មណ៍ប្លែក ព្រោះនៅក្នុងឃុំទន្លូងទាំងមូល គឺមានតែនៅភូមិក្តុលលើដែលមានរោងបុណ្យស្អាត និងរចនាម៉ូតប្លែកខុសពីកន្លែងដទៃ។ ជាពិសេស ខ្ញុំឃើញមានសិស្សានុសិស្សជាច្រើនបានមកអានសៀវភៅនៅទីនេះ។ ខ្ញុំគិតថា រោងបុណ្យនេះក៏ជាទីកន្លែងសម្រាប់ផ្តល់ចំណេះដឹងដល់ក្មេងៗជំនាន់ក្រោយ និងជាកន្លែងសម្រាប់ធ្វើបុណ្យទានផងៗ ជាចុងក្រោយខ្ញុំសូមអរគុណដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ដែលបានផ្តួចផ្តើមសាងសង់រោងបុណ្យនេះឡើងវិញ សម្រាប់ប្រជាជនក្នុងភូមិងាយស្រួលក្នុងការរៀបចំពិធីបុណ្យទានផ្សេងៗ និងបន្សល់ទុកឱ្យក្មេងជំនាន់ក្រោយបានឃើញ។ ខ្ញុំសូមជូនពរឱ្យក្រុមការងារទទួលបានជោគជ័យគ្រប់ភារកិច្ច និងបន្តអភិវឌ្ឍន៍សហគមន៍។

# មជ្ឈមណ្ឌលផ្សះផ្សាវាលវែងបញ្ចាំងខ្សែភាពយន្តឯកសាររឿង «កុំស្មានបងភ្លេច» ឱ្យ សិស្សមកពីវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយទស្សនាដើម្បីយល់ដឹងអំពីការបាត់បង់តន្ត្រីអំឡុងពេលសង្គ្រាម និងប្រវត្តិសាស្ត្រខ្មែរក្រហម

**ធី គីមហុង**




មជ្ឈមណ្ឌលផ្សះផ្សាវាលវែងចាក់បញ្ចាំងខ្សែភាពយន្តឯកសារ «កុំស្មានបងភ្លេច» ឱ្យសិស្សមកពីវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយទស្សនា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៤ សិស្សមកពីវិទ្យាល័យ ហ៊ុនសែនប្រម៉ោយចំនួន២១នាក់ បានមកធ្វើទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលផ្សះផ្សាវាលវែង និងទស្សនាខ្សែភាពយន្តឯកសាររឿង «កុំស្មានបងភ្លេច» ខ្មែរបាត់បង់តន្ត្រីរ៉ក់។ ជាកិច្ចចាប់ផ្ដើម លោក ឡុង ដានី នាយកមជ្ឈមណ្ឌលផ្សះផ្សាវាលវែងបានណែនាំខ្លួន និងបានរៀបរាប់អំពីគោលបំណងនៃការបញ្ចាំងខ្សែភាពយន្តឯកសាររឿង «កុំស្មានបងភ្លេច» នៅពេលនេះ។ លោក ឡុង ដានី បន្ថែមថា ខ្សែភាពយន្តឯកសារនេះ គឺចង់បង្ហាញពីទិដ្ឋភាពសង្គម និងសិល្បៈក្នុងរបបសង្គមរាស្ត្រនិយម សង្គ្រាមស៊ីវិលក្រោយរដ្ឋប្រហារ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ និងរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ ការបាត់បង់តន្ត្រីរ៉ក់ក្នុងរបបប្រល័យពូជសាសន៍ខ្មែរក្រហម និងការរស់ឡើងវិញបន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ ឆ្លៀត

ឱកាសនោះ លោក ឡុង ដានី បានលើកនូវប្រធានបទដើម្បីពិភាក្សាជាមួយសិស្សានុសិស្ស ទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហម (ពីឆ្នាំ១៩៧៥-១៩៧៩) ដើម្បីឱ្យសិស្សានុសិស្សយល់បន្ថែមទៀត។

បន្ទាប់ពីការពិភាក្សា និងទស្សនាខ្សែភាពយន្តឯកសាររឿង «កុំស្មានបងភ្លេច» រួច សិស្សបង្ហាញចំណាប់ដូចខាងក្រោម៖

១) ខ្ញុំឈ្មោះ **សុក សាខុង** ភេទប្រុស អាយុ១៨ឆ្នាំ រៀននៅវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ។ ក្រោយពីទស្សនាការចាក់ខ្សែភាពយន្តឯកសាររឿង «កុំស្មានបងភ្លេច» ខ្ញុំមានអារម្មណ៍ថាថ្មីហើយប្លែក នៅពេលស្តាប់បទចម្រៀងតាមសម័យកាលនីមួយៗ និងបានឃើញទិដ្ឋភាពទីក្រុងភ្នំពេញមុនពេលមានសង្គ្រាមដែលមានសភាពអ៊ូអរ និងមានតន្ត្រីច្រើនសម្បូរបែប។ ចូលដល់របបកម្ពុជាប្រជាធិបតេយ្យ តន្ត្រីស្ទើរតែបាត់បង់ទាំងស្រុង ហើយសិល្បករបានបាត់បង់ជីវិតអស់ជាច្រើននាក់។ នៅក្នុងខ្សែភាពយន្តក៏បានបង្ហាញអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ហើយខ្មែរក្រហមបង្កើតទម្រង់សិល្បៈរបស់ខ្លួនដែលខុសពីសម័យដើម។

២) ខ្ញុំឈ្មោះ **ធុំ សុនិតា** ភេទស្រី អាយុ១៨ឆ្នាំ រៀននៅវិទ្យាល័យ ហ៊ុនសែនប្រម៉ោយ។ ខ្ញុំសំណូមពរដល់ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងបន្តចាក់បញ្ចាំងខ្សែភាពយន្តឯកសារ «កុំស្មានបងភ្លេច» ឬខ្សែភាពយន្តឯកសារផ្សេងៗទាក់ទងនឹងប្រវត្តិសាស្ត្រប្រទេសកម្ពុជាឱ្យខ្ញុំទស្សនា ព្រោះការចាក់បញ្ចាំងខ្សែភាពយន្តនេះបានជួយដល់ការសិក្សា បានផ្តល់ចំណេះដឹង និងការចងចាំដល់ខ្ញុំ និងសិស្សានុសិស្សដទៃ ជាជាងការសិក្សាតាមសៀវភៅតែមួយមុខ។

៣) ខ្ញុំឈ្មោះ **សុខ ស៊ីម៉ា** ភេទស្រី អាយុ១៨ឆ្នាំ មកពីវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ។ នាងខ្ញុំពិតជាមានចិត្តរំភើបរីករាយខ្លាំងណាស់ដែលបានចូលរួមទស្សនាខ្សែភាពយន្ត «កុំស្មានបងភ្លេច» នៅក្នុងមជ្ឈមណ្ឌលផ្សះផ្សាវាលវែង។ ពេលដែលខ្ញុំទស្សនាខ្សែភាពយន្ត «កុំស្មានបងភ្លេច» បានធ្វើឱ្យខ្ញុំយល់ដឹងច្រើនអំពីតន្ត្រីករដែលរស់នៅក្នុងសម័យសង្គមរាស្ត្រនិយម ការស្លៀកពាក់ម៉ូតសក់បទចម្រៀងបែបកន្ត្រាក់អារម្មណ៍។ ខ្ញុំក៏អាណិតអាសូរសិល្បករដែលល្បីៗជំនាន់មុនដូចជា៖ ស៊ីនស៊ីសាមុត, រស់សេរីសុទ្ធា, សុះ ម៉ាត់, ហួយ មាស ដែលបានបាត់បង់ជីវិតក្នុងរបបខ្មែរក្រហម។ ជាចុងក្រោយ ខ្ញុំសំណូមពរដល់មជ្ឈ-មណ្ឌលផ្សះផ្សាវាលវែង ប្រសិនបើមានការចាក់បញ្ចាំងកុនឯកសារ ឬមានកម្មវិធីអប់រំប្រវត្តិសាស្ត្រផ្សេងៗ ខ្ញុំសូមចូលរួមម្តងទៀត។

៤) ខ្ញុំឈ្មោះ **ថា អាលីសា** ភេទស្រី អាយុ១៨ឆ្នាំ ជាសិស្សមកពីវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ។ ខ្ញុំពិតជាសប្បាយរីករាយយ៉ាងខ្លាំងណាស់ ដែលបានមកទស្សនកិច្ច និងទស្សនាខ្សែភាពយន្តរឿង «កុំស្មានបងភ្លេច» ដែលបានរៀបរាប់អំពីសិល្បករតាំងពីសម័យសង្គមរាស្ត្រនិយម សាធារណរដ្ឋ





លោក ឡុង ដានី នាយកមជ្ឈមណ្ឌលផ្សះផ្សាវាលវែង ធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) ដល់សិស្សមកពីវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយទស្សនា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្មែរ របបកម្ពុជាប្រជាធិបតេយ្យ និងបទចម្រៀងដែលបានបាត់បង់។ ខ្ញុំទទួលបានចំណេះដឹងជាច្រើនពីខ្សែភាពយន្តនេះ ដែលខុសប្លែកពីសៀវភៅដែលខ្ញុំបានរៀនសូត្រនៅតាមសាលារៀន។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់មជ្ឈមណ្ឌលផ្សះផ្សាវាលវែងដែលបានអញ្ជើញខ្ញុំចូលរួមទស្សនាខ្សែភាពយន្តនេះ។









សិស្សមកពីវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ ទស្សនាខ្សែភាពយន្តឯកសារ «កុំស្មានបងភ្លេច» និងសិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលផ្សះផ្សាវាលវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលផ្សះផ្សាវាលវែង ផ្តល់រទេះរុញជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានពិការភាព នៅឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់

ឡាំ ស្រីនីត, មឿន ស្រីណុច, ចាន់ ណារិទ្ធ និង ធី គឹមហុង



មជ្ឈមណ្ឌលផ្សះផ្សាវាលវែង ផ្តល់រទេះរុញជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាព នៅឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពីថ្ងៃទី១៤ ដល់ ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៤ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានផ្តល់រទេះរុញដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពចំនួន៤នាក់ រស់នៅភូមិសំរោង២ ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនពិការចំនួន៤នាក់មានវ័យចាស់ជរា និងមានជីវភាពខ្វះខាត។ លោក ឡុង ដានី នាយកមជ្ឈមណ្ឌលផ្សះផ្សាវាលវែងបានលើកឡើងពីគោលបំណងនៃការចែករទេះរុញ គឺដើម្បីជួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពអាចជិះនៅជុំវិញផ្ទះ ទៅលេងសាច់ញាតិក្នុងភូមិ ទៅចូលរួមប្រជុំ និងទៅបុណ្យ។ នៅក្នុងឱកាសនោះ លោក ឡុង ដានី លើកទឹកចិត្តដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពទាំងនោះឱ្យចែករំលែកនូវរឿងរ៉ាវដែលធ្លាប់ឆ្លងកាត់ពីរបបប្រល័យពូជសាសន៍ទៅកាន់កូនចៅ និងក្មេងៗជំនាន់ក្រោយឱ្យបានដឹងពីទុក្ខ

លំបាករបស់គាត់ដែរ។ ការនិយាយរឿងរ៉ាវពីរបបខ្មែរក្រហមនឹងធ្វើឱ្យកូនចៅ និងក្មេងៗជំនាន់ក្រោយមានការអាណិតស្រឡាញ់តាយាយ ឪពុកម្តាយរបស់ខ្លួន ដែលខិតខំតស៊ូរស់នៅ និងចិញ្ចឹមកូនចៅរបស់ខ្លួនបានរស់នៅដូចសព្វថ្ងៃនេះ។

បន្ទាប់មកអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានពិការភាពទាំង៤នាក់ បានបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម៖



## ១) តែម ព្រីង៖ អ្នកបោចវល្លិធ្វើដៃបន្តក្នុងសម័យខ្មែរក្រហម

ខ្ញុំសប្បាយចិត្តនិងរំភើបយ៉ាងខ្លាំង នៅពេលបានដឹងថាក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង ចែករទេះរុញឱ្យខ្ញុំ និងប្រជាជននៅក្នុងភូមិ។ រទេះរុញនេះមានសារសំខាន់ខ្លាំងណាស់សម្រាប់ខ្ញុំ និងគ្រួសារ ព្រោះងាយស្រួលក្នុងការដឹះផ្លាស់ទីទៅជិតឬឆ្ងាយ ងាយស្រួលចូលបន្ទប់ទឹកដោយមិនចាំបាច់ប្រើឈើច្រត់ដូចពីមុនទៀត។ កូនៗខ្ញុំមិនចាំបាច់គ្រាខ្ញុំពេលទៅលេងផ្ទះបងប្អូនកូនចៅម្តងៗ និងងាយស្រួលដាក់តាមខ្លួនពេលខ្ញុំទៅព្យាបាលនៅមន្ទីរពេទ្យ។ ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមជ្ឈមណ្ឌលផ្សះផ្សាវាលវែង ដែលបានយកចិត្តទុកដាក់ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងភូមិរបស់ខ្ញុំ។

ខ្ញុំឈ្មោះ តែម ព្រីង ភេទប្រុស អាយុ៧៨ឆ្នាំ មានស្រុកកំណើតនៅភូមិសំរោង ឃុំផ្ទះរុង ស្រុកបាកាន ខេត្តពោធិ៍សាត់។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិសំរោង២ ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ ខ្ញុំមានឪពុកឈ្មោះ តែម និងម្តាយឈ្មោះ ចេង អ៊ុល។ ឪពុកម្តាយខ្ញុំបានស្លាប់អស់ហើយ។ ខ្ញុំមានបងប្អូនចំនួន៧នាក់ ហើយខ្ញុំគឺជាកូនច្បងនៅក្នុងគ្រួសារ។ ខ្ញុំមានប្រពន្ធឈ្មោះ ហ៊ុន នាង និងមានកូនចំនួន៥នាក់។

កាលពីតូចខ្ញុំរស់នៅជាមួយម្តាយឪពុកប្រកបរបរធ្វើស្រែចម្ការ។ នៅអាយុ២១ឆ្នាំ ខ្ញុំសម្រេចចិត្តបួសរៀនដើម្បីទទួលបាននូវចំណេះដឹងជាប់ខ្លួន។ ខ្ញុំបួសរៀននៅវត្តកណ្តាលជាមួយព្រះចៅអធិការវត្តឈ្មោះ សៀក។ ខ្ញុំបួសបានរយៈពេល២ព្រះវស្សាក៏សឹកវិញដោយសារភ្នែកខ្ញុំងងឹត។ ខ្ញុំបានត្រឡប់មករស់នៅជាមួយឪពុកម្តាយ និងសម្រាកព្យាបាលភ្នែកមួយរយៈទើបធូរស្បើយវិញ។

នៅឆ្នាំ១៩៧០ ពេលសេនាប្រមុខ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ខ្ញុំរស់នៅជាមួយឪពុកម្តាយនៅក្នុងភូមិសំរោង ដោយប្រកបរបរធ្វើស្រែចម្ការ។ ពេលនោះ អាហារហូបចុកមិនខ្វះខាតទេ គឺមានហូបគ្រប់គ្រាន់។ ក្រោយមកមានទាហានជាច្រើនបានចូលមកដល់ភូមិរបស់ខ្ញុំ ព្រមទាំងបាញ់កាំភ្លើងបន្លើលប្រជាជនរត់ឈូឆរពេញភូមិ។ នៅឆ្នាំ១៩៧២ ខ្ញុំនិងគ្រួសារបានផ្លាស់ទីលំនៅមករស់នៅភូមិផ្ទះរុង ដោយខ្លាចកងទ័ពខ្មែរក្រហមធ្វើបាប។ ខ្ញុំរស់នៅទីនោះរយៈពេល៣ខែទើបត្រឡប់មករស់នៅភូមិសំរោងវិញ។ នៅក្នុងឆ្នាំ១៩៧៣ ទាហាន លន់ នល់ បានទម្លាក់គ្រាប់បែកនៅភូមិចាន់សេរី ធ្វើឱ្យប្រជាជននៅក្នុងភូមិខ្ញុំច្របូកច្របល់យ៉ាងខ្លាំង ពីព្រោះខ្លាចយន្តហោះមកទម្លាក់គ្រាប់នៅភូមិសំរោងដែរ។ នៅចុងឆ្នាំ១៩៧៣ ខ្មែរក្រហមបានវាយបែកស្រុកភ្នំក្រវាញទាំងស្រុង ប៉ុន្តែខ្មែរក្រហមមិនទាន់ចូលមកគ្រប់គ្រងភូមិសំរោងភ្លាមទេ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមគ្រប់គ្រងប្រទេសកម្ពុជាទាំងស្រុង ពេលនោះប្រជាជនទាំងអស់នៅក្នុងភូមិសំរោង រស់នៅនិងប្រកបរបរធ្វើស្រែធម្មតា។ ខ្មែរក្រហមមិនទាន់បានបែងចែកការងារដល់ប្រជាជនទេ។ ខ្ញុំជាមួយគ្រួសារបានរស់នៅភូមិសំរោង ដោយប្រកបរបរធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិត។ ពេលនោះអាហារហូបចុកមិនទាន់ខ្វះខាតទេ ពីព្រោះខ្មែរក្រហមមិនទាន់បានដកហូតរបស់របរ និងទ្រព្យសម្បត្តិមកដាក់រួម។ នៅចុងឆ្នាំ១៩៧៥ ខ្មែរក្រហមចាប់ផ្តើមដើរប្រមូលទ្រព្យ

សម្បត្តិប្រជាជនទាំងអស់ដាក់នៅរួមគ្នា រួមមាន ស្រូវ អង្ករ ចាន ឆ្នាំង និងរបស់របរមានតម្លៃផ្សេងៗទៀត។ ក្រោយមកខ្មែរក្រហមបែងចែកការងារដល់ប្រជាជនទាំងអស់នៅក្នុងភូមិសំរោង។ ប្រជាជនត្រូវធ្វើស្រែរួម ហូបរួម និងដេកនៅក្នុងសហករណ៍រួមៗ ខ្មែរក្រហមប្រើឱ្យប្រជាជនទាំងអស់ធ្វើការងារចាប់ពីម៉ោង៧ព្រឹក ដល់ម៉ោង១១ថ្ងៃត្រង់ ទើបបានសម្រាកហូបបាយ។ លុះដល់ម៉ោង១រសៀលប្រជាជនចាប់ផ្តើមចូលធ្វើការងារបន្តរហូតដល់ម៉ោង៥ល្ងាចទើបឈប់សម្រាកនិងត្រឡប់ទៅតាមកន្លែងរៀងៗខ្លួន។

នៅឆ្នាំ១៩៧៦ ខ្មែរក្រហមផ្លាស់ខ្ញុំឱ្យទៅបោចវល្លិ៍នៅភូមិដំណាក់កន្សែង ដើម្បីយកមកធ្វើដៃបង្គីឱ្យប្រជាជនយកទៅរែកដី។ បន្ទាប់មក ខ្មែរក្រហមតែងតាំងខ្ញុំជាប្រធានក្រុមនៅកន្លែងបោចវល្លិ៍ ដោយក្នុងមួយក្រុមមានសមាជិកចំនួន៣នាក់។ ក្រៅពីបោចវល្លិ៍ និងធ្វើបង្គី ខ្ញុំជាមួយសមាជិកក្រុមបាននាំគ្នាធ្វើចន្ទុះដើម្បីដុតបំភ្លឺនៅពេលយប់។ សម័យនោះអាហារហូបចុកមិនគ្រប់គ្រាន់ទេ គឺមានតែបបររាវៗតែប៉ុណ្ណោះ ដូច្នេះខ្ញុំត្រូវដើរជីកក្តួលល្ហុង និងក្តួលចេក យកមកហូបបន្ថែម។

នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានផ្លាស់ខ្ញុំឱ្យមកធ្វើការនៅក្នុងភូមិសំរោង២ ដោយធ្វើការងារជាមួយកងចល័តយុវជនលើកប្រព័ន្ធភ្លឺស្រែ ដោយក្នុងមួយថ្ងៃខ្មែរក្រហមកំណត់កងចល័តម្នាក់លើកឱ្យបាន៤ម៉ែត្រគុប។ ប្រសិនបើលើកមិនហើយ នឹងត្រូវពិន័យគុណជាពីរដងមិនខាន។ មួយកងចល័តមានយុវជនចំនួន១០០នាក់ ដូច្នេះយុវជនទាំងអស់ត្រូវតែរូតរះញាប់ដៃជើងប្រឹងប្រែងធ្វើការមិនហ៊ានឈប់សម្រាកឡើយ។ នៅឆ្នាំ១៩៧៨ ខ្ញុំផ្លាស់ទៅធ្វើជាអ្នកដឹកជញ្ជូនអង្ករ ត្រី ប្រហុក យកទៅចែកប្រជាជននៅភូមិស្វាយដូនកែវ។ ចាប់តាំងពីចូលកងដឹកជញ្ជូន ខ្ញុំទទួលបានអាហារហូបចុកគ្រប់គ្រាន់ ដោយក្នុងមួយថ្ងៃខ្ញុំទទួលបានអង្ករមួយកំប៉ុង ហូបគ្នា២នាក់។ បន្ទាប់មកខ្មែរក្រហមបានផ្សំផ្គុំឱ្យខ្ញុំមានគ្រួសារ។ ថ្ងៃខ្ញុំរៀបការ គឺមានចំនួន១២គូ ដោយគ្រាន់តែយើងចាប់ដៃគ្នាហើយ ឡើងប្តេជ្ញាចិត្តតែប៉ុណ្ណោះ។

នៅឆ្នាំ១៩៧៩ កងទ័ពរបស់វៀតណាមចូលមករំដោះប្រជាជនកម្ពុជាឱ្យរួចផុតពីរបបខ្មែរក្រហម។ ខ្ញុំត្រឡប់មកជួបជាមួយប្រពន្ធនៅភូមិមុខរារថភ្លើង។ នៅក្នុងឆ្នាំ១៩៨០ ខ្ញុំរស់នៅជាមួយប្រពន្ធដោយប្រកបរបរធ្វើស្រែរួមគ្នាជាមួយប្រជាជននៅក្នុងភូមិ។ រហូតដល់រដូវប្រមូលផលស្រូវ ទើបយើងចែកផលស្មើៗគ្នា។ នៅក្នុងឆ្នាំ២០១៩ ខ្ញុំបានផ្លាស់ទីលំនៅមករស់នៅភូមិសំរោងវិញដើម្បីនៅជិតកូនស្រីច្បងៗ ខ្ញុំបានប្រកបរបរធ្វើស្រែជាមួយប្រពន្ធ ប៉ុន្តែមកដល់បច្ចុប្បន្នខ្ញុំចាស់ជរាហើយ គឺនៅអង្គុយតែមួយកន្លែងប៉ុណ្ណោះ ព្រោះខ្ញុំធ្លាក់ខ្លួនពិការអស់រយៈពេលមួយឆ្នាំហើយ។ មូលហេតុដែលខ្ញុំធ្លាក់ខ្លួនពិការ គឺដោយសារតែជំងឺទឹកនោមផ្អែម និងមានអាការ ហើមដៃជើង អស់កម្លាំង ញ័រដៃជើងៗ។



## ២) គុំ ផាត ៖ នៅកងដឹកជញ្ជូន

ខ្ញុំសប្បាយរីករាយ និងអរគុណដល់មជ្ឈ-មណ្ឌលផ្សះផ្សាវាលវែង ដែលបានផ្តល់រទេះរុញនេះឱ្យខ្ញុំ។ ខ្ញុំនឹងឱ្យកូនចៅជួយរុញរទេះខ្ញុំជុំវិញផ្ទះបំបាត់ការអផ្សុក ទៅពេទ្យពិនិត្យសុខភាព ទៅជួបមិត្តភក្តិបងប្អូន ទៅធ្វើបុណ្យនៅវត្តព្រោះការធ្វើបុណ្យធ្វើឱ្យខ្ញុំជ្រះថ្លា។

ខ្ញុំឈ្មោះ គុំ ផាត ភេទស្រី អាយុ៧៥ឆ្នាំ។ ខ្ញុំមិនមានមុខរបរអ្វីនោះទេ គឺចាស់ជរារស់នៅជាមួយកូនស្រីពៅ។ ខ្ញុំមានស្រុកកំណើតនៅក្នុងភូមិសំរោង ឃុំផ្ទះរុង ស្រុកបាកាន ខេត្តពោធិ៍សាត់។ បច្ចុប្បន្នខ្ញុំរស់នៅ ភូមិសំរោង២ ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ ខ្ញុំបែកគ្នាជាមួយប្តីយូរណាស់មកហើយ និងមានកូនចំនួន៩នាក់។ កូនៗរបស់ខ្ញុំសព្វថ្ងៃនៅរស់រានមានជីវិត៦នាក់ គឺស្រីទាំងអស់។

កាលនៅតូចខ្ញុំរៀនសូត្របន្តិចបន្តួចៗ ឪពុក

ម្តាយខ្ញុំមានជីវភាពធូរធារតាំងពីសម័យសង្គមរាស្ត្រនិយម។ នៅភូមិសំរោង ខ្មែរក្រហមចាប់ផ្តើមកើតតាំងពីឆ្នាំ១៩៧០ ហើយនៅពេលនោះដែរ ប្រជាជនរស់នៅក្នុងភាពច្របូកច្របល់ព្រោះមានសង្គ្រាម និងរត់គេចខ្លួនពីការទម្លាក់គ្រាប់បែក។ ប្រជាជនមិនសូវបានរស់នៅក្នុងភូមិជាប់លាប់ទេ។ រហូតឆ្នាំ១៩៧២ ខ្មែរក្រហមបានវាយចូលដល់លាច ហើយចូលមកគ្រប់គ្រងក្នុងភូមិសំរោងទាំងស្រុង។

នៅចន្លោះឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ខ្ញុំធ្វើការនៅក្នុងកងចល័ត មិនដែលបានរស់នៅជុំជាមួយប្តីនិងកូនឡើយ។ ក្រោយមក ខ្ញុំនៅកងដឹកជញ្ជូនតាមរទេះ ពេលនោះខ្មែរក្រហមបានប្រើខ្ញុំឱ្យធ្វើការងារគ្មានពេលសម្រាកឡើយ។ ខ្ញុំត្រូវលីបាវស្រូវ ដឹកកណ្តាប់ និងរែកដីថែមទៀត។ បន្ទាប់មកខ្ញុំត្រូវបររទេះទៅដឹកថ្ម ហើយថ្ងៃខ្លះ ខ្ញុំត្រូវទៅដឹកឈើហ៊ុប។ ពេលនោះកូនៗរបស់ខ្ញុំដែលធំខ្លះនៅកងចល័ត កូនខ្លះនៅកងកុមារ ចំណែកកូនតូចៗ២នាក់ទៀត នៅជាមួយខ្ញុំដោយដើរតាមខ្ញុំទៅធ្វើការក្រោមកម្តៅថ្ងៃ និងភ្លៀងផ្គរកម្សត់ណាស់។ ខ្ញុំទទួលបានរបបដែលមានតែបបររាវៗប៉ុណ្ណោះ ធ្វើឱ្យខ្ញុំគ្មានកម្លាំងកំហែងឡើយ។ ខ្ញុំចេញទៅធ្វើការងារឆ្ងាយៗពីភូមិ។ ខ្ញុំចាំបានថា នៅថ្ងៃមួយ ខ្ញុំបានលួចទៅលេងម្តាយ ហើយខ្ញុំស្រក់ទឹកភ្នែកអាណិតគាត់ ព្រោះឃើញគាត់អត់ឃ្លាន និងគ្មានអាហារហូប។ មិនយូរប៉ុន្មានម្តាយរបស់ខ្ញុំក៏បានស្លាប់ដោយសារអត់អាហារ។ ខ្ញុំឈឺចាប់ព្រោះត្រូវបាត់បង់ម្តាយ និងមនុស្សជាទីស្រឡាញ់អស់ជាច្រើននាក់នៅក្នុងរបប ប៉ុល ពត។ ចំណែកកូនៗខ្ញុំកើតជំងឺហើម និងមិនមានថ្នាំព្យាបាលឡើយ។

សព្វថ្ងៃខ្ញុំមានជំងឺទឹកដក់ក្នុងខួរក្បាល ភ្លេចភ្លាំង វង្វេងវង្វាន់ និងជំងឺជាច្រើនទៀត ដូចជា ខ្វាញ់រុំបេះដូង បេះដូងរីក ខូចក្រលៀន រលាកក្រពះ រលាកតម្រងនោម រលាកសួត។

### ៣) ហេង ខុន៖ អ្នកធ្វើជន្រុកដាក់ស្រូវ

ខ្ញុំសប្បាយចិត្តខ្លាំងណាស់ដែលក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានចុះមកចែករទេះរុញឱ្យខ្ញុំ។ រទេះរុញនេះពិតជាមានសារសំខាន់ខ្លាំងណាស់សម្រាប់ខ្ញុំ ព្រោះអាចជួយខ្ញុំផ្លាស់ទីដោយខ្លួនឯងបាន គឺមិនសូវពិបាកដល់កូនចៅពេលខ្ញុំចង់ទៅណាម្តងៗ។



ខ្ញុំឈ្មោះ ហេង ខុន ភេទប្រុស អាយុ៨៦ឆ្នាំ។ ខ្ញុំកើតនៅភូមិសំរោង១ ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ បច្ចុប្បន្នខ្ញុំរស់នៅភូមិឃុំដដែល។ ខ្ញុំមានឪពុកឈ្មោះ ហេង ចំណែកម្តាយឈ្មោះ ជាង។ ឪពុកម្តាយខ្ញុំបានស្លាប់អស់ហើយ។ ខ្ញុំមានប្រពន្ធឈ្មោះ ជន គឿន អាយុ៨០ឆ្នាំ និងមានកូនចំនួន៦នាក់ ប៉ុន្តែកូនខ្ញុំ២នាក់បានស្លាប់ហើយ។

កាលពីតូច ខ្ញុំមិនបានចូលរៀនទេព្រោះគ្មានអ្នកជួយឪពុកម្តាយធ្វើស្រែចម្ការ។ នៅពេលខ្ញុំអាយុ១៧ឆ្នាំ ឪពុកខ្ញុំបានយកខ្ញុំទៅផ្ញើជាមួយព្រះសង្ឃដែលគង់នៅវត្តស្បូវរីក ដើម្បីឱ្យខ្ញុំរៀនធម៌ និងរៀនអក្សរ។ ខ្ញុំរស់នៅក្នុងវត្តបានមួយឆ្នាំ ក៏សម្រេចចិត្តបួសជាព្រះសង្ឃ។ ខ្ញុំបួសបានមួយវស្សាក៏សឹកវិញ ដោយសារតែឪពុកខ្ញុំស្លាប់ ហើយម្តាយខ្ញុំចាស់គ្មានអ្នកមើលថែ។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សេនាប្រមុខ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ពេលនោះក្នុងភូមិរបស់ខ្ញុំមិនទាន់មានហេតុការណ៍អ្វីកើតឡើងទេ គឺប្រជាជនអាចប្រកបរបរធ្វើស្រែធម្មតា។ ក្រោយមក ខ្មែរក្រហមបានដើរឃោសនាឱ្យប្រជាជនរួបរួមកម្លាំងគ្នាដើម្បីតតាំងជាមួយសេនាប្រមុខ លន់ នល់ ហើយពេលនោះមានប្រជាជនជាច្រើនបានសម្រេចចិត្តចូលរួមជាមួយខ្មែរក្រហម។ មិនយូរប៉ុន្មាន ក៏មានការទម្លាក់គ្រាប់បែកមកលើភូមិចាន់សេរី ដែលជាភូមិមួយនៅជាប់ភូមិរបស់ខ្ញុំ។ ប្រជាជននៅក្នុងភូមិមានភាពតក់

ស្អុត និងមានភាពច្របូកច្របល់យ៉ាងខ្លាំង។ ការទម្លាក់គ្រាប់បែកនៅតែបន្តឥតឈប់ឈរនៅភូមិចាន់សេរី ដោយឃើញសភាពការណ៍មិនស្រួល ខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីភូមិសំរោង១ ឱ្យទៅរស់នៅផ្សារបត់រំដួល។ ខ្ញុំរស់នៅបត់រំដួលបានរយៈពេល៣ខែ ក៏ត្រឡប់មកភូមិសំរោង១វិញ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានរំដោះប្រទេសបានពីសេនាប្រមុខ លន់ នល់។ បន្ទាប់ពីទទួលបានជ័យជម្នះ ខ្មែរក្រហមបានចូលមកដល់ភូមិឃុំដែលខ្ញុំរស់នៅ ហើយបានបង្កើតសហករណ៍ដើម្បីឱ្យប្រជាជនយកសម្ភារដាក់រួម ហូបបាយរួម និងធ្វើការងាររួម។ ខ្មែរក្រហមបានចាត់តាំងខ្ញុំនិងប្រជាជនដែលមានអាយុច្រើនចូលធ្វើការងារនៅក្នុងកងចល័ត។ នៅក្នុងកងចល័តរបស់ខ្ញុំ មានគ្នាប្រហែល៣០នាក់ត្រូវធ្វើការងារលើកភ្លឺស្រែ រែកដី លើកទំនប់ និងជីកប្រឡាយពីដំណាក់អំពិល រហូតទៅដល់ស្រុកមោងឫស្សី ខេត្តបាត់ដំបង។ ក្នុងមួយថ្ងៃៗ ខ្ញុំធ្វើការមិនសូវបានសម្រាកឡើយ ព្រោះខ្មែរក្រហមបានដាក់ផែនការក្នុងម្នាក់ត្រូវជីកដីឱ្យបាន៣ម៉ែត្រគុប។ ប្រជាជនដែលធ្វើមិនគ្រប់ផែនការ គឺអង្គការដាក់ការងារឱ្យធ្វើបន្ថែមទៀត ប៉ុន្តែបើនៅតែធ្វើមិនហើយ គឺយកទៅសម្លាប់មិនខាន។ ខ្ញុំនៅជីកប្រឡាយបានរយៈពេល១ឆ្នាំ ក៏ខ្មែរក្រហមផ្លាស់ឱ្យមកធ្វើជង្រុកស្រូវវិញ។ ពេលនោះខ្មែរក្រហមបានកំណត់ក្នុងមួយភូមិត្រូវធ្វើជង្រុកស្រូវឱ្យបានមួយសម្រាប់ដាក់ស្រូវ។ ចំណែករបបអាហារ ខ្ញុំមិនដែលទទួលបានគ្រប់គ្រាន់ឡើយ។

ចន្លោះពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៧ ខ្មែរក្រហមផ្លាស់ក្រុមខ្ញុំចេញពីកងធ្វើជង្រុកស្រូវឱ្យទៅជីកប្រឡាយនៅស្រុកគាស់ក្រឡវិញ។ ពេលទៅដល់ទីនោះ ខ្មែរក្រហមបានឱ្យក្រុមខ្ញុំចូលធ្វើការងារនៅក្នុងកងចល័តជាប្រជាជនក្នុងភូមិ។ នៅចុងឆ្នាំ១៩៧៧ ខ្មែរក្រហមបានបង្ខំខ្ញុំឱ្យរៀបការ។ ពេលនោះខ្ញុំមិនទាន់ចង់មានគ្រួសារទេ ប៉ុន្តែប្រសិនបើខ្ញុំបដិសេធ ខ្មែរក្រហមនឹងចាប់ខ្ញុំចងរួចបង្អត់អាហារ។ នៅថ្ងៃរៀបការខ្ញុំ គឺមានទាំងអស់១២គូ។ បន្ទាប់ពីរៀបការរួច ខ្មែរក្រហមបានចាត់តាំងខ្ញុំឱ្យទៅធ្វើការងារផ្សេង រីឯប្រពន្ធខ្ញុំទៅធ្វើការងារផ្សេងៗ លុះដល់ពេលយប់ ទើបយើងអាចមករស់នៅជុំជាមួយគ្នាបាន។

នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពវៀតណាមនិងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានចូលមករំដោះប្រជាជនកម្ពុជា។ ពេលនោះខ្ញុំរត់ចេញពីភូមិគាស់ក្រឡ ខេត្តបាត់ដំបង មកស្នាក់នៅភូមិផ្ទះរុង ស្រុកបាកាន ខេត្តពោធិ៍សាត់វិញ។ ខ្ញុំស្នាក់នៅផ្ទះរុងបានរយៈពេល៣ថ្ងៃ ក៏មកនៅស្វាយរីក និងបានជួបកងទ័ពវៀតណាមនៅទីនោះ។ កងទ័ពវៀតណាមបានផ្តល់អាហារឱ្យខ្ញុំហូប និងបានផ្តល់ស្រូវចំនួន៣ការ៉ាវ ឱ្យខ្ញុំយកមកភូមិសំរោង១វិញ។ ខ្ញុំស្នាក់នៅផ្ទះបានមួយថ្ងៃ បងប្អូននិងប្រពន្ធខ្ញុំបានមកជុំគ្នាវិញ ហើយយើងនាំគ្នាភ្ជួររាស់ដីធ្វើស្រែដើម្បីចិញ្ចឹមជីវិតរហូតដល់សព្វថ្ងៃ។



### ៤) ពិល គឿះ កងកុមារ

ខ្ញុំពិតជាមានអារម្មណ៍រីករាយខ្លាំងណាស់នៅពេលដែលក្រុមការងារបានផ្តល់រទេះរុញដល់រូបខ្ញុំសម្រាប់ជិះផ្លាស់ទីជិតឆ្ងាយ និងមិនពិបាកមានអ្នកចាំជួយគ្រាដូចពេលមុនឡើយ។

ខ្ញុំឈ្មោះ ពិល គឿ អាយុ៦៣ឆ្នាំ គឺជាជនពិការដើរមិនរួចជាច្រើនឆ្នាំមកហើយ។ ខ្ញុំមានស្រុកកំណើតនៅក្នុងភូមិសំរោង ឃុំផ្ទះរុង ស្រុកបាកាន ខេត្តពោធិ៍សាត់។ សព្វថ្ងៃ ខ្ញុំរស់នៅក្នុងភូមិសំរោង២ ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ ខ្ញុំមានឪពុកឈ្មោះ គិត និងម្តាយឈ្មោះ យ៉ា។ ឪពុកខ្ញុំបានស្លាប់ក្នុងរបប ប៉ុល ពត ដោយសារមិនមានបាយហូបគ្រប់គ្រាន់ និងឈឺ។ ខ្ញុំមានបងប្អូនចំនួន៩នាក់ ហើយបច្ចុប្បន្ន នៅរស់រានមានជីវិតចំនួន៥នាក់។

នៅចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៦ ខ្មែរក្រហមបានបំបែកខ្ញុំពីឪពុកម្ដាយឱ្យទៅនៅកងកុមារ ធ្វើស្រែ និងជីកប្រឡាយ នៅភូមិតាសាសន៍ និងដំណាក់កន្ទ្រេង។ ពេលនោះឪពុកម្ដាយខ្ញុំ ក៏មិនបានដឹងថាខ្មែរក្រហមបញ្ជូនខ្ញុំទៅ ទីកន្លែងណាទេ។ ពេលនោះខ្មែរក្រហមបានបំផ្លាញវត្តអារាម និងបញ្ជូនព្រះសង្ឃជាច្រើនអង្គមកលើកប្រឡាយនៅដំណាក់ឈើក្រមៗ លុះក្រោយមកទើបខ្មែរក្រហមផ្សឹក និងបញ្ជូនព្រះសង្ឃឱ្យទៅភ្ជួរស្រែ អារឈើ និងលើកទំនប់។

នៅឆ្នាំ១៩៧៧ ការរស់នៅកាន់តែពិបាក គឺប្រជាជនមិនមានអាហារហូបគ្រប់គ្រាន់ឡើយ គឺហូបតែបបរមួយកំប៉ុងគ្នា៣០ទៅ៤០នាក់។ ខ្មែរក្រហមចាត់តាំងខ្ញុំឱ្យធ្វើស្រែ និងជីកប្រឡាយច្រើនជាងមុនទៀត។ ខ្ញុំនិងកុមារនៅក្នុងកងបានលើកទំនប់នៅផ្ទះរ៉ុង បន្ទាប់មកខ្មែរក្រហមបានបញ្ជូនយើងឱ្យទៅជីកប្រឡាយនៅខាង១០បាត និងត្រពាំងជង។ បន្ទាប់ពីខ្ញុំធ្វើការនៅត្រពាំងជងបានរយៈពេល១ខែ ក៏ផ្លាស់ទៅធ្វើការនៅដំណាក់កន្ទ្រេង ត្រពាំងអណ្ដែង និងផ្ទះបីងវិញ។ ខ្ញុំចាំថា នៅថ្ងៃមួយដោយសារខ្ញុំមិនមានអាហារហូបចុកគ្រប់គ្រាន់ ខ្ញុំបានទៅលួចដកដំឡូងមកដុតហូប ហើយត្រូវខ្មែរក្រហមចាប់បានធ្វើទារុណកម្ម។

នៅឆ្នាំ១៩៧៨ ខ្មែរក្រហមបញ្ជូនខ្ញុំទៅបររទេះគោនៅខាងដំណាក់អំពិល ដោយពេលនោះខ្ញុំគឺជាអ្នកដឹកជញ្ជូនកណ្ដាប់ស្រូវ។ រហូតដល់ដើមឆ្នាំ១៩៧៩ កងទ័ពវៀតណាមវាយចូលមក ទើបខ្ញុំ និងប្រជាជនដទៃទៀតរត់គេចខ្លួនទៅរស់នៅតាមព្រៃបានមួយរយៈ ក៏ជួបកងទ័ពវៀតណាម។ បន្ទាប់មកខ្ញុំបានចេញមករស់នៅក្នុងភូមិ ហើយរដ្ឋអំណាចក៏បានបែងចែកដីធ្លីឱ្យខ្ញុំនិងប្រជាជនជាកម្មសិទ្ធិ និងស្រែចម្ការដើម្បីចិញ្ចឹមគ្រួសារ។



លោក ឡុង ដានី នាយកមជ្ឈមណ្ឌលផ្សះផ្សាវាលវែង (រូបខាងស្ដាំ) ជួបជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានពិការភាពនៅឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សវិទ្យាល័យចម្រើនវិជ្ជា សិក្សាអំពី ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងទស្សនាខ្សែភាពយន្តឯកសារ នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង

*ភា រស្មី និង ថុន ស្រីពេជ្រ*



*សិស្សវិទ្យាល័យចម្រើនវិជ្ជា ទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅព្រឹកថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៤ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានទទួលស្វាគមន៍សិស្សានុសិស្សមកពីវិទ្យាល័យចម្រើនវិជ្ជា ថ្នាក់ទី១១ ដែលត្រៀមឡើងថ្នាក់ទី១២ ចំនួន១៣នាក់ ដែលមកទស្សនាពីព័រណ៌រូបថតទាក់ទងនឹងរបបខ្មែរក្រហម ឈ្វេងយល់ពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) និងទស្សនាខ្សែភាពយន្តឯកសាររឿង «កុំស្អានបងភ្លេច» ។

លោក ដេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងបានណែនាំខ្លួន និងប្រាប់សិស្សអំពីការិយាល័យស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ដែលនៅទទួលស្វាគមន៍សិស្សដែលមានបំណងចង់សិក្សាឈ្វេងយល់ និងសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។

នៅក្នុងឱកាសនោះ សិស្សបានលើកជាសំណួរដូចខាងក្រោម ៖

**១) តើនៅខេត្តព្រៃវែង មានវាលពិឃាតដែរឬទេ?**
**២) តើ ឌុច គឺជានរណា?**
**៣) នៅពេលប្រជាជនធ្វើស្រូវបានច្រើន តើស្រូវទាំងអស់នោះខ្មែរក្រហមយកទៅណា?**

៤) ហេតុអ្វីបានជាខ្មែរក្រហមមិនឱ្យប្រជាជនហូបឆ្អែត?

៥) ហេតុអ្វីបានជាតុលាការកាត់ទោស ឌុច ឱ្យជាប់គុកអស់មួយជីវិត។ ហេតុអ្វីបានជាមិនប្រហារជីវិត ឌុច?

៦) តើខ្មែរក្រហម មានទំនាក់ទំនងជាមួយប្រទេសបារាំងដែរឬទេ?

៧) តើ សោ ភឹម ត្រូវបានកាត់ទោសដែរឬទេ?

បន្ទាប់ពីលោក ដេង ពង្សរ៉ាស៊ី ឆ្លើយនូវសំណួររបស់សិស្សានុសិស្សដែលបានលើកឡើងខាងលើរួចហើយ ក៏មានការចាក់បញ្ចាំងខ្សែភាពយន្តឯកសាររឿង «កុំស្មានបងភ្លេច» ឱ្យសិស្សទាំងអស់បានទស្សនា និងឈ្វេងយល់អំពីការបាត់បង់សិល្បៈតន្ត្រី និងសិល្បករនៅក្នុងសម័យសង្គ្រាម ជាពិសេសនៅពេលខ្មែរក្រហមឡើងគ្រប់គ្រងប្រទេសនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ សិស្សានុសិស្សបានទស្សនាខ្សែភាពយន្តឯកសាររឿង«កុំស្មានបងភ្លេច» យ៉ាងស្ងៀមស្ងាត់ និងយកចិត្តទុកដាក់។ បន្ទាប់ពីបានទស្សនាខ្សែភាពយន្តឯកសាររួច សិស្សានុសិស្សបានបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម ៖



១) ខ្ញុំឈ្មោះ **គង់ ស្រីនិច្ច** ភេទស្រី មានអាយុ១៦ឆ្នាំ គឺជាសិស្សថ្នាក់ទី១១ រៀននៅវិទ្យាល័យចម្រើនវិជ្ជា។ សព្វថ្ងៃ ខ្ញុំរស់នៅភូមិបឹងវែង ឃុំដីពុន ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង។ នៅពេលដែលខ្ញុំបានមកដល់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ខ្ញុំគិតថាខ្ញុំមានឱកាសបានដឹងច្រើន ព្រោះនៅទីនេះមានឯកសារច្រើនដើម្បីអាន។ ពីមុនមកខ្ញុំក៏ធ្លាប់បានដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហមខ្លះដែរ ប៉ុន្តែនៅមានភាពស្រពេចស្រពិលនៅឡើយ គឺមិនដឹងថា តើដំណើរដើមទងរបបខ្មែរក្រហមកើតឡើងយ៉ាងដូចម្តេចទេ។ ខ្ញុំនឹងយកចំណេះដឹងដែលទទួលបានពីលោកគ្រូទៅចែករំលែកទៅកាន់មិត្តភក្តិរបស់ខ្ញុំ។ កាលពីមុន ខ្ញុំមានបំណងចង់ទៅទស្សនានៅគុកទួលស្លែង ដើម្បីឈ្វេងយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហម ប៉ុន្តែឥឡូវនេះខ្ញុំសប្បាយចិត្តនៅពេលដែលដឹងថា នៅក្នុងខេត្តព្រៃវែង ក៏មានឯកសារប្រវត្តិសាស្ត្រខ្មែរក្រហមដែរ។ ម្តាយខ្ញុំក៏បានប្រាប់ដែរថា ប្រជាជនត្រូវបានសម្លាប់អស់ជាច្រើននាក់នៅក្នុងខេត្តព្រៃវែងនេះ និងអ្នកខ្លះត្រូវបានជម្លៀសទៅខេត្តពោធិ៍សាត់ ហើយត្រូវបានសម្លាប់នៅទីនោះ។ ជីតារបស់ខ្ញុំក៏បានស្លាប់នៅក្នុងរបប ប៉ុល ពត ដែរ។



២) ខ្ញុំឈ្មោះ **ទ្រី ស៊ាង ស្រ៊ាង** ភេទប្រុស អាយុ១៦ឆ្នាំ គឺសិស្សថ្នាក់ទី១១នៅវិទ្យាល័យចម្រើនវិជ្ជា។ សព្វថ្ងៃខ្ញុំរស់នៅភូមិស្នេហ៍ ឃុំធាយ ស្រុកបាភ្នំ ខេត្តព្រៃវែង។ ខ្ញុំសប្បាយរីករាយនៅពេលស្គាល់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ ពីមុនមក ខ្ញុំពុំបានដឹងថា នៅខេត្តព្រៃវែងនេះ មានមជ្ឈមណ្ឌលឯកសារខ្មែរក្រហមទេ។ ការមកសិក្សារៀនសូត្រនៅទីនេះ គឺធ្វើឱ្យខ្ញុំកើននូវចំណេះដឹងច្រើនជាងមុន។ ខ្ញុំមានឱកាសសួរសំណួរដែលខ្ញុំធ្លាប់ឆ្ងល់ពីមុន។ ចំពោះការទស្សនាខ្សែភាពយន្តខ្ញុំចាប់អារម្មណ៍ទៅលើបទចម្រៀង ព្រោះខ្ញុំគិតថាបទចម្រៀងនៅសម័យសម្តេចព្រះ នរោត្តម សីហនុ គឺពីរោះ ហើយអ្នកស្តាប់បានលើកតម្កើងចម្រៀងទាំងនោះខ្លាំង។ ចុងក្រោយ ខ្ញុំសូមអរគុណលោកគ្រូ ដែលបានពន្យល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហមឱ្យខ្ញុំបានដឹង ហើយខ្ញុំក៏សូមអរគុណដល់បងៗក្រុមការងារដែលបានទទួលក្រុមខ្ញុំយ៉ាងរាក់ទាក់។



៣) ខ្ញុំឈ្មោះ **ថុន ថុតិមា** ភេទស្រី មានអាយុ១៦ឆ្នាំ គឺជាសិស្សមកពីវិទ្យាល័យចម្រើនវិជ្ជា។ ខ្ញុំរស់នៅភូមិជើងទឹក «ខ» សង្កាត់ជើងទឹក

ក្រុងព្រៃវែង ខេត្តព្រៃវែង។ ពេលខ្ញុំបានមកដល់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង គឺខ្ញុំមានបំណងឈ្វេងយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហមកាន់តែស៊ីជម្រៅជាងមុន ដូចជា៖ តើនៅសម័យនោះប្រជាជនបានជួបនូវផលលំបាកយ៉ាងណាខ្លះ? មេរៀនទាំងមូលដែលលោកគ្រូបានពន្យល់ ខ្ញុំមានការចាប់អារម្មណ៍ជាងគេទៅលើការបង្កើតបក្សលើកដំបូង និងការបោះឆ្នោតលើកដំបូង។ ខ្ញុំចង់ឱ្យលោកគ្រូពន្យល់បន្ថែមទៀតទាក់ទងទៅនឹងច្បាប់គ្រប់គ្រងរបស់ខ្មែរក្រហម។ បន្ទាប់ពីខ្ញុំទស្សនាខ្សែភាពយន្តឯកសាររឿង «កុំស្មានបងភ្លេច» រួច គឺខ្ញុំគិតថាខ្សែភាពយន្តឯកសារនេះ បានលើកតម្កើងសិល្បៈតន្ត្រីដែលជាដួងព្រលឹងរបស់ជាតិ។ ខ្ញុំនឹងយកចំណេះដឹងដែលខ្ញុំទទួលបានទៅចែករំលែកជាមួយមិត្តភក្តិទាំងអស់គ្នាដែលមិនបានមកចូលរួម។



៨) ខ្ញុំឈ្មោះ **អ៊ុងអន រតនៈ** ភេទប្រុស អាយុ១៦ឆ្នាំ គឺជាសិស្សថ្នាក់ទី១១ នៃវិទ្យាល័យចម្រើនវិជ្ជា។ ការធ្វើទស្សនកិច្ចមកកាន់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានធ្វើឱ្យខ្ញុំដឹងបន្ថែមអំពីសិល្បៈឆ្លងពីជំនាន់មួយទៅជំនាន់មួយទៀត បានយល់ដឹងអំពីចម្រៀង ខ្សែភាពយន្ត និងអំពើឃោរឃៅរបបខ្មែរក្រហម។ របបខ្មែរក្រហមបានធ្វើឱ្យប្រទេសជាតិធ្លាក់ទៅក្នុងភាពដុនដាបយ៉ាងខ្លាំង។ នៅអំឡុងពេលទស្សនកិច្ចសិក្សា ខ្ញុំចាប់អារម្មណ៍ខ្លាំងជាងគេ គឺការធ្វើរដ្ឋប្រហាររបស់ លន់ នល់។ ចំណុចមួយទៀតដែលខ្ញុំចង់ដឹងបន្ថែម ទាក់ទងជាមួយរបបខ្មែរក្រហម គឺការរស់នៅរបស់ប្រជាជន និងការរៀបអាពាហ៍ពិពាហ៍។ យើងដឹងហើយថាខ្មែរក្រហមមិនឱ្យយើងមានស្នេហានោះទេ ដូច្នេះហើយ តើយើងអាចបង្កើតគ្រួសារបានយ៉ាងដូចម្តេច។



៩) ខ្ញុំឈ្មោះ **អៀប រស្មី** ភេទប្រុស អាយុ១៧ឆ្នាំ គឺជាសិស្សថ្នាក់ទី១១ នៃវិទ្យាល័យចម្រើនវិជ្ជា។ បន្ទាប់ពីសិក្សាប្រវត្តិ-សាស្ត្រខ្មែរក្រហមនៅក្នុងថ្ងៃនេះ គឺខ្ញុំបានដឹងបន្ថែមទៀតទាក់ទងទៅនឹងការធ្វើទារុណកម្មរបស់ខ្មែរក្រហមទៅលើប្រជាជន។ ខ្ញុំបានដឹងទីតាំងសម្លាប់នៅស្រុកបាភ្នំ នៅវិទ្យាល័យព្រះអង្គឌួង និងនៅសង្កាត់បារាយណ៍។ ជាចុងក្រោយ ប្រសិនបើមានឱកាស ខ្ញុំសូមសំណូមពរឱ្យលោកគ្រូ ដេងពង្សរ៉ាស៊ី ពន្យល់ខ្ញុំបន្ថែមទៀត ទាក់ទងទៅនឹងគោលការណ៍៨ចំណុចរបស់ខ្មែរក្រហម ព្រោះខ្ញុំមិនទាន់បានសិក្សាលម្អិតនៅឡើយ។





សិស្សវិទ្យាល័យចម្រើនវិជ្ជាទស្សនកិច្ចសិក្សា មជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប្រវត្តិតំបន់ «ទន្លេចាម»

ឈុំ រ៉ា




បង្គោលព្រំដែនខ្មែរ នៅទន្លេចាម ក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បើយើងធ្វើដំណើរពីផ្លូវជាតិលេខ៧ ប្រមាណ ១៨គីឡូម៉ែត្រនឹងទៅដល់ទន្លេចាម។ ទន្លេចាម មានព្រំប្រទល់ជាប់ប្រទេសកម្ពុជា និងវៀតណាម។ ផ្នែកខ្លះនៃទន្លេចាមជាទឹកដីកម្ពុជា និងផ្នែកខ្លះជាទឹកដីវៀតណាម ផ្អែកទៅលើខណ្ឌសីមា។ ទន្លេចាម ជាប់ឃុំចំនួនពីរ គឺឃុំទន្លូង និងឃុំជាំក្រវៀន ស្រុកមេមត់ ក្នុងនោះមានភូមិចំនួន៦ គឺភូមិកោះថ្ម ភូមិចង្កឺក្រោម និងភូមិចង្កឺកណ្តាល (ឃុំទន្លូង) ចំណែកឃុំជាំក្រវៀន មានភូមិត្រដោក ភូមិស្រែលើ សែនជ័យ និងភូមិសាទុំ។ ក្បាលទឹកទន្លេចាម ហូរពីស្រុកឡុកនិញ ខេត្តប៊ិញហ្វឿក នៃប្រទេសវៀតណាម។

ចាប់តាំងពីប្រទេសវៀតណាម វាយយកនគរចម្ប៉ា ឈ្មោះទន្លេចាម មានលំនាំមកពីប្រទេសចម្ប៉ា ដែលប្រជាជនចាមរត់ភៀសខ្លួនមកនៅតាមដងទន្លេ បន្ទាប់ពីវៀតណាមចូលទៅគ្រប់គ្រង។ ក្រោយមក ទន្លេចាម ខណ្ឌសីមាម្ខាងម្ខាក់រវាងកម្ពុជា និងវៀតណាម។ ជនជាតិចាមកាលពីជំនាន់ឆ្នាំ៤២, ៤៣ និង៤៤ រហូតដល់៥១ និង៥៤។ ចាមពីនគរចម្ប៉ា មករស់នៅស្រែតាចាម ឬស្រែអំពិល លើទឹកដីខ្មែរ តាមអ្នកស្រុកភូមិហៅថា ស្រែតាចាម។ ស្រែតាចាម គឺប្រជាជនចាមមករស់នៅបន្ទាប់ពីភៀសខ្លួនអំឡុងពេលមានសង្គ្រាមជាមួយវៀតណាម។

កន្លែងចាមរស់នៅមានឈ្មោះស្រែតាចាម ឬស្រែអំបិល តាំងពីចាមភៀសខ្លួនពីសង្គ្រាម។

នៅឆ្នាំ១៩៧០ នៅតំបន់ទន្លេចាមទទួលរងការទម្លាក់គ្រាប់បែកយ៉ាងធ្ងន់ធ្ងររួមទាំងប្រជាជនរស់នៅក្បែរទន្លេចាម ជាពិសេស ឃុំទន្លូង និងឃុំជាំក្រវៀន ស្រុកមេមត់ ជាប់ជាមួយព្រំប្រទល់វៀតណាម។ ទោះបីជាសង្គ្រាមត្រូវបានបញ្ចប់ ប៉ុន្តែរណ្ដៅគ្រាប់មិនទាន់រលុប។

ជនជាតិចាមត្រូវបានផ្លាស់ចេញពីស្រែតាចាម ត្រឡប់ទៅរស់នៅខាងស្រុកក្រូចឆ្មារ និងមួយផ្នែកទៀតនៃប្រទេសកម្ពុជា។ ចាប់ពីពេលនោះតំបន់ទន្លេចាម លែងមានមនុស្សរស់នៅ។

មុនសម័យសង្គ្រាម ឈ្មោះ តាភិ ជាមេឃុំទន្លូង បានចូលទៅធ្វើស្រែបន្ត ក្រោយពីជនជាតិចាមចាកចេញអស់។ អំឡុងឆ្នាំ១៩៧៥-១៩៧៨ តំបន់ទន្លេចាមជាកន្លែងសមរភូមិក្ដៅ មានការវាយប្រហារគ្នារវាងខ្មែរក្រហមនិងវៀតណាម។ ក្រោយមក តាភិឈប់ធ្វើមេឃុំទន្លូង ហើយ តាហង្ស បន្តធ្វើជាមេឃុំទន្លូង រហូតក្រោយឆ្នាំ១៩៧៩។

កាលពី១៥ឆ្នាំមុន ប្រជាជនខ្មែរដែលរស់នៅក្បែរទន្លេចាម អាចទៅនេសាទត្រីដោយសេរី ព្រោះកាលមុនសម្បូរត្រីគ្រប់ប្រភេទ។ រដូវខែវស្សាទឹកចាប់ផ្ដើមហក់ឡើង ប្រជាជននាំគ្នាទៅនេសាទតាមបែបប្រពៃណី។ បច្ចុប្បន្ន នៅតំបន់ទន្លេចាម មានប្រជាជនខ្មែរមករស់នៅតាមផ្ទៃដីតិចតួច ព្រោះនៅជាប់ស្រយ៉ាលពីទីប្រជុំជនណាមួយការនេសាទមានការហាមឃាត់រវាងប្រទេសខ្មែរ និងវៀតណាម។





ទន្លេចាម ក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# គាង សុខន ៖ បងប្រុសខ្ញុំពីរនាក់ ត្រូវខ្មែរក្រហមចាប់យកទៅសម្លាប់

**ហាក់ គីមលីង**

ខ្ញុំឈ្មោះ គាង សុខន ភេទស្រី អាយុ៦៨ឆ្នាំ។ ខ្ញុំកើតនៅភូមិព្រែកដំបូកក្រោម ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ខ្ញុំមានឪពុកឈ្មោះ ទៀង និងម្តាយឈ្មោះ ស៊ិន។ ខ្ញុំមានបងប្អូនបង្កើតចំនួន៧ នាក់ គឺប្រុស៤នាក់ និងស្រី៣នាក់។ ខ្ញុំមានប្តីឈ្មោះ សឹម ម៉ាន់ និងមានកូនចំនួន៦នាក់ ក្នុងនោះស្រី៥នាក់និងប្រុស១នាក់។

កាលពីក្មេងខ្ញុំមិនបានចូលរៀនទេ ខ្ញុំត្រូវនៅជួយធ្វើស្រែចម្ការឪពុកម្តាយ។ ឆ្នាំ១៩៧០ ក្រោយរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ សង្គ្រាមក៏ចាប់ផ្តើមឡើងដោយមានការបាញ់ផ្លោង និងទម្លាក់គ្រាប់បែក។ ពេលនោះឪពុកម្តាយខ្ញុំបាននាំកូនៗចូលពួននៅក្នុងព្រៃរនាម សូម្បីតែភ្លើងបំភ្លឺក៏ឪពុកម្តាយខ្ញុំមិនហ៊ានអុជបំភ្លឺដែរ ព្រោះខ្លាចមានការទម្លាក់គ្រាប់បែក។

ចូលមកដល់ឆ្នាំ១៩៧៥ ខ្ញុំមានអាយុ១៨ឆ្នាំ ខ្មែរក្រហមចូលគ្រប់គ្រងប្រទេសបានទាំងស្រុង។ នៅឆ្នាំ១៩៧៦ អង្គការចាត់តាំងខ្ញុំឱ្យចូលធ្វើការងារនៅតាមកងចល័តដើម្បីលើកទំនប់ ដកស្ទូង និងជីកប្រឡាយ នៅភូមិបុស្សសាញ់ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង និងស្វាយពោធិ៍ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។ ក្នុងកង និងក្រុមនីមួយៗ មានសមាជិកចាប់ពី៤ទៅ៦នាក់។

ពេលខ្ញុំចល័តដល់ភូមិព្រែកដំបូក អង្គការប្រាប់ថាត្រូវជម្លៀសអ្នកភូមិទៅខេត្តបាត់ដំបង។ អ្នកភូមិសរុបប្រហែល២០គ្រួសារ ត្រូវបានជម្លៀសចេញពីភូមិ ប៉ុន្តែម្តាយខ្ញុំប្រកែកគឺមិនព្រមទៅដាដាច់ខាត។



គាង សុខន អាយុ៦៨ឆ្នាំ រស់នៅភូមិព្រែកដំបូកក្រោម ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ម្តាយខ្ញុំនិយាយថា «គាត់សុខចិត្តស្លាប់រស់នៅភូមិកំណើត»។ ដោយសារតែគ្រួសារខ្ញុំ គឺជាប្រជាជនមូលដ្ឋាន ហេតុនេះមិនត្រូវបានជម្លៀសចេញពីភូមិទេ លើកលែងតែខ្ញុំ ដែលធ្វើការងារនៅកងចល័តយុវជន-យុវនារី។ ខ្ញុំកម្របានជួបឪពុកម្តាយណាស់។ នៅការដ្ឋានទំនប់ ខ្ញុំត្រូវក្រោកពីព្រលឹមដើម្បីរែកដី។ ខ្ញុំបានទទួលអាហារហូបចុកគ្រប់គ្រាន់។ ក្នុងសម័យខ្មែរក្រហម ខ្ញុំចងចាំមិនភ្លេចគឺបងប្រុសបង្កើតខ្ញុំចំនួន ២នាក់ ត្រូវខ្មែរក្រហមយកទៅសម្លាប់។ បងប្រុស

ខ្ញុំទាំង២នាក់ គឺជាកងទ័ពខ្មែរក្រហម អង្គការហៅប្រជុំតែតាមការពិត គឺហៅយកទៅសម្លាប់ចោល។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ខ្ញុំធ្វើស្រែនៅលើដីខ្លួនឯងផ្ទាល់។ ខ្ញុំចង់ឱ្យក្មេងជំនាន់ក្រោយដឹងអំពីផលលំបាក នៅពេលដែលប្រទេសមានសង្គ្រាម ពីព្រោះខ្ញុំបានហែលឆ្លងអស់ហើយ ដូចជាការរត់ចូលរណ្ដៅលេណដ្ឋាន បុត្រង់សេ ពួនគេចពីការទម្លាក់គ្រាប់បែក។ ខ្ញុំតែងតែនិយាយប្រាប់កូនចៅថា៖ «នែ៎! បើធ្វើការងារ ឬហូបចុកដូចសព្វថ្ងៃនេះ ប្រាដកជាស្លាប់ដាច់ពោះអស់ហើយ។ ជំនាន់យាយ គឺមានតែបបរាវរាវលំបែកគ្នាហូបនោះទេ។ ក្នុងគ្រួសារណាមួយ មានកូនណាម្នាក់មិនទៅជួយកើបអាចម៍គោ មិនទៅធ្វើអីមួយ គឺអង្គការផ្ដាច់របប។ ម្នាក់ៗតម្រូវឱ្យសមាជិកក្នុងគ្រួសារជួយរំលែកចែកគ្នាម្នាក់បន្តិចៗ បបរតែពាវែកប៉ុណ្ណោះ»។



ទេសភាពភូមិព្រែកដំបូកក្រោមថតពីលើអាកាស។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ជា អ៊ា ៖ អង្គការផ្តាច់របបអាហារ ព្រោះខ្ញុំឈឺមិនបានទៅធ្វើការឱ្យអង្គការ

ឌី ស៊ីថា

ខ្ញុំឈ្មោះ ជា អ៊ា ភេទស្រី អាយុ៨៤ឆ្នាំ។ ខ្ញុំកើតនៅក្នុងភូមិក្តុលត្បូង ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្នខ្ញុំរស់នៅភូមិក្តុលក្រោម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានឪពុកឈ្មោះ ជា និងម្តាយឈ្មោះ ខន គាត់ទាំងពីរនាក់បានបាត់បង់ជីវិតដោយសារអាការខ្យល់គរ។ ខ្ញុំមានបងប្អូនចំនួន៣នាក់ ក្នុងនោះមានប្រុសចំនួន២នាក់។ ពេលធំពេញវ័យ ឪពុកម្តាយខ្ញុំបានរៀបចំឱ្យខ្ញុំមានប្តី និងមានកូនចំនួន៩ នាក់ ក្នុងនោះមានកូនស្រីចំនួន៥នាក់។



ជា អ៊ា អាយុ៨៤ឆ្នាំ រស់នៅភូមិក្តុលត្បូង ឃុំក្តុល ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កាលពីក្មេង ខ្ញុំមិនបានរៀនសូត្រដូចក្មេងឯទៀតទេ ពីព្រោះខ្ញុំជាប់រវល់ជួយធ្វើការងារស្រែចម្ការឪពុកម្តាយ។ ខ្ញុំចាំបានថា ក្នុងភូមិខ្ញុំរស់នៅ គឺមានការទម្លាក់គ្រាប់បែកក្នុងជំនាន់ លន់ នល់។ បន្ទាប់មក ក្នុងភូមិក៏ចាប់ផ្តើមបង្កើតឱ្យមានការធ្វើស្រែប្រវាស់ដៃគ្នា ប៉ុន្តែរបបអាហារគឺហូបនៅតាមផ្ទះរៀងៗខ្លួន។ អ្នកភូមិខ្ញុំត្រូវធ្វើស្រែចម្ការរួមគ្នា ហើយប្រមូលផលមកត្រូវយកមកចែកស្មើៗគ្នា។ រំលងបានប្រហែលជាមួយឆ្នាំក្នុងភូមិចាប់ផ្លាស់ប្តូរបង្កើតឱ្យមានសហករណ៍ ត្រូវមានផ្ទះបាយរួម និងប្រមូលរបស់របរទ្រព្យសម្បត្តិដាក់រួម។ ប្រមូលសម្ភារដាក់រួមរួច អង្គការបានជម្លៀសខ្ញុំចេញពីភូមិឱ្យទៅធ្វើការងារនៅម្ជិច ដូចជា កាស់កូនឈើ និងលើកភ្លឺស្រែ តាមការកំណត់ចាត់តាំងពីអង្គការ។ របបអាហារហូបចុកពិតជាពិបាកណាស់ ព្រោះហូបបានតែបបររាវៗមួយវែកៗ។ នៅតំបន់ម្ជិចខ្ញុំឃើញប្រជាជនស្លាប់ជាច្រើនដោយសារតែការប្រើឱ្យធ្វើការងារធ្ងន់ៗ ឈឺគ្មានថ្នាំព្យាបាល និងគ្មានអាហារហូបចុកគ្រប់គ្រាន់។ ខ្ញុំឃើញរណ្តៅដាក់សាកសពរួមចំនួនពី២០ទៅ៣០រណ្តៅ។ ក្នុងរបបខ្មែរក្រហម ខ្ញុំធ្លាប់កើតមានជំងឺហើមក្បាលជង្គង់ មិនអាចទៅធ្វើការងារជូនអង្គការបាន ហេតុនេះអង្គការបានបង្អត់អាហារខ្ញុំចំនួនមួយថ្ងៃមួយយប់។ ខ្ញុំមិនមានបបរ និងបាយហូប ក៏ហូបកន្ទក់ដែលធ្វើឱ្យមានបញ្ហាឈឺក្រពះ និងពោះវៀន។ ក្រោយមកអង្គការចាប់ជម្លៀសខ្ញុំទៅតាមស្ពាយជ្រះ ថ្មគ្រែ និងចុងក្រោយជិះស្រឡាងចុះស្ទឹងត្រង់ ឆ្ពោះទៅស្រុកចំការលើ ខេត្តកំពង់ចាម។ គោលបំណងរបស់អង្គការ

ចំពោះការជម្លៀសជាច្រើនដំណាក់នេះ គឺបញ្ជូនទៅវាយសម្លាប់ទម្លាក់ក្នុងរណ្ដៅតែមួយ ប៉ុន្តែជាសំណាងខ្ញុំ ស្រាប់តែមានយន្តហោះហោះស្រែកប្រកាសពីលើអាកាសមកកាន់ប្រជាជនថា «អ្នករស់នៅក្នុងភូមិណា សូមឱ្យធ្វើដំណើរត្រឡប់ទៅភូមិនោះវិញ»។ បន្ទាប់ពីទទួលបានការប្រកាស ខ្ញុំបានធ្វើដំណើរត្រឡប់មកផ្ទះវិញ ប៉ុន្តែខ្ញុំធ្វើដំណើរបានពាក់កណ្ដាលផ្លូវខ្មែរក្រហមបានស្កាក់ដំណើរខ្ញុំឱ្យឈប់។ តែខ្ញុំមិនបានឈប់ទេ រួចបន្តធ្វើដំណើរទាំងយប់ថ្ងៃរហូតមកដល់កំពង់ចាម ដើម្បីរង់ចាំឆ្លងមកត្រើយទន្លេបិទ។ ព្រឹកឡើងខ្ញុំបានបន្តដំណើរ ដោយឆ្លងស្រឡាងពីកំពង់ចាម មកកាន់ត្រើយទន្លេបិទ និងបន្តធ្វើដំណើរដោយថ្មើរជើងរហូតបានឡើងឡានដឹះមកដល់ស្រុកពញាក្រែក។ ខ្ញុំធ្វើដំណើរត្រឡប់មកភូមិវិញ គឺគ្មានអ្វីជាប់តាមខ្លួនទេ សូម្បីកាំបិត និងឆ្នាំងបាយ។

លុះត្រឡប់មកដល់ផ្ទះវិញ ខ្ញុំឃើញសភាពផ្ទះរបស់ខ្ញុំមានការបាក់បែក និងមានស្មៅដុះពេញជុំវិញផ្ទះ។ ចំណែកផ្ទះអ្នកភូមិឯទៀត មានការខូចខាតច្រើន។ ខ្ញុំ និងអ្នកភូមិឯទៀត ត្រូវដើរបូតស្រូវដែលអង្គការ ដាំហើយជម្លៀសប្រជាជនចេញ។ បន្ទាប់មកខ្ញុំដើររើសគ្រាប់កាហ្វេ ដើម្បីយកទៅដូរគ្រាប់ស្រូវពូជពីប្រទេសវៀតណាម ដើម្បីបណ្ដុះធ្វើស្រែចម្ការ។

ចូលមកឆ្នាំ២០២៣ វ័យរបស់ខ្ញុំកាន់តែចាស់ជរា មានជំងឺក្នុងខ្លួនច្រើន និង ត្រចៀកស្ដាប់មិនសូវបាន។ បញ្ហាត្រចៀក ធ្វើឱ្យខ្ញុំមានអារម្មណ៍ពិបាកក្នុងខ្លួន មិនដឹងនិយាយថាម៉េច ជាមួយកូនចៅ និងកូនចៅនិយាយមកវិញស្ដាប់មិនបាន។ ពេលខ្ញុំឈឺម្ដងៗស្ដាប់មិនឮអ្វីទាំងអស់ ធ្វើឱ្យខ្ញុំមិនចង់និយាយស្ដីជាមួយអ្នកណា។ តែពេលនេះ ខ្ញុំសូមអរគុណដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម នៃមជ្ឈ-មណ្ឌលឯកសារកម្ពុជា ដែលបានផ្ដល់កាសជំនួយត្រចៀកដល់រូបខ្ញុំ ធ្វើឱ្យខ្ញុំអាចស្ដាប់ឮម្ដងទៀត។



ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មចុះជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឈាន កុច ៖ អតីតទាហានការពារព្រំដែនប្រចាំស្ពាក់ការភូមិដូង និង ភូមិសាទុំ

ឌី ស៊ីថា



ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មថតរូបជុំគ្នាជាមួយ ឈាន កុច រស់នៅក្នុងភូមិក្តុលក្រោម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ឈាន កុច ភេទប្រុស អាយុ៦៥ឆ្នាំ គឺជាជនជាតិភាគតិចស្ទៀង កើតនៅក្នុងភូមិក្តុលក្រោម (ក្តុលត្បូង) ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្នរស់នៅក្នុងភូមិក្តុលក្រោម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានឪពុកឈ្មោះ មន ឈាន ស្លាប់តាំងពីខ្ញុំនៅតូចទើបចេះក្រឡាប់ និង ម្តាយឈ្មោះ ឃួនតួន ស្លាប់ក្នុងឆ្នាំ១៩៨៦ដោយសារកង្វះអាហារ។ ខ្ញុំមានបងប្អូន៤នាក់ ក្នុងនោះមានប្រុស៣នាក់ ខ្ញុំគឺជាកូនពៅនៅក្នុងគ្រួសារ។ ខ្ញុំរៀបការប្រពន្ធឈ្មោះ សោម ចន្ថា និង មានកូនចំនួន៦នាក់គឺកូនប្រុស២នាក់ និងកូនស្រី៤នាក់។

កាលពីក្មេង ខ្ញុំរៀននៅវត្តក្តុល ចេះអាននិងអាចសរសេរបាន។ មិត្តរួមថ្នាក់ខ្ញុំមានក្មេងប្រុសៗច្រើនគួរសមដែរ កាលណោះនៅក្នុងមួយថ្ងៃ ត្រូវរៀនពីរវេន និងរៀនធម៌បន្តិចបន្តួច។ ខ្ញុំរៀនបានរយៈពេល២ឆ្នាំ មានរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ ពេលធ្វើរដ្ឋប្រហារហើយ ខ្ញុំឃើញមានឡានដឹកប្រជាជនទៅមេមត់ និងពញាក្រែក ដើម្បីទៅចូលរួមធ្វើបាតុកម្មនៅបន្ទាយវាំងសែង ហៅតាមភាសាបារាំង។ អំឡុងពេលនោះ ប្រជាជននៅក្នុងភូមិក្តុលក្រោម ត្រូវទៅឈរនៅតាមផ្លូវ ដើម្បីចូលរួមអបអរសាទរ។ នៅពេលមានការទម្លាក់គ្រាប់បែកនៅឆ្នាំ១៩៧០ អ្នកភូមិមានការប្រុងប្រយ័ត្នណាស់ ដោយនៅក្នុងផ្ទះមួយៗតែងមានការជីកលេណដ្ឋាន ឬរណ្តៅត្រង់សេត្រៀមដើម្បីទុកលាក់ខ្លួនពីការទម្លាក់គ្រាប់

បែកៗ រណ្ដៅត្រង់សេបុលេណដ្ឋានមានទំហំធំអាចដាក់គ្រែបានមួយ និងមានជម្រៅលិចក្បាល ហើយមានប្រហោងសម្រាប់ចូលនិងចេញ។ គ្រួសារខ្ញុំពិបាកក្នុងការហូបចុកណាស់ មិនសូវបានហូបចុកគ្រប់គ្រាន់ទេ។ ជាពិសេស បាយភាគច្រើនលាយជាមួយចេកពោត ដំឡូង និងមើមក្ដួចយកមកហូបលាយគ្នា។ គ្រួសារខ្ញុំទាល់តែស្ងាត់ការទម្លាក់គ្រាប់បែកទើបចេញពីរណ្ដៅមកដាំបាយហូប។ លុះទាហានអាមេរិកចេញទៅវិញ ក្រុមខ្មែររំដោះចូលមកនៅក្នុងភូមិ ចាប់ផ្ដើមរៀបចំរចនាសម្ព័ន្ធថ្មីដោយចាប់ផ្ដើមដំបូងឱ្យប្រជាជនធ្វើស្រែចម្ការប្រវាស់ដៃគ្នាបុហៅថាសហករណ៍កម្រិតទាប។ នៅក្នុងភូមិប្រជាជនធ្វើស្រែចម្ការប្រវាស់ដៃគ្នាម្ដងម្នាក់ និងហូបបាយតាមផ្ទះរៀងខ្លួន។

ចូលដល់ឆ្នាំ១៩៧៥ ខ្មែរក្រហមបានវាយឈ្នះទាហាន លន់ នល់។ នៅក្នុងភូមិចាប់ផ្ដើមប្រមូលទ្រព្យសម្បត្តិឯកជនដាក់ជារបស់រួម។ គោ ក្របី ជ្រូក មាន់ ទា ដែលប្រជាជនចិញ្ចឹមនៅតាមផ្ទះគ្មានសិទ្ធិចាប់មកធ្វើម្ហូបហូបទេ។ ប្រជាជនត្រូវរស់នៅជាសមូហភាព។ អង្គការបានរៀបចំបែងចែករចនាសម្ព័ន្ធក្នុងភូមិជាក្រុមៗ មានដូចជា ក្រុមកុមារ, ក្រុមវ័យជំទង់, ក្រុមយុវជន, យុវនារី និង ក្រុមមនុស្សចាស់។ អំឡុងពេលនោះ បងប្រុសរបស់ខ្ញុំឈ្មោះ ឈាន សំអៀន និង ឈាន សំអឿន បានធ្វើជាពេទ្យ។ បងសំអៀនជាពេទ្យតែខ្ញុំមិនដឹងពេទ្យនៅតំបន់ណាទេ។ ចំណែកបងសំអឿន ខ្ញុំដឹងថា គាត់ធ្វើពេទ្យនៅអូររាំងឪ (ពេទ្យព-២)។ ឪពុកម្ដាយខ្ញុំធ្វើស្រែចម្ការតាមការចាត់តាំងរបស់អង្គការ។ ឆ្នាំ១៩៧៦ អង្គការបានចាត់តាំងឱ្យខ្ញុំទៅធ្វើជាយោធា ជាហេតុធ្វើឱ្យខ្ញុំត្រូវឃ្លាតឆ្ងាយពីគ្រួសារ។ កាលនោះ អង្គការបានប្រមូលយុវជនទៅឈរតម្រង់ជួរនៅមុខសាលាឃុំទន្លូង (ចាស់)។ ខ្ញុំបានទៅដល់សាលាស្រុកត្រមូងរួចអង្គការបញ្ជូនឱ្យទៅហ្វឹកហាត់ក្បួនច្បាប់យោធានៅភូមិសាទុំរយៈពេលកន្លះខែ ក្រោមការគ្រប់គ្រងពីប្រធានវីរ ឈ្មោះ សាម៉ុន និង ប្រធានអនុសេនាតូចឈ្មោះ សុគីន។ ខ្ញុំរៀនក្បួនច្បាប់យោធាបានកន្លះខែ អង្គការបញ្ជូនឱ្យទៅប្រចាំការនៅតាមព្រំដែនភូមិដូង និងមានទីស្នាក់ការ នៅភូមិសាទុំ។ ខ្ញុំវាយជាមួយវៀតណាមដំបូងនៅស្ពានដែក (ទន្លេរចាម) មិនបានវាយយកចាញ់ឈ្នះទេ គ្រាន់តែវាយ មិនឱ្យវៀតណាមចូលក្នុងទឹកដីខ្មែរ។ កាលណោះ ខ្ញុំកាន់កាំភ្លើងអាកា (AK) ដោយក្នុងមួយបង់មានចំនួន៣០គ្រាប់។ ការហូបចុកពិបាកណាស់ ព្រោះនៅតាមព្រំដែនមានការវាយគ្នាញឹកញាប់។

ឆ្នាំ១៩៧៧ អង្គការបានចាប់យកប្រធានៗនៅភូមិភាគបូព៌ា ដោយមានការសង្ស័យជា «ពួកក្បាលយួនខ្លួនខ្មែរ» បណ្ដាលឱ្យពួកយោធាយាមនៅតាមព្រំដែន ដូចជាខ្ញុំត្រូវអត់បាយ។ ពេលទាហាននិរតីចូលមកបានប្រមូលក្រុមខ្ញុំឱ្យទៅយាមនៅផ្លូវ១៣ (២ផ្លូ)។ ខ្ញុំប្រចាំការនៅ២ផ្លូរយៈពេល៣ខែ ពេលខ្លះមានបាយហូប ថ្ងៃខ្លះអត់។ យោធាខ្មែរក្រហមខ្លះបានរត់ទៅវៀតណាម ទើបធ្វើឱ្យទាហានមជ្ឈិមមកដកហូតកាំភ្លើងពីខ្ញុំ។ ក្រោយមក ខ្ញុំផ្លាស់ទៅធ្វើស្រែនៅភូមិស្រែត្រែង ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ។ នៅស្រែត្រែងគ្មានអាហារហូបចុកគ្រប់គ្រាន់ទេ គឺហូបតែបបររាវៗលាយមើមក្ដួច។ ខ្ញុំនៅបានកន្លះខែ ត្រឡប់មកខាងភូមិថ្មគ្រែវិញ។ ខ្ញុំសម្រាកនៅថ្មគ្រែបានរយៈពេល២ទៅ៣យប់ បន្តដំណើរឆ្លងស្រឡាងទៅស្រុកស្ទឹងត្រង់ សម្រាកបាន២ទៅ៣យប់ក៏បន្តដំណើរទៅស្រុកចំការលើ។ ខ្ញុំនៅចំការលើបាន៥ថ្ងៃ លំបាកពេកក៏ធ្វើដំណើរទៅមុខទៀតដល់ភូមិព្រៃស្រង៉ែ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ ខ្ញុំបានទៅដល់ទំនប់១មករា ខេត្តកំពង់ធំ និងបានសម្រាកបាន២យប់ ស្រាប់តែមានទាហានវាយមកពីភ្នំពេញ។ សមមិត្តដន់បែកអង្ករក្នុងម្នាក់បាន៨គីឡូ ដើម្បីធ្វើដំណើរតាមគោលដៅរៀងៗខ្លួន។ ខ្ញុំបានធ្វើដំណើរត្រឡប់មកស្រុកចំការលើ ដើម្បីចេញមកទីរួមខេត្តកំពង់ចាម រួចជិះស្រឡាងឆ្លងមកទន្លេបិទនិងបន្តធ្វើដំណើរដោយថ្មើរជើងរហូតមកដល់វត្តក្ដុល (វត្តចាស់)។ ដល់វត្តក្ដុលខ្ញុំបានជួបម្ដាយខ្ញុំនិងបានទៅរើសក្ដួរស្រូវនៅស្រែថ្មី ស្រុកស្អួល ដើម្បីយកមកបុកទុក ដាំបាយហូប។ ខ្ញុំសម្រាកនៅវត្តក្ដុលបានកន្លះខែទើបហ៊ានចូលមកក្នុងភូមិ និងចាប់ផ្ដើមរកកាប់កូនឈើមកសាងសង់ផ្ទះដើម្បីរស់នៅ។ ក្រោយពីសម័យខ្មែរក្រហមបានបញ្ចប់ទៅ ខ្ញុំបាត់បង់សមាជិកគ្រួសារចំនួនបីនាក់ ដែលមិនឃើញត្រឡប់មកផ្ទះវិញរហូតមកដល់បច្ចុប្បន្ន។

# នុត ពិច ៖ ខ្ញុំពិការក៏ត្រូវធ្វើការជូនអង្គការ

ឈុំ រ៉ា



ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មថតរូបជុំគ្នាជាមួយ នុត ពិច រស់នៅក្នុងភូមិក្តុលក្រោម ឃុំទន្ទូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ នុត ពិច ភេទស្រី អាយុ៦១ឆ្នាំ កើតនៅភូមិក្តុលក្រោម ឃុំទន្ទូង ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្នរស់នៅភូមិក្តុលក្រោម ឃុំទន្ទូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានឪពុកឈ្មោះ ឌុល នុត (ស្លាប់) និងម្តាយឈ្មោះ ទូច អួន ស្លាប់នៅពេលធ្វើការងារក្នុងសម័យខ្មែរក្រហម។ ខ្ញុំមានបងប្អូនចំនួន៣នាក់ ក្នុងនោះមានស្រី២នាក់។ កាលខ្ញុំអាយុ៧ឆ្នាំឪពុកម្តាយខ្ញុំបានបញ្ជូនឱ្យចូលរៀនបានត្រឹមថ្នាក់ទី៤នៅសាលាក្តុល។ កាលណោះសាលាក្តុលមានកម្រិតសិក្សាត្រឹមថ្នាក់ទី៤ ចំណែកបន្ទប់រៀនមានតែពីរបន្ទប់តែប៉ុណ្ណោះ។ សិស្សដែលទៅរៀនមានប្រមាណ ៤៥នាក់នៅក្នុងឃុំទន្ទូង។ ខ្ញុំធ្លាប់បានរៀនជាមួយលោកគ្រូ លី ប៉ុក និង ហ៊ួរ ប៊ុតសាន។ ពេលខ្ញុំដើរទៅរៀន គឺពិបាកខ្លាំងណាស់ ព្រោះជើងរបស់ខ្ញុំខ្វិនមិនងាយស្រួលដើរដូចជាសិស្សឯទៀត ទម្រាំដើរដល់សាលាប្រើពេលយូរ។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមគ្រប់គ្រងប្រទេសបានទាំងស្រុង និងជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញឱ្យមករស់នៅតាមតំបន់មូលដ្ឋានដាច់ស្រយាលដើម្បីធ្វើស្រែ លើកទំនប់ ប្រឡាយ តាមអង្គការខ្មែរក្រហមចាត់តាំង។ ដំបូងខ្មែរក្រហមឱ្យធ្វើការងារប្រវាស់ដៃ ប្រមូលផលដាក់រួម ហើយចែកជូនតាមក្រុមគ្រួសារមានសមាជិកតិចឬច្រើនបានស្រូវ ឬអង្ករ តាមចំនួនគ្រួសារ។ ការចិញ្ចឹមជ្រូកចែកសាច់គ្នាតាមឈ្មោះ និងគ្រួសារ។ នៅក្នុងភូមិក្តុល មានប្រជាជន១៧មេសា ឬប្រជាជនថ្មីចំនួន៥គ្រួសារ ដែលខ្មែរក្រហមជម្លៀសពីទីក្រុងភ្នំពេញដើម្បីធ្វើស្រែ។ ក្រោយមកមិនបានប៉ុន្មាន អង្គការដាក់ភូមិក្តុល ចូលជាសហករណ៍រួម។

វត្តចាស់ ក៏ត្រូវវាយកម្ទេចចោលទាំងស្រុង ចំណែកព្រះសង្ឃត្រូវចាប់ផ្សឹកជាប្រជាជនធម្មតា និងធ្វើស្រែចម្ការ។ ទីតាំងវត្តចាស់ ស្ថិតនៅភូមិក្តុលក្រោម ក្លាយទៅជារោងបាយ និងរោងម៉ាស៊ីនបោកស្រូវ។ ខ្ញុំអង្គការចាត់តាំងចូលក្នុងកងកុមារ ត្រូវធ្វើការរែកដី ស្រោចដំណាំ។ ប្រធានកងកុមារគ្រប់គ្រងខ្ញុំឈ្មោះ អូន ជាមនុស្សស្រី អាយុដំណាលខ្ញុំ ឥឡូវនេះ គាត់បានទៅរស់នៅប្រទេសវៀតណាម។ ការហូបចុកនៅក្នុងមួយថ្ងៃទទួលបានពីរពេល គឺពេលព្រឹកបបរ និងពេលល្ងាចហូបបាយ។ ខ្ញុំចាំបានថា មុននឹងចេញទៅធ្វើការ គឺកងកុមារត្រូវរៀនរយៈពេលមួយម៉ោង ក្រោយពីនោះ ត្រូវចាត់តាំងធ្វើជី ប្រមូលលាមកតាមផ្ទះ និងលាមកសត្វយកមកដាក់ក្នុងរណ្តៅជី។ ប្រមាណ ៣ថ្ងៃទៅមួយអាទិត្យ ទើបយកលាយជាមួយដីទៅចាក់នៅវាលស្រែ។

ឆ្នាំ១៩៧៧ ខ្ញុំនៅរៀនជាមួយគ្រូ សាន ស្រាប់តែអង្គការជម្លៀសខ្ញុំចេញពីភូមិ ព្រោះខ្លាចវៀតណាមចូលមកបាញ់សម្លាប់។ ដំណាក់កាលទី១ អង្គការជម្លៀសខ្ញុំមកដល់ភូមិកូនក្រពើ ឃុំដាំតាម៉ៅ រួចសម្រាករយៈពេលបីយប់ដើម្បីរង់ចាំប្រជាជនដែលអង្គការកំពុងជម្លៀសមកតាមក្រោយបន្ថែមទៀត។ ខ្មែរក្រហមជម្លៀសប្រជាជនស្ទើរគ្រប់ភូមិ ឃុំ យកមកជួបជុំគ្នានៅភូមិកូនក្រពើ។ រយៈពេល៣ថ្ងៃក្រោយ នៅពេលព្រឹក មានបុរសពីរនាក់កាន់កាំភ្លើងដើរនាំប្រជាជនពីមុខម្នាក់ និងពីក្រោយប្រជាជនម្នាក់ ដើម្បីនាំផ្លូវទៅកាន់កន្លែងថ្មី។ ខ្ញុំចាប់ផ្តើមសួរខ្លួនឯងថា តើខ្ញុំត្រូវស្លាប់ឬអាចនៅបន្តជីវិតរស់ទៅមុខទៀត? កម្លាំងកាយខ្ញុំស្ទើរតែគ្មាន ដង្ហើមដកមិនដល់គ្នា ដើរមិនទាន់គេ។ អំឡុងពេលជម្លៀសពីកន្លែងមួយទៅកន្លែងមួយ គឺពិបាកសម្រាប់ខ្ញុំ ព្រោះជើងខាងស្តាំស្វិតតាំងពីកំណើត ពិបាកដើរមិនដូចអ្នកភូមិដែលមិនពិការ។ ដើរហូតដល់ភូមិស្រែរនាម គឺអត់មានបាយហូបគ្រប់គ្រាន់ជាហេតុធ្វើឱ្យខ្ញុំត្រូវចេញទៅរកត្រីបន្លែឆ្ងាយពីសហករណ៍ ដែលអង្គការហាមមិនឱ្យចេញឆ្ងាយពីសហករណ៍។ អង្គការខ្មែរក្រហមបានស្តីបន្ទោសខ្ញុំថា ជាមនុស្សមិនស្តាប់តាមការណែនាំអង្គការ អង្គការមិនឱ្យមនុស្សស្លាប់ទេ អ្វីដែលសំខាន់ប្រឹងប្រែងធ្វើការងារឱ្យបានល្អ។ ក្រោយមកទៀត ខ្ញុំមិនចាំឆ្នាំណានោះទេ គ្រាន់ដឹងថា មានការទម្លាក់គ្រាប់បែកនៅភូមិស្រែរនាម បណ្តាលឱ្យមានមនុស្សស្លាប់និងរបួសជាច្រើន។ មិនយូរប៉ុន្មានមានការបាញ់តទល់គ្នារវាងកងកម្លាំងខ្មែរក្រហម និងកងកម្លាំងវៀតណាម។ ខ្ញុំរត់ទៅនៅខាងស្រែព្រីង ស្ថិតនៅស្រុកស្នួល ដែលជាតំបន់មានព្រៃក្រាស់ សម្បូរដើមឈើខ្ពស់ និងត្បែងធំៗ។ ស្រែព្រីង មិនមែនជាភូមិដែលមានប្រជាជនរស់នៅនោះទេ តែអង្គការខ្មែរក្រហម បានចាត់តាំងប្រជាជនឱ្យចូលមកកាប់ឆ្ការរានព្រៃយកដីធ្វើស្រែ។

អំឡុងខែវស្សាភ្លៀងធ្លាក់ជោគជាំ ទឹកសាយពេញព្រៃ កន្លែងណាក៏ទឹក អារម្មណ៍ខ្ញុំចាប់ផ្តើមភ័យខ្លាចពួកខ្មែរក្រហមយកទៅសម្លាប់។ ខ្ញុំគិតក្នុងចិត្តថា ប្រសិនបើខ្ញុំធ្លាក់ក្នុងទឹកច្បាស់ជាមិនរស់ទេ ព្រោះខ្ញុំមិនចេះហែលទឹក ណាមួយទឹកហូរខ្លាំង។ ខ្ញុំនៅលើដើមខ្នុររយៈពេលមួយព្រឹក ទាល់ទឹកស្រកបានខ្ញុំត្រឡប់ទៅរោងបាយស្រែព្រីង។ នៅក្នុងសហករណ៍ស្រែព្រីង ប្រធានភស្តុភារ បានហៅខ្ញុំឱ្យមកធ្វើជាកូនកាំបិតនៅរោងបាយសហករណ៍ ព្រោះគាត់ឃើញខ្ញុំមិនអាចទៅកាប់ឆ្ការព្រៃ និងរែកដីបាន។ ខ្ញុំទទួលបានភាពកក់ក្តៅពីប្រធានភស្តុភារ រាល់ថ្ងៃគ្រាន់តែចេញទៅរកបន្លែ និង ធ្វើត្រី សាច់ ដែលមានក្រុមផ្សេងៗទៀតយកមកទុកនៅកន្លែងភស្តុភារ។ ខ្ញុំនៅស្រែព្រីងមិនបានយូរប៉ុន្មាន ក៏អង្គការជម្លៀសឱ្យទៅខាងភូមិថ្មគ្រែ ឃុំថ្មគ្រែ ស្រុកចិត្របុរី ខេត្តក្រចេះ ដើម្បីបន្តជិះកាណូតតាមទន្លេមេគង្គឆ្ពោះទៅកាន់ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។ ដល់ស្រុកស្ទឹងត្រង់ ឃើញមានឡាននៅចំណតចាំដឹកបន្តទៅ ភូមិជយោ ឃុំជយោ ស្រុកចំការលើ ខេត្តកំពង់ចាម។ ខ្ញុំ និងអ្នកភូមិឯទៀតរស់នៅក្នុងភូមិជយោ បានរយៈពេលមួយខែ ស្រាប់តែមានការប្រកាសប្រាប់ឱ្យប្រជាជនទាំងអស់ត្រឡប់ទៅកាន់ស្រុកកំណើតរៀងៗខ្លួនវិញ។ ខ្ញុំចេញដំណើរទាំងយប់ឡើងទៅទីរួមខេត្តកំពង់ចាម ដើម្បីរកទូកឆ្លងទៅខាងទន្លេបិទ។ ដល់ត្រើយម្ខាងទន្លេបិទ គឺមានឡានទាហានវៀតណាម ចាំដឹកអ្នកភូមិមកដាក់ត្រឹមស្រុកពញាក្រែក ខ្ញុំក៏បន្តដំណើរដោយថ្មើរជើងរហូតមកដល់ភូមិកំណើតវិញ។

# ផាន់ ចាន់ថា ៖ កងចល័តតាមភូមិ

**ហាក់ គីមលីង**



ផាន់ ចាន់ថា អាយុ៦៣ឆ្នាំ សព្វថ្ងៃរស់នៅភូមិព្រែកដំបូកក្រោម ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ផាន់ ចាន់ថា ភេទស្រី អាយុ៦៣ឆ្នាំ សព្វថ្ងៃរស់នៅភូមិព្រែកដំបូកក្រោម ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ខ្ញុំមានឪពុកឈ្មោះ អ៊ុង ផាន់ និងម្តាយឈ្មោះ អឿ យីន។ ខ្ញុំគឺជាកូនទោលក្នុងគ្រួសារ។ ខ្ញុំរៀបការជាមួយប្តីឈ្មោះ ម៉ាង ស៊ាន់ ព្រមទាំងមានកូនចំនួន៦នាក់ ក្នុងនោះស្រី៣នាក់ និងប្រុស៣នាក់។

កាលពីក្មេងខ្ញុំចូលរៀននៅសាលាព្រែកដំបូក។ អំឡុងរដ្ឋប្រហារឆ្នាំ១៩៧០ គ្រួសារខ្ញុំបន្តការរកស៊ីនិងស្នាក់នៅភូមិកំណើតដដែល។ អ្នកភូមិនិងគ្រួសារខ្ញុំបានជីកលេណដ្ឋានដើម្បីការពារខ្លួនពីការបាញ់ផ្លោងនិងទម្លាក់គ្រាប់បែក។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំមានអាយុ១៤ឆ្នាំ ខ្មែរក្រហមបានឡើងកាន់កាប់អំណាចទាំងស្រុង។ ខ្ញុំនិងក្មេងៗឯទៀតនៅក្នុងភូមិខ្មែរក្រហមតម្រូវឱ្យដកស្មៅ និងបាចទឹកបញ្ចូលស្រែ។ បន្ទាប់មក ខ្មែរក្រហមបានឱ្យខ្ញុំទៅកើបអាចម៍គោ ទុកធ្វើជាជីដាក់ស្រែ។ ក្រោយមក អង្គការចាត់តាំងខ្ញុំឱ្យចូលធ្វើការងារក្នុងកងចល័តភូមិ គឺប្រូតស្រូវ ដោយដើរធ្វើការ ពីភូមិមួយទៅភូមិមួយទៀត។ នៅសម័យនេះ អង្គការបែងចែកប្រជាជនឱ្យធ្វើការងារជាក្រុមៗ ប្រចាំថ្ងៃ ដោយក្នុងមួយក្រុមមានសមាជិកចាប់ពី២៥ទៅដល់៣០នាក់។ ខ្ញុំគឺជាប្រជាជនមូលដ្ឋានដូច្នេះមិនត្រូវបានជម្លៀសទៅតំបន់ផ្សេងឡើយ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ខ្ញុំនិងគ្រួសារប្រកបមុខរបរធ្វើស្រែចម្ការ។ រឿងរ៉ាវដែលខ្ញុំចងចាំមិនភ្លេចកាលពីរបបខ្មែរក្រហម គឺការអត់ឃ្លាន។ អង្គការចែករបបអាហារឱ្យខ្ញុំហូបមិនឆ្អែតឡើយ ទោះបីខ្ញុំហូបនៅរោងបាយរួម ក៏មិនគ្រប់ដែរ។ ដូចពាក្យចាស់ចំណាំនិយាយតៗគ្នាថា «ធ្វើខ្លាំង ស៊ីខ្សោយ» គឺជាធ្វើការងារយ៉ាងលំបាកប៉ុន្តែហូបចុកមិនសមនឹងការខិតខំប្រឹងប្រែងធ្វើការងារ។

ខ្ញុំចង់ឱ្យក្មេងៗជំនាន់ក្រោយ ខិតខំរៀនសូត្រធ្វើយ៉ាងណាឱ្យប្រទេសមានសន្តិភាព កុំឱ្យរបប ប៉ុល ពត ត្រឡប់មកវិញម្តងទៀត។ ខ្ញុំតែងតែនិយាយរឿងរ៉ាវក្នុងរបបខ្មែរក្រហមប្រាប់កូនចៅ។ កូនចៅរបស់ខ្ញុំខ្លះជឿ និងខ្លះទៀតក៏មិនជឿ ប៉ុន្តែនៅពេលបើកទូរទស្សន៍មើលឃើញក្រុមសិល្បៈសម្តែងរឿងដោយឆ្លុះបញ្ចាំងពីរបប ប៉ុល ពត ទើបចៅៗខ្ញុំសួរថា តើជំនាន់នោះកើតឡើងបែបហ្នឹងមែនដែរឬទេ? ខ្ញុំក៏ឆ្លើយតបថា ពិតមែន ព្រោះកាលនោះខ្ញុំរត់ចូលពួនក្នុងលេណដ្ឋានដើម្បីគេចពីគ្រាប់បែក និងស្លៀកពាក់តែខោអាវខ្មៅ ដោយពុំមានខោអាវស្លៀកពាក់ដូចសព្វថ្ងៃនេះទេ។

# មាច ប៉ោង ៖ ត្រូវធ្វើការទាំងបង្ខំ និង មើលថែម្ដាយឈឺ

ហាក់ គីមលីង



មាច ប៉ោង មានអាយុ៨៦ឆ្នាំ រស់នៅភូមិព្រែកដំបូកក្រោម ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ មាច ប៉ោង ភេទស្រី មានអាយុ៨៦ឆ្នាំ រស់នៅភូមិព្រែកដំបូកក្រោម ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ខ្ញុំមានឪពុកឈ្មោះ មាច និង ម្ដាយឈ្មោះ នាង គាត់ទាំងពីរនាក់ស្លាប់ហើយ។ បច្ចុប្បន្នខ្ញុំរស់នៅជាមួយក្មួយ ខ្ញុំពុំមានស្វាមីទេ។ កាលជំនាន់សង្គមចាស់ ខ្ញុំចូលរៀនអក្ខរកម្មបន្តិចបន្តួចក៏ឈប់ព្រោះខ្ញុំរៀនមិនចេះអ្វីសោះ។ កំឡុងកើតមានរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ ពីប្រមុខរដ្ឋខ្ញុំរស់នៅក្នុងភូមិឃុំធម្មតា ព្រោះមានម្ដាយចាស់ជរានៅជាមួយ។ ដោយសារជីវភាពខ្វះខាត ហើយប្រទេសធ្លាក់ក្នុងសង្គ្រាមបងៗរបស់ខ្ញុំតែងតែចេញទៅរើសក្អួរស្រូវជាប្រចាំ ពីស្រែអ្នកភូមិដែលប្រមូលផលរួច យកមកបុកជាអង្ករដាំបាយហូប។ ជីវភាពខ្វះខាតហើយនៅមានការបាញ់ផ្លោងយន្តហោះទម្លាក់គ្រាប់បែកមកលើភូមិខ្ញុំទៀត។ បងប្អូនខ្ញុំនាំគ្នាជីកលេណដ្ឋានងាយស្រួលគេចខ្លួនពីគ្រាប់បែក។ ឱ្យតែឮសំឡេងយន្តហោះទម្លាក់គ្រាប់ ខ្ញុំរត់ពរក្មួយចូលលេណដ្ឋាន ពេលខ្លះរត់ទាំងខ្លួនទៅពោមពុងមួជទឹក។ យន្តហោះទម្លាក់គ្រាប់បែក ធ្វើឱ្យបងប្អូនជីដូនមួយខ្ញុំម្នាក់បាត់បង់ជីវិត។

ចូលមកដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានឡើងកាន់អំណាចបានទាំងស្រុង ព្រោះទទួលជ័យជម្នះលើរបប លន់ នល់។ ខ្ញុំកាលនោះមានអាយុ៤៥ឆ្នាំ ខ្ញុំនៅធ្វើការជូនអង្គការផ្នែកដាំកប្បាសស្ទូងស្រូវ និង ដកសំណាប។ ស្រាប់តែមានអ្នកភូមិឯទៀតមកនិយាយថា «មុខហ្នឹង! ជីងតែទៅធ្វើការនៅស៊ីធរកណ្ដាលហើយ» ដល់ល្ងាចឡើង ក៏មានអង្គការមកហៅខ្ញុំឱ្យទៅធ្វើការងារជាកងចល័តនៅស្រុកស៊ីធរកណ្ដាលមែន។ ខ្ញុំក៏បានបដិសេធ ព្រោះខ្ញុំត្រូវនៅមើលថែម្ដាយងងឹតភ្នែក។ អង្គការក៏យល់ព្រមឱ្យខ្ញុំនៅមើលថែម្ដាយ ដោយអង្គការចាត់តាំងការងារថ្មី គឺទៅដកសំណាបនៅបារាយណ៍ ហើយពេលល្ងាចចេញមកសម្រាកនៅផ្ទះវិញ។ ការងារដែលអង្គការបានចាត់ឱ្យធ្វើនេះ ក៏មានបែងចែកក្រុមដែរ។ ដោយមួយក្រុមមានសមាជិកប្រហែលជា៥នាក់។ បន្ទាប់មកបានអង្គការឱ្យខ្ញុំមកធ្វើការនៅភូមិចុងបឹងក្រៅវិញ ព្រោះត្រូវនៅមើលម្ដាយដែលងងឹតភ្នែក។

ឆ្នាំ១៩៧៩ របបខ្មែរក្រហមបានដួលរលំ ខ្ញុំនៅតែបន្តរស់នៅភូមិព្រែកដំបូកក្រោមដដែល ព្រមទាំងប្រកបការងារធ្វើស្រែចម្ការ ពេលខ្លះដើរស៊ីឈ្នួល ដាំថ្នាំជក់ រកប្រាក់កម្រៃទិញអង្ករ និងសម្លៀកបំពាក់។

# រស់ យ៉ាន៖ អ្នកភូមិខ្ញុំត្រូវចោទជាជនក្បត់ភូមិភាគបូព៌ា

**មុត សុខបុប្ផា**



រស់ យ៉ាន អាយុ៦៣ឆ្នាំ មានទីកន្លែងកំណើតនៅភូមិចុងបឹងក្រៅ ឃុំផ្ទះកណ្តាល ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ រស់ យ៉ាន ភេទស្រី អាយុ៦៣ឆ្នាំ មានទីកន្លែងកំណើតនៅភូមិចុងបឹងក្រៅ ឃុំផ្ទះកណ្តាល ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ឪពុកខ្ញុំមានឈ្មោះ រស់ កេង និង ម្តាយខ្ញុំឈ្មោះ រស់ គេន។ ខ្ញុំមានបងប្អូនចំនួន៣នាក់ គឺបងប្រុសឈ្មោះ រស់ កន និងប្អូនខ្ញុំឈ្មោះ រស់ យឿន។

កាលពីក្មេងខ្ញុំចូលរៀននៅសាលាវត្តបុទុមសាគរ គ្រូបង្រៀនគឺព្រះចៅអធិការវត្តបុទុមសាគរ។ ខ្ញុំបានរៀនដល់ថ្នាក់ទី៥។ ចូលមកដល់របបលន់នល់ ខ្ញុំអាចនៅរៀនបានតែមួយរយៈពេលខ្លីប៉ុណ្ណោះក៏ឈប់រៀន។ នៅឆ្នាំ១៩៧០ គ្រួសារខ្ញុំនៅអាចធ្វើកសិកម្មធម្មតា។ ឆ្នាំ១៩៧២ ដល់ឆ្នាំ១៩៧៣ មានការបាញ់ផ្លោងទម្លាក់គ្រាប់បែកនៅភូមិខ្ញុំ ត្រូវផ្ទះអ្នកជិតខាងខ្ញុំរំលងពីផ្ទះរបស់ខ្ញុំតែ៣ផ្ទះតែប៉ុណ្ណោះ។ យន្តហោះទម្លាក់គ្រាប់បែកបណ្តាលឱ្យមានការឆេះផ្ទះខ្ទេចខ្ទីអស់។ នៅពេលមានការទម្លាក់គ្រាប់បែកម្តងៗ ឪពុកខ្ញុំបាននាំម្តាយបងប្អូនខ្ញុំចូលលេណដ្ឋានដែលបានជីករួចជាស្រេចនៅក្រោមផ្ទះដើម្បីការពារខ្លួន។

ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានបង្ខំឱ្យខ្ញុំ និងក្មេងៗដទៃទៀតឱ្យឈប់រៀន ហើយក៏ត្រូវចូលមកធ្វើការក្នុងកងកុមារ។ បន្ទាប់មកអង្គការបាត់តាំងឱ្យចូលកងចល័ត។ អង្គការបានជម្លៀសគ្រួសារខ្ញុំនិងអ្នកភូមិទាំងអស់ទៅកាន់ភូមិពាមជីកង ដោយប្រាប់អ្នកភូមិពាមជីកងថា ប្រជាជនទាំងនេះជាជនក្បត់ភូមិភាគបូព៌ា។ អ្នកភូមិមិនហ៊ាននិយាយរកយើងទេ។ នៅពាមជីកងបានមួយរយៈក៏ត្រូវជម្លៀសទៅស្រុកបាធាយ។ ស្នាក់នៅស្រុកបាធាយបានរយៈពេល២ថ្ងៃ ក៏មានដំណឹងថាអង្គការប្រុងនឹងយកប្រជាជនទាំងអស់ទៅសម្លាប់នៅលើភ្នំធំប៉ុន្តែជាសំណាងកងទ័ពវៀតណាមចូលមករំដោះប្រទេស គ្រួសារខ្ញុំនិងអ្នកភូមិឯទៀតក៏រស់រានមានជីវិតមកដល់សព្វថ្ងៃ។

បងប្រុសខ្ញុំឈ្មោះ រស់ កន បួសរៀនជាសាមណេរនៅវត្តបុទុមសាគរ ត្រូវខ្មែរក្រហមចាប់ផ្សឹកគាត់ដើម្បីឱ្យចូលធ្វើជាទាហាន។ នៅឆ្នាំ១៩៧៧ខ្ញុំក៏ទទួលដំណឹងថាបងប្រុសរបស់ខ្ញុំត្រូវខ្មែរក្រហមសម្លាប់ចោល ខ្ញុំមានការសោកស្តាយបងប្រុសរបស់ខ្ញុំយ៉ាងខ្លាំង។

# រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចេញពីស្រុកអន្លង់វែង

អន្លង់វែង គឺជាតំបន់តស៊ូចុងក្រោយរបស់កងកម្លាំងខ្មែរក្រហមដែលបានផ្តាច់ខ្លួនចុះចូលជាមួយរដ្ឋាភិបាលនៅចុងឆ្នាំ១៩៩៨។ ប្រជាជនរស់នៅសហគមន៍អន្លង់វែងគឺចម្រុះគ្នា រួមមានអតីតកម្មាភិបាល និងកងទ័ពខ្មែរក្រហម ប្រជាជនមកពីតំបន់ផ្សេងៗនៅទូទាំងប្រទេសកម្ពុជាដែលគេចខ្លួនពីសង្គ្រាម, ការវាយប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហម និងកងទ័ពរដ្ឋាភិបាល និងប្រជាជនចំណាកស្រុក។ ប្រជាជនទាំងនោះបានឆ្លងកាត់បទពិសោធន៍ និងរឿងរ៉ាវផ្ទាល់ខ្លួនជាច្រើន៖

## ឃិម វ៉ាំង ៖ កងចល័ត

*អត្ថបទ៖ ដោយ កុម្ភៈ អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តឧត្តរមានជ័យ*



ខ្ញុំឈ្មោះ ឃិម វ៉ាំង អាយុ៦៥ឆ្នាំ កើតនៅភូមិត្រពាំងវែង ឃុំកូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ សព្វថ្ងៃខ្ញុំរស់នៅភូមិថ្មល់បត់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ ខ្ញុំមានឪពុកឈ្មោះ ឃិម អោន និង ម្តាយឈ្មោះ ធិម វិញ ប្រកបរបរធ្វើស្រែចម្ការ។ ខ្ញុំមានបងប្អូនបង្កើតចំនួន៦នាក់។ បងរបស់ខ្ញុំ៤នាក់បានស្លាប់នៅក្នុងរបបខ្មែរក្រហម។ ខ្ញុំបានរៀនសូត្របន្តិចបន្តួច និងអាចអាន ហើយសរសេរអក្សរបានខ្លះ។

នៅដើមឆ្នាំ១៩៧៥ ខ្ញុំរស់នៅជាមួយឪពុកម្តាយ បន្ទាប់ពីខ្មែរក្រហមបានចាត់តាំងខ្ញុំឱ្យធ្វើការនៅកងចល័តភូមិត្រពាំងវែង។ នៅឆ្នាំ១៩៧៦ ខ្ញុំបែកពីឪពុកម្តាយទៅធ្វើការឆ្ងាយៗពីផ្ទះ។ ការងាររបស់ខ្ញុំ គឺវែកដីលើកទំនប់ និងធ្វើស្រែចម្ការ។ ពេលនោះឪពុករបស់ខ្ញុំនៅកងឃ្វាលគោ ហើយម្តាយរបស់ខ្ញុំនៅកងតម្បាញ។ រីឯបងៗរបស់ខ្ញុំ ធ្វើការនៅកងចល័តនៅការដ្ឋានផ្សេងទៅតាមការចាត់តាំងរបស់អង្គការ។ នៅសម័យនោះ ខ្ញុំមិនដែលបានហូបឆ្អែតទេ ព្រោះរបបអាហាររ៉ាលីចែកគ្នា ដោយក្នុងមនុស្សម្នាក់ទទួលបានមួយកូនចានតូចៗ។ ពេលឈឺម្តងៗ ខ្ញុំបានសុំប្រធានក្រុមឈប់សម្រាកបានតែមួយថ្ងៃប៉ុណ្ណោះ។ នៅថ្ងៃបន្ទាប់ ប្រធានក្រុមមកហៅខ្ញុំទៅប្រជុំ ហើយស្តីបន្ទោសខ្ញុំថា គឺជាមនុស្សទម្រន់។ លើសពីនេះទៅទៀតបានចោទខ្ញុំថា ឈឺសតិអារម្មណ៍ និងមិនឱ្យខ្ញុំឈប់សម្រាកបន្តទេ។

រាល់ថ្ងៃ ខ្ញុំត្រូវក្រោកពីព្រលឹមទៅធ្វើការរហូតដល់ម៉ោង១១ ទើបបានឈប់សម្រាកហូបបាយ។ បន្ទាប់មក ខ្ញុំត្រូវធ្វើការងារបន្តរហូតដល់ល្ងាចទើបបានហូបបាយម្តងទៀត។ ថ្ងៃមួយ ខ្ញុំឈឺរាំងរ៉ៃរហូតដល់រយៈពេលមួយឆ្នាំ ហើយខ្លួនប្រាណខ្ញុំចាប់ផ្តើមស្គមស្គាំង និងគ្មានកម្លាំងកំហែងឡើយ។ ខ្ញុំបានសុំប្រធានក្រុមមកនៅជាមួយឪពុកម្តាយនៅក្នុងភូមិវិញ ដើម្បីព្យាបាលជំងឺ។ ខ្ញុំបានប្រាប់ប្រធានក្រុមថា នៅ

ពេលជាសះស្បើយ ខ្ញុំនឹងត្រឡប់ទៅធ្វើការវិញ។ មានរឿងរ៉ាវមួយដែលខ្ញុំនិងគ្រួសារខ្ញុំឈឺចាប់ និងចងចាំមិនភ្លេច គឺបងប្រុសរបស់ខ្ញុំ៤នាក់ត្រូវខ្មែរក្រហមយកទៅសម្លាប់ចោល បន្សល់ទុកប្រពន្ធ និងកូនរបស់គាត់ឱ្យនៅកំព្រា។

ក្រោយរបបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩ ខ្ញុំចូលធ្វើការនៅសាលាឃុំកូនគ្រៀលបានមួយរយៈ ក៏រៀបការជាមួយប្តីមុនរបស់ខ្ញុំឈ្មោះ ខេង។ ខ្ញុំកើតបានកូនមួយ ក៏ផ្លាស់ប្តូរទីលំនៅពីភូមិត្រពាំងវែង ទៅរស់នៅក្រុងសំរោងជាមួយប្តី។ ក្រោយមក ប្តីរបស់ខ្ញុំមានប្រពន្ធមួយទៀត ដូច្នេះយើងទាំងពីរនាក់ក៏សម្រេចចិត្តបែកគ្នា។ ខ្ញុំត្រឡប់ទៅស្រុកកំណើតនៅភូមិត្រពាំងវែងវិញ។ មួយរយៈក្រោយមក ម្តាយមីងរបស់ខ្ញុំ បាននាំខ្ញុំមករស់នៅភូមិខ្ញុំដោយប្រកបរបរធ្វើស្រែចម្ការដើម្បីចិញ្ចឹមកូន។ ខ្ញុំរស់នៅភូមិខ្ញុំបានរយៈពេលមួយឆ្នាំ ក៏បានរៀបការម្តងទៀតជាមួយប្តីទីពីរធ្វើជាទាហាន។ ក្រោយមក ខ្ញុំកើតបានកូនចំនួនពីរនាក់ទៀត។ អំឡុងពេលនោះ ខ្ញុំកើតជំងឺរបេងបណ្តាលឱ្យក្អក រហូតនិយាយមិនចេញ។ ខ្ញុំត្រូវសម្រាកព្យាបាលនៅមន្ទីរពេទ្យរយៈពេល២ខែ និងត្រូវលេបថ្នាំរយៈពេល៨ខែទៀតទម្រាំបានជាសះស្បើយ។ ក្រោយមក ខ្ញុំមានផ្ទៃពោះកូនទីបី។ ថ្ងៃមួយពេល យើងកំពុងប្រមូលកណ្តាប់ស្រូវ ប្តីរបស់ខ្ញុំបានលើកចំគំនរកណ្តាប់ដែលទាហានប៉ុល ពតបានដាក់បង្កប់គ្រាប់មីន។ ពេលនោះមីនបានផ្ទុះ ហើយអំបែងគ្រាប់មីនត្រូវចំពោះប្តីរបស់ខ្ញុំបណ្តាលឱ្យហូរឈាមស្រោចពេញខ្លួន។ ភ្លាមៗនោះ ប្តីរបស់ខ្ញុំបានយកដៃខ្ទប់ពោះរបស់គាត់ ហើយរត់ទៅរកអ្នកភូមិឱ្យជួយ។ សំណាងល្អអ្នកភូមិបានជួយសែងប្តីរបស់ខ្ញុំយកមកមន្ទីរពេទ្យដើម្បីព្យាបាលទាន់ពេលវេលា។ ចំណែកខ្ញុំដែលកំពុងពរពោះកូនទីបី បានពរកូនតូចនៅចង្កេះផង និងដឹកដៃកូនច្បងផងរត់តាមពីក្រោយប្តី។ ខ្ញុំលំបាកវេទនាខ្លាំងណាស់។ ពេលនោះពេទ្យស្រុកមិនអាចព្យាបាលរបួសប្តីរបស់ខ្ញុំបានទេ ដូច្នេះក៏បញ្ជូនប្តីរបស់ខ្ញុំបន្តទៅទីរួមខេត្តសៀមរាប។ ដោយសារតែខ្ញុំគ្មានថវិកាសម្រាប់ព្យាបាលរបួសប្តីរបស់ខ្ញុំឱ្យបានជិតដល់ ទើបនៅក្នុងឆ្នាំ២០០១ របួសប្តីរបស់ខ្ញុំបានលាប់ឡើងវិញ ហើយបានស្លាប់ចោលខ្ញុំនិងកូនៗ។ ខ្ញុំរស់នៅជាស្ត្រីមេម៉ាយចិញ្ចឹមកូនៗ។ សព្វថ្ងៃខ្ញុំរស់នៅជាមួយកូនស្រីពៅដែលទើបនឹងរៀបការរួច។

## ម៉ាន់ ហួត ៖ កងចល័ត

អត្ថបទ ៖ ឆោយ កុម្ភៈ អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តឧត្តរមានជ័យ



ខ្ញុំឈ្មោះ ម៉ាន់ ហួត អាយុ៦២ឆ្នាំ កើតនៅភូមិថ្នល់បត់ ឃុំកូនគ្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ បច្ចុប្បន្នខ្ញុំរស់នៅភូមិឃុំដដែល។ ខ្ញុំមានឪពុកឈ្មោះ ម៉ាន់ និងម្តាយឈ្មោះ ឈើយ។ ខ្ញុំមានបងប្អូនចំនួន១០នាក់ ហើយខ្ញុំគឺជាកូនទី៣នៅក្នុងគ្រួសារ។ ឪពុកម្តាយខ្ញុំប្រកបរបរធ្វើស្រែចម្ការ និងមានជីវភាពមិនសូវធូរធារឡើយ។ កាលពីក្មេងខ្ញុំមិនបានចូលរៀនទេ ដោយសារគ្រួសារខ្ញុំមានជីវភាពលំបាក ហើយម្យ៉ាងទៀតខ្ញុំឈឺជាប្រចាំ។ បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ បានមួយរយៈ ខ្មែរក្រហមបានចូលមកគ្រប់គ្រងភូមិរបស់ខ្ញុំ។ ខ្មែរក្រហមបានបំបែកខ្ញុំឱ្យទៅនៅកងចល័ត និងរស់នៅឆ្ងាយពីឪពុកម្តាយ។ នៅទីនោះ ខ្មែរក្រហមបានចាត់តាំងខ្ញុំឱ្យធ្វើការដកស្ទូង ច្រូត និងលើកទំនប់ ដោយមិនមានថ្ងៃឈប់សម្រាកឡើយ។ របបអាហារហូបចុករបស់ខ្ញុំមិនទៀងទាត់ឡើយ ពេលខ្លះខ្ញុំហូបឆ្អែត ពេលខ្លះក៏ខ្វះខាតដែរ។ ក្នុងមួយថ្ងៃ ខ្មែរក្រហមចែករបបឱ្យខ្ញុំហូបតែពីរពេលប៉ុណ្ណោះ គឺពេលថ្ងៃម៉ោង១១ឱ្យហូបបបរ

មួយចាន និងពេលល្ងាចឱ្យហូបបាយមួយចានជាមួយសម្លល្ពៅ។ ខ្ញុំមិនចូលចិត្តល្ពៅទេ ដូច្នេះខ្ញុំទៅសុំអំបិលគ្រួសពីសហករណ៍មកហូបជាមួយបាយ។ ខ្មែរក្រហមបានបែងចែកការងារឱ្យប្រជាជនធ្វើការទៅតាមវ័យ ដោយមនុស្សចាស់ៗត្រូវមើលថែទាំក្មេងតូចៗ ហើយកុមារដែលមានអាយុចាប់ពី៥ឆ្នាំឡើងទៅប្រធានកងប្រើឱ្យដើរកាត់ដើមទន្ទ្រានខែត្រយកមកធ្វើជី។ ចំណែកកងម៉ែៗ ត្រូវចិញ្ចឹមមាន់ ចិញ្ចឹមជ្រូក ដាំបន្លែនិងកិនស្រូវ។

ក្រោយប្រទេសកម្ពុជាត្រូវបានរំដោះនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំរៀបការជាមួយប្តីខ្ញុំឈ្មោះយ៉ាន់ ស្រៀន។ បន្ទាប់ពីរៀបការរួច យើងបានប្រកបរបរធ្វើស្រែចម្ការ។ ទោះបីយ៉ាងណា ពេលនោះសង្គ្រាមមិនទាន់ចប់ឡើយ និងមានការវាយប្រយុទ្ធគ្នាជាញឹកញាប់។ នៅពេលវាយប្រយុទ្ធគ្នាម្តងៗ ខ្ញុំបានរត់ចូលលេណដ្ឋានដើម្បីលាក់ខ្លួន។ ពេលខ្ញុំកើតកូនទី៤ ខ្ញុំបានធ្លាក់ខ្លួនឈឺវង្វេង រហូតលែងស្គាល់បងប្អូនរយៈពេលបីខែ ហើយជំងឺនេះតែងតែកើតឡើងចំពោះខ្ញុំនៅពេលខ្ញុំឈឺម្តងៗ។ នៅឆ្នាំ១៩៩៦ ខ្ញុំបានបង្កើតកូនទី៧ ហើយបន្ទាប់ពីខ្ញុំកើតកូនបានរយៈពេល៥ខែ ប្តីរបស់ខ្ញុំក៏បានស្លាប់ចោលខ្ញុំនិងកូនៗ។

## ស្មិន តិ ៖ កងចល័តលើកទំនប់

អត្ថបទ ៖ ដាប់ ដារ៉ា អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តឧត្តរមានជ័យ



ខ្ញុំឈ្មោះ ស្មិន តិ អាយុ៦៥ឆ្នាំ កើតនៅភូមិខ្ញុំ សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ ខ្ញុំមានបងប្អូនបង្កើតចំនួន៨នាក់។ នៅពេលខ្មែរក្រហមចូលមកគ្រប់គ្រងភូមិរបស់ខ្ញុំ ខ្មែរក្រហមបានចាត់តាំងខ្ញុំទៅលើកទំនប់ជាមួយសមាជិកនៅកងចល័តជាច្រើននាក់។ ក្រៅពីលើកទំនប់ ខ្មែរក្រហមចាត់តាំងឱ្យខ្ញុំលើកភ្លឺស្រែរយៈពេល៦ខែទៀត។ ថ្ងៃមួយ ឈ្លបខ្មែរក្រហម បានចាប់ខ្លួនខ្ញុំយកទៅសួរនាំទាក់ទងនឹងប្រវត្តិឪពុកម្តាយ តើធ្វើជាកងទ័ព ឬមាននិន្នាការនយោបាយណាខ្លះ? ក្រៅពីខ្ញុំ ឈ្លបខ្មែរក្រហមបានចាប់ខ្លួនមនុស្ស៦នាក់ទៀត មកសួរចម្លើយម្តងម្នាក់ដូចខ្ញុំដែរ។ អ្នកទាំង៦នាក់នោះ ត្រូវឈ្លបខ្មែរក្រហមយកទៅអស់ លើកលែងតែខ្ញុំ ឈ្លបដោះលែងឱ្យត្រឡប់មកវិញ។ ប្រធានកងបានបែងចែកសមាជិកឱ្យធ្វើការជាក្រុម និងដាក់ការងារឱ្យធ្វើក្នុងមួយថ្ងៃៗ ប្រសិនបើនរណាធ្វើមិនហើយតាមផែនការ គឺមិនឱ្យឈប់សម្រាកឡើយ។ ពេលនោះ មុនចេញទៅធ្វើការងារ ម្តាយត្រូវយកកូនតូចៗទៅប្រគល់ឱ្យយាយចាស់ៗមើលថែទាំ រហូតដល់ចប់ម៉ោងការងារទើបម្តាយមកយកកូនទៅផ្ទះវិញ។ ការងារមើលក្មេងតូចៗក៏ជួបការលំបាកដែរ ព្រោះប្រសិនបើមើលក្មេងៗទាំងនោះមិនបានល្អ គឺប្រធានសហករណ៍ចាប់យាយៗទាំងនោះទៅអប់រំមិនខាន។

ក្រោយមក ខ្មែរក្រហមបានរៀបការប្រពន្ធឱ្យខ្ញុំ ហើយនៅក្នុងថ្ងៃរៀបការរបស់ខ្ញុំនោះ គឺខ្មែរក្រហមបានរៀបការប្តីប្រពន្ធឱ្យប្រជាជនចំនួន៤៩គូផ្សេងទៀត។ បន្ទាប់ពីរៀបការរួច ខ្មែរក្រហមបានបញ្ជូនខ្ញុំឱ្យទៅរស់នៅផ្ទះខាងប្រពន្ធ។ ខ្ញុំរស់នៅផ្ទះខាងប្រពន្ធបានរយៈពេលពីរខែ ក៏បែកពីប្រពន្ធទៅធ្វើការនៅកន្លែងផ្សេងៗ។ របបអាហារពេលនោះមិនបានគ្រប់គ្រាន់ ពេលខ្លះខ្ញុំបេះត្រួយល្ងៀង មើមរកាយកមកលាយផ្សំគ្នាដើម្បីហូបឱ្យរួចមួយពេលៗ។ នៅពេលពុស្ទរជួងបើករបបអាហារម្តង ប្រសិនបើខ្ញុំទៅមិនទាន់ពេលទេគឺគ្មានអាហារឡើយ។ ក្រោយមក ខ្មែរក្រហមជម្លៀសខ្ញុំពីភូមិតាម៉ា ឃុំបេងឱ្យទៅនៅអន្លង់ថ្មរយៈពេលជិត៣ខែ។ នៅទីនោះខ្មែរក្រហមប្រើខ្ញុំឱ្យធ្វើការជាទម្ងន់។ បន្ទាប់មក ខ្មែរក្រហម

ក៏ផ្លាស់ខ្ញុំឱ្យមកនៅខាងបុស្សវិញ។ ខ្ញុំធ្វើស្រែចម្ការនៅបុស្សបានរយៈពេលមួយឆ្នាំក៏ប្ដូរទៅនៅព្រែកដីកៗ ពេលផ្លាស់ការដ្ឋានម្ដងៗ ខ្ញុំត្រូវធ្វើដំណើរដោយថ្មើរជើង ដោយខ្មែរក្រហមកំណត់ឱ្យដើររយៈពេលមួយថ្ងៃឱ្យដល់គោលដៅ។

នៅពេលកងទ័ពវៀតណាមវាយចូលមក ខ្មែរក្រហមដើរនិយាយឃោសនាប្រាប់ប្រជាជនថា ប្រសិនបើកងទ័ពវៀតណាមចាប់ខ្លួនបាននឹងយកទៅអារកជាមួយធាងត្នោតសម្លាប់ចោល។ ដូច្នេះ មានប្រជាជនជាច្រើនបានរត់គេចខ្លួនទៅតាមខ្មែរក្រហម រួមទាំងខ្ញុំដែរ។ ក្រោយមក ខ្ញុំក៏ត្រឡប់មកភូមិកំណើតនិងប្រកបរបរធ្វើស្រែចម្ការ។

## ប៉ាត់ កឿត ៖ កងចល័ត

អត្ថបទ ៖ យ៉ឹម ស្រីមុំ អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តឧត្តរមានជ័យ



ខ្ញុំឈ្មោះ ប៉ាត់ កឿត មានអាយុ៦២ឆ្នាំ កើតនៅភូមិលាងដៃ ឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប។ ខ្ញុំមានឪពុកឈ្មោះ ណែត ម៉ាត់ និងម្ដាយឈ្មោះ ផ្លូវ ឡាត។ ឪពុកម្ដាយរបស់ខ្ញុំបានស្លាប់ដោយសារជំងឺអស់ហើយ។ ខ្ញុំមានបងប្អូនចំនួន៥នាក់។ ខ្ញុំបានរៀបការនៅអាយុ២១ឆ្នាំ ជាមួយប្ដីឈ្មោះ ង៉ុច និងមានកូនប្រុសស្រីចំនួន៨នាក់។ កូនខ្ញុំនៅរស់៤នាក់ ហើយ៤នាក់ទៀតបានស្លាប់ដោយសារជំងឺ។

ក្រោយរដ្ឋប្រហារទម្លាក់សម្ដេចព្រះនរោត្ដម សីហនុ ឆ្នាំ១៩៧០ កងទ័ព លន់ នល់ និងកងរំដោះខ្មែរក្រហមបានវាយប្រយុទ្ធគ្នាជាញឹកញាប់ ធ្វើឱ្យអ្នកភូមិមានការភ័យខ្លាច និងនាំគ្នារត់ទៅលាក់ខ្លួននៅព្រៃ និងនៅក្បែរៗប្រាសាទព្រះខ័ន។ នៅអំឡុងពេលនោះ ក៏មានការទម្លាក់គ្រាប់បែករយៈពេលមួយឆ្នាំ ទើបស្ងប់ស្ងាត់ទៅវិញ ហើយប្រជាជនក៏នាំបងប្អូនមករស់នៅតាមផ្ទះសម្បែងវិញ។ មួយរយៈក្រោយមក កងកម្លាំងខ្មែរក្រហមបានមកគ្រប់គ្រងភូមិលាងដៃ។ ខ្មែរក្រហមបានបែងចែកប្រជាជនទៅតាមអាយុ ដើម្បីបែងចែកការងារ។ ពេលនោះ ខ្ញុំអាយុប្រមាណ៩ឆ្នាំ ខ្មែរក្រហមបែកចែកខ្ញុំឱ្យនៅកងកុមារ និងជួយដកស្ទូងធ្វើស្រែចម្ការនៅភូមិតាប្រុក រហូតផុតរដូវវស្សាទើបត្រឡប់មកភូមិវិញ។ នៅពេលខ្ញុំអាយុ១១ឆ្នាំ ខ្មែរក្រហមបានចាត់តាំងឱ្យនៅកងចល័តកុមារធ្វើស្រែ និងធ្វើជី។ កុមារទាំងអស់ត្រូវនាំគ្នាដើរកើបលាមកមនុស្ស, កាត់ដើមទន្រ្ទានខែត្រ, ជីកដីដំបូកយកមកលាយគ្នាដើម្បីធ្វើជីដាក់ស្រែ។ នៅពេលខ្ញុំអាយុ១៣ឆ្នាំ ប្រធានកងប្រើខ្ញុំឱ្យទៅលើកភ្លឺស្រែ ដោយកំណត់ក្នុងម្នាក់លើកឱ្យបាន១០ម៉ែត្រ។ ខ្ញុំលើកភ្លឺរយៈពេលមួយខែ ទើបប្រធានកងប្រើខ្ញុំឱ្យដើរដេញសត្វចាបតាមវាលស្រែនៅពេលស្រូវជិតទុំរហូតដល់ប្រមូលផលស្រូវរួច ទើបខ្ញុំអាចវិលត្រឡប់មកភូមិវិញ។ បន្ទាប់



មក ទើបខ្មែរក្រហមប្រើខ្ញុំឱ្យដកស្ទូងនៅស្រះស្រង់។ ក្រោយពីដកស្ទូង ខ្ញុំត្រូវជញ្ជូនកណ្តាប់ឱ្យកងនារីដើម្បីស្ទូង។ ចេញពីស្រះស្រង់ ខ្ញុំត្រូវទៅច្រូតស្រូវជាមួយកងនារីធំៗនៅម្តុំប្រាសាទបាក់ខែង រហូតដល់ចប់ការងារ ទើបប្រធានកងឱ្យខ្ញុំមកធ្វើការងារនៅក្នុងភូមិវិញ។ តមកខ្មែរក្រហមបានចាត់តាំងខ្ញុំឱ្យដេញចាប ច្រូតកាត់ស្រូវ និងដើររើសកួរស្រូវនៅបារាយណ៍។ ចំណែកបងៗដែលគ្មានអ្នកជួយមើលប្អូនតូចៗនៅផ្ទះ ត្រូវវិលត្រឡប់មកភូមិវិញបន្ទាប់ពីចប់ការងារ។ នៅឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានចូលមករំដោះ ទើបខ្ញុំបានជួបជុំបងប្អូន និងម្តាយដែលជាស្ត្រីមេម៉ាយក្រោយខ្មែរក្រហមដួលរលំ។

## ព្រាប សារេទ៖ កងកុមារ

*អត្ថបទ៖ សុខ សីហា អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តឧត្តរមានជ័យ*



ខ្ញុំឈ្មោះ ព្រាប សារេទ អាយុ៥៥ឆ្នាំ កើតនៅភូមិភ្លើងឆេះ ឃុំតាស្នួស ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង។ សព្វថ្ងៃ ខ្ញុំរស់នៅភូមិវត្ត ឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប។ កាលនៅក្នុងរបបខ្មែរក្រហម ខ្ញុំមិនបានរៀនសូត្រច្រើនទេ ព្រោះឪពុកម្តាយខ្ញុំក្រីក្រ និងគ្មានលទ្ធភាពបញ្ជូនកូនៗឱ្យទៅសាលា។ ឪពុកម្តាយខ្ញុំ ប្រកបមុខរបរធ្វើស្រែចម្ការដើម្បីចិញ្ចឹមកូន និងផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ។ ទោះបីយ៉ាងណានៅសម័យនោះ ប្រជាជននៅក្នុងភូមិខ្ញុំចេះយកអាសាគ្នា ជួយទុក្ខធុរៈគ្នា ស្រឡាញ់គ្នាដូចបងប្អូន ហើយតែងតែចែករំលែកគ្នា។ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ខ្ញុំឮឪពុកម្តាយខ្ញុំប្រាប់ថា សេនាប្រមុខ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេច ព្រះនរោត្តម សីហនុ ចេញពីតំណែង។ បន្ទាប់ពី លន់ នល់ ធ្វើរដ្ឋប្រហាររួច ស្ថានការណ៍នៅក្នុងស្រុកភូមិរបស់ខ្ញុំខុសពីមុន និងចាប់ផ្តើមមានភាពចលាចលប្រឆាំងនឹងរបប លន់ នល់ និងការទម្លាក់គ្រាប់បែកធ្វើឱ្យខូចខាតផ្ទះសម្បែង និងសម្ភារទ្រព្យសម្បត្តិប្រជាជនអស់ជាច្រើន។ ក្រោយមក ប្រជាជននៅក្នុងភូមិខ្ញុំក៏ត្រូវបានជម្លៀសចេញពីផ្ទះមួយរយៈដើម្បីគេចចេញពីការទម្លាក់គ្រាប់បែក។ ខណៈពេលនោះគ្រួសារខ្ញុំរួមទាំងអ្នកភូមិជាច្រើនទៀត មិនអាចប្រកបមុខរបរធ្វើស្រែ និងរកស៊ីដូចមុនបានឡើយ។

បន្ទាប់ពីរបបខ្មែរក្រហមឡើងគ្រប់គ្រងប្រទេសកម្ពុជា នៅឆ្នាំ១៩៧៥ ខ្ញុំត្រូវបានបញ្ជូនទៅនៅកងកុមារ និងធ្វើការងារកើបអាចម៍គោ ក្របី កាត់ដើមទន្ទ្រានខែត្រលាយធ្វើជីដាក់ស្រែ និងជីករណ្តៅដី។ ក្រោយពីការងារទាំងអស់នោះ ខ្ញុំត្រូវជួយដាំបន្លែ កាប់ដីធ្វើរងដាំដំណាំជាមួយកងមីងៗ។ ចំណែកអាហារហូបចុក ខ្ញុំហូបមិនដែលគ្រប់គ្រាន់ទេ ដោយក្នុងមួយថ្ងៃខ្ញុំទទួលបានអាហារពីរពេលគឺ ពេលព្រឹក និងពេលល្ងាច។ ខ្ញុំមិនសូវបានបាយហូបទេ គឺហូបតែបបរលាយជាមួយដើមចេក និងត្រកួន។ កំឡុងពេលដែលខ្ញុំចេញទៅធ្វើការ ខ្ញុំបានលួចមើលឃើញខ្មែរក្រហមយកកូនក្មេងទៅសម្លាប់ចោល ដោយទម្លាក់ចូលក្នុងអណ្តូងទឹកជាច្រើននាក់។ ខ្ញុំមិនអាចធ្វើអ្វីបានទេ គឺបានត្រឹមតែយំអាណិតដល់ក្មេងៗ ដែលត្រូវខ្មែរក្រហមសម្លាប់យ៉ាងព្រៃផ្សៃ។ ពេលនោះ ខ្មែរក្រហមបានឃើញខ្ញុំ ក៏បានគំរាមសម្លាប់ខ្ញុំចោលជាមួយក្មេងៗដទៃទៀត។ ខ្ញុំយំដោយសារតែខ្លាចការគំរាមរបស់ខ្មែរក្រហម ហើយឪពុករបស់ខ្ញុំបានប្រាប់ខ្ញុំឱ្យឈប់យំ ដើម្បីកុំឱ្យខ្មែរក្រហមយកទៅវាយធ្វើបាបឬសម្លាប់។ ក្រោយមក ខ្មែរក្រហមយកគ្រួសារជីតារបស់ខ្ញុំទៅសម្លាប់ចោលទាំងអស់ ដោយគ្មានសល់សមាជិកណាម្នាក់ឡើយ។

ខ្មែរក្រហមបានប្រើប្រជាជនឱ្យធ្វើការងារលើស

កម្លាំង និងមិនផ្តល់អាហារឱ្យហូបគ្រប់គ្រាន់ឡើយ។ រហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ទើបប្រទេសកម្ពុជាត្រូវបានរំដោះ ហើយខ្ញុំបានរស់រានមានជីវិតមកដល់សព្វថ្ងៃ។

## មុី រៀង ៖ កងកុមារ

អត្ថបទ៖ សែ សាវីន អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តឧត្តរមានជ័យ



ខ្ញុំឈ្មោះ មុី អៀង អាយុ៥៧ឆ្នាំ កើតនៅភូមិពង្រ សង្កាត់តាផូ ស្រុកស្វាយចេក ខេត្តបាត់ដំបង(បច្ចុប្បន្នខេត្តបន្ទាយមានជ័យ)។ បច្ចុប្បន្នខ្ញុំរស់នៅពេល ឃុំបេង ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។ នៅពេលកងទ័ពខ្មែរក្រហម ឡើងគ្រប់គ្រងអំណាចនៅឆ្នាំ១៩៧៥ ការរស់នៅរបស់ក្រុមគ្រួសារខ្ញុំលំបាកវេទនាខ្លាំងណាស់។ ពេលនោះម្តាយរបស់ខ្ញុំហូបតែបបរជាមួយដើមព្រលិត ហើយគាត់ត្រូវចែករំលែកអាហាររបស់គាត់មួយចំណែកឱ្យខ្ញុំ និងកូនៗដែលនៅតូចៗបានហូបដែរ។

ក្រោយពេលកងទ័ពវៀតណាមចូលមករំដោះនៅឆ្នាំ១៩៧៩ ខ្ញុំនៅជួបការលំបាក ព្រោះខ្ញុំត្រូវបីកូនរត់គេចចេញពីការវាយប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហម និងកងទ័ពវៀតណាម។ ខ្ញុំបានជួបកងទ័ពខ្មែរក្រហម ហើយកងទ័ពខ្មែរក្រហមម្នាក់នោះបម្រុងនឹងបាញ់ខ្ញុំសម្លាប់ចោល ព្រោះសង្ស័យថាខ្ញុំជាគឺខ្សែរយៈស៊ើបការណ៍របស់វៀតណាម។ ខ្ញុំត្រូវបានអ្នកភូមិម្នាក់មកជួយធានា ទើបខ្ញុំបានរួចរស់ជីវិត។

## លូក អុន ៖ កងចល័ត

អត្ថបទ៖ លេន វីរ៉ា អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តឧត្តរមានជ័យ



ខ្ញុំឈ្មោះ លូក អុន អាយុ៧១ឆ្នាំ កើតនៅភូមិឈូក សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិត្រពាំងវែង សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ ខ្ញុំមានម្តាយឈ្មោះ រ៉ាន អូ និងឪពុកឈ្មោះ លូក ឡាំ។ ខ្ញុំមានបងប្អូនបង្កើតចំនួន៥នាក់។

កាលពីកុមារខ្ញុំរៀនដល់ថ្នាក់ទី១០ ពីសង្គមចាស់ ក៏ឈប់រៀននៅឆ្នាំ១៩៦៦ ដោយសារឪពុករបស់ខ្ញុំបានផ្លាស់ប្តូរទីកន្លែងធ្វើការជាញឹកញាប់។ នៅឆ្នាំ១៩៧២ ខ្ញុំបានរៀបការជាមួយប្តីរបស់ខ្ញុំ។ ខ្ញុំរស់នៅជាមួយប្តីនៅក្នុងភូមិរហូតដល់ខ្មែរក្រហមឡើងគ្រប់គ្រងប្រទេស នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទើបខ្មែរក្រហមជម្លៀសខ្ញុំនិងគ្រួសារពីសំរោងទៅនៅភូមិបន្សាយរាក់។ នៅទីនោះ ប្រធានកងប្រើខ្ញុំឱ្យធ្វើស្រែចម្ការ ប៉ុន្តែអាហារហូបចុកគឺខ្មែរក្រហមឱ្យគ្រួសារខ្ញុំដោះស្រាយខ្លួនឯង។ ខ្ញុំរស់នៅភូមិបន្សាយរាក់បានរយៈពេលមួយខែ ខ្មែរក្រហមក៏យកប្តីរបស់ខ្ញុំទៅសម្លាប់ចោល។

បន្ទាប់ពីខ្មែរក្រហមយកប្តីរបស់ខ្ញុំទៅសម្លាប់ចោលបានមួយថ្ងៃ ខ្មែរក្រហមបានបញ្ជូនខ្ញុំជាមួយកូន និងប្អូនស្រីខ្ញុំម្នាក់ទៀតទៅនៅភូមិដង្រឹង។ ខ្មែរក្រហមបើកអង្ករយើងហូបកន្ទះគីឡូក្នុងមួយថ្ងៃ។ កូនរបស់ខ្ញុំពីរនាក់បានស្លាប់ ដោយសារហូបមិនគ្រប់គ្រាន់។ រយៈពេលមួយឆ្នាំក្រោយ ខ្មែរក្រហមបាន

ប្រមូលខ្ញុំ និងប្រជាជន១៧ មេសា ទាំងអស់ចូលក្នុងសហករណ៍។ ចាប់តាំងពីពេលនោះមក យើងត្រូវហូបបាយរួម និងធ្វើការងារលើកទំនប់ ដក ស្ទូង រែកដី ច្រូតកាត់រួមៗ បន្ទាប់ពីហូបបាយល្ងាចរួច ប្រធានកងចាត់តាំងឱ្យយើងធ្វើការងារពេលយប់បន្ថែមៗ នៅពេលនោះ ខ្ញុំបានលាក់ប្រវត្តិថា ខ្ញុំមិនមានឪពុកម្តាយ និងបងប្អូនធ្លាប់ធ្វើការ ឡើយព្រោះខ្លាចខ្មែរក្រហមយកទៅសម្លាប់។ ខ្ញុំធ្លាប់ឃើញខ្មែរក្រហមយកសមាជិកនៅក្នុងសហករណ៍របស់ខ្ញុំទៅសម្លាប់ដោយដំបូងយកប្តីទៅសម្លាប់មុនបន្ទាប់មកទើបយកប្រពន្ធទៅសម្លាប់តាមក្រោយ ដោយចោទប្រកាន់ថា ជាវៀតណាមៗ ខ្ញុំធ្លាប់ឈឺរោគស្ត្រី និងទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យដែរ ដោយគ្រូពេទ្យខ្មែរក្រហមចាក់ថ្នាំ និងឱ្យថ្នាំខ្ញុំលេប។ ខ្ញុំដេកពេទ្យរយៈពេលកន្លះខែ ទើបត្រឡប់មកធ្វើការវិញ។ នៅសម័យនោះ ប្រសិនបើយើងឈឺស្រាល ប្រធានកងឱ្យធ្វើការនៅការដ្ឋានដដែល លុះត្រាតែយើងឈឺធ្ងន់ធ្វើការលែងកើត ទើបបញ្ជូនយើងទៅមន្ទីរពេទ្យ។ ចំណែកទំនាក់ទំនងរវាងស្ត្រីនិងបុរស ខ្មែរក្រហម ហាមមិនឱ្យប្រព្រឹត្តខុសសីលធម៌ឡើយ គឺស្ត្រីនិងបុរសនោះអាចស្នើសុំប្រធានអង្គភាពរបស់ខ្លួនដើម្បីរៀបការ។ ប្រសិនបើប្រធានអង្គភាពយល់ព្រម គឺបន្ទាប់ពីប្រមូលផលស្រូវរួចហើយ ប្រធានអង្គភាពនឹងរៀបការឱ្យតែម្តង ដោយនៅក្នុងពិធីរៀបការម្តងៗគឺមានច្រើនគូ។

មួយរយៈក្រោយមក ប្រធានកងបានបញ្ជូនខ្ញុំទៅធ្វើស្រែនៅកំពង់ក្ដី។ នៅទីនោះខ្វះខាតខ្លាំងណាស់ ពេលខ្លះខ្ញុំហូបបបរ ពេលខ្លះហូបបាយ ហើយពេលខ្លះទៀតមិនមានអាហារហូបតែម្តង។ ខ្ញុំរស់នៅកំពង់ក្ដីរហូតដល់កងទ័ពវៀតណាមចូលមករំដោះនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ ក្រោយមក ខ្ញុំទៅរស់នៅខាងដំដែក បានរយៈពេលកន្លះឆ្នាំទើបបានត្រឡប់មកស្រុកកំណើតវិញ។ ខ្ញុំធ្វើដំណើរដោយថ្មើរជើង ជាមួយបងប្អូនរបស់ខ្ញុំ។ ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ១៩៩៧ ខ្ញុំរស់នៅបុស្សស្បូវ និងអំពិលពង្រ។ បន្ទាប់មកទើប ខ្ញុំផ្លាស់មករស់នៅភូមិត្រពាំងវែង រហូតមកដល់សព្វថ្ងៃ។

## ខួន ឆក ៖ កងចល័ត

អត្ថបទ៖ លេន វីរ៉ា អ្នកស្ម័គ្រចិត្តកម្ពុជា
ខេត្តឧត្តរមានជ័យ



ខ្ញុំឈ្មោះ ខួន ឆក អាយុ៦១ឆ្នាំ កើតនៅភូមិត្រពាំងវែង សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ បច្ចុប្បន្ន ខ្ញុំរស់នៅក្នុងភូមិឃុំដដែល។ ខ្ញុំមានឪពុកឈ្មោះ ធៀម ខួន និងម្តាយឈ្មោះ ហៀម ហ៊ួន និងមានបងប្អូនបង្កើតចំនួន៨នាក់។

ខ្ញុំរៀនថ្នាក់ទី១២ ពីសង្គមចាស់នៅសាលាក្នុងភូមិត្រពាំងវែង បន្ទាប់មកក៏បានឈប់រៀននៅពេលខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ រយៈពេលកន្លះឆ្នាំក្រោយមក ខ្មែរក្រហមប្រមូលទ្រព្យសម្បត្តិ ចានឆ្នាំង អង្ករដាក់ចូលក្នុងសហករណ៍រួមទាំងអស់។ ខ្មែរក្រហមបានសួរប្រវត្តិរូបប្រជាជនក្នុងភូមិ ហើយអ្នកដែលធ្លាប់ធ្វើមន្ត្រីរាជការ និងធ្វើទាហានសម័យ លន់ នល់ គឺឈ្លបយកទៅសម្លាប់ចោល។ ចំណែកប្រពន្ធកូនឈ្លបខ្មែរក្រហមយកទៅតាមក្រោយ។ បងរបស់ខ្ញុំ៤នាក់ដែលធ្លាប់ធ្វើការពីសង្គមចាស់រួមទាំងគ្រួសារ ត្រូវឈ្លបខ្មែរក្រហមចាប់យកទៅសម្លាប់ទាំងអស់។ ចំណែក ខ្ញុំនិងប្រជាជនផ្សេងទៀត ខ្មែរក្រហមបញ្ជូនឱ្យទៅធ្វើការតាមគោលដៅរៀងៗខ្លួន ដូចជា ទៅដាំដំណាំនៅភូមិគោកគរ ក្រុងសំរោង។ នៅកន្លែងនោះ ខ្ញុំបានហូបឆ្អែត ហើយអាចបេះបន្លែផ្លែឈើមកហូបរួមគ្នាបាន។ ខ្ញុំរស់នៅកន្លែងនេះ រហូតដល់កងទ័ពវៀតណាមចូលមករំដោះ នៅឆ្នាំ១៩៧៩។ ក្រោយមក ខ្ញុំបានរត់គេច

ខ្លួនចូលទៅព្រៃជាមួយអ្នកភូមិផ្សេងទៀត ព្រោះខ្មែរក្រហម និងទាហានប៉ារ៉ា ដើរប្រមូលប្រុសៗឱ្យចូលធ្វើទាហាន។ ខ្ញុំនិងគ្រួសារបានរត់ទៅនៅភូមិពុរ និងធ្វើស្រែចម្ការនៅទីនោះបានរយៈពេលប្រាំឆ្នាំ ក៏ត្រឡប់មករស់នៅក្នុងភូមិត្រពាំងវែងវិញ។ ខ្ញុំបានសង់ផ្ទះសម្បែង និងប្រកបមុខរបរធ្វើស្រែចម្ការរហូតមកដល់សព្វថ្ងៃ។

## កែវ នី ៖ អ្នកដឹកជញ្ជូនស្បៀងឱ្យកងទ័ពខ្មែរក្រហម

*អត្ថបទ៖ ផូរ ដានុន អ្នកស្ម័គ្រចិត្តកម្ពុជា*
*ខេត្តឧត្តរមានជ័យ*



ខ្ញុំឈ្មោះកែវ នី អាយុ៦៩ឆ្នាំ កើតនៅឃុំដេកពក ស្រុកកញ្ជៀច ខេត្តព្រៃវែង។ បច្ចុប្បន្ននេះ ខ្ញុំរស់នៅភូមិត្រាំប៉ោង ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ ខ្ញុំមានបងប្អូនបង្កើតចំនួន៦នាក់ ហើយខ្ញុំគឺជាកូនទី៤នៅក្នុងគ្រួសារ។ បច្ចុប្បន្នបងប្អូនខ្ញុំនៅរស់តែ៣នាក់ប៉ុណ្ណោះ ដោយបងប្អូនពីរនាក់ទៀតរស់នៅខេត្តព្រៃវែង។ ខ្ញុំមានកូនចំនួន៨នាក់ បច្ចុប្បន្នរស់នៅខេត្តព្រៃវែង។ កូនៗរបស់ខ្ញុំមានប្តីប្រពន្ធរៀងៗខ្លួនអស់ហើយ។ សព្វថ្ងៃ ខ្ញុំរស់នៅតែពីរនាក់ប្តីប្រពន្ធប៉ុណ្ណោះ។

ខ្ញុំបានរៀនដល់ថ្នាក់ទី៩ នៅក្នុងសម័យសង្គមរាស្ត្រនិយម។ ខ្ញុំឈប់រៀននៅអំឡុងឆ្នាំ១៩៧០ ពេល លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ចេញពីតំណែង។ ពេលនោះ សិស្សបានប្រមូលផ្តុំគ្នាដើម្បីប្រឆាំងតវ៉ានឹងរដ្ឋប្រហារនេះ ឃើញដូច្នេះម្តាយរបស់ខ្ញុំក៏សម្រេចចិត្តឱ្យខ្ញុំឈប់រៀន។ បន្ទាប់មក ខ្ញុំបានជួយឃ្វាលគោក្របីឪពុកម្តាយសរុបចំនួន៦ក្បាល ហើយរាល់ថ្ងៃខ្ញុំចេញទៅឃ្វាលគោក្របីជាមួយកូនអ្នកភូមិ។

បន្ទាប់ពី លន់ នល់ ធ្វើរដ្ឋប្រហារបានមួយរយៈ ភូមិឃុំរបស់ខ្ញុំមានភាពច្របូកច្របល់យ៉ាងខ្លាំង ដោយសារមានការទម្លាក់គ្រាប់ផ្លោងស្ទើររាល់ថ្ងៃ។ ពេលនោះ ម្តាយរបស់ខ្ញុំលែងឱ្យខ្ញុំទៅឃ្វាលគោទៀតហើយ ព្រោះខ្លាចគ្រោះថ្នាក់ គឺឱ្យខ្ញុំសំងំលាក់ខ្លួននៅក្នុងត្រង់សេ (លេណដ្ឋាន)។ នៅពេលខ្មែរក្រហមចូលមកនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមជ្រើសរើសខ្ញុំឱ្យចូលកងទ័ព និងបានបញ្ជូនខ្ញុំទៅព្រំដែនវៀតណាម ប៉ុន្តែខ្ញុំមិនចាំទីតាំងឡើយ។ ចាប់តាំងពីពេលនោះមក ខ្ញុំបាត់ដំណឹងពីគ្រួសារ និងមិនដឹងសាច់ញាតិឪពុកម្តាយមានសុខទុក្ខយ៉ាងណាឡើយ។ ទោះបីខ្ញុំធ្វើកងទ័ពមែន ប៉ុន្តែខ្ញុំមិនបានកាន់កាំភ្លើងប្រយុទ្ធឡើយ ដោយសារតែខ្ញុំមាឌល្អិត ដូច្នេះប្រធានអង្គភាពផ្លាស់ខ្ញុំមកនៅកងដឹកជញ្ជូនស្បៀង និងគ្រាប់រំសេវវិញ។ ក្នុងមួយសប្តាហ៍ខ្ញុំត្រូវដឹកជញ្ជូនស្បៀង និងគ្រាប់រំសេវទៅឱ្យកងទ័ពម្តង។ នៅពេលដឹកជញ្ជូនម្តងៗ ខ្ញុំប្រឈមនឹងគ្រោះថ្នាក់ខ្លាំងណាស់ព្រោះខ្ញុំត្រូវដើរឆ្លងកាត់ផ្លូវដែលពោរពេញទៅដោយគ្រាប់មីន និងគ្រាប់ផ្លោងពីកងទ័ពវៀតណាម។ មធ្យោបាយដឹកជញ្ជូនគឺគ្មានអ្វីក្រៅពីរទេះគោឡើយ។ ខ្ញុំមានមិត្តភក្តិម្នាក់ទៅជាមួយខ្ញុំរាល់ពេលដឹកជញ្ជូនស្បៀងនិងគ្រាប់រំសេវម្តងៗ។ ខ្ញុំភ័យខ្លាចខ្លាំងណាស់ ប៉ុន្តែខ្ញុំមិនដឹងធ្វើដូចម្តេច ព្រោះខ្ញុំស្ថិតនៅក្រោមអង្គការ។ ប្រសិនបើខ្ញុំហ៊ានតវ៉ា ខ្មែរក្រហមនឹងយកខ្ញុំទៅសម្លាប់ចោលជាមិនខាន ថែមទាំងចោទប្រកាន់ខ្ញុំថាគឺជាជនក្បត់ជាតិ។

ក្រៅពីការងារដឹកជញ្ជូនស្បៀងឱ្យកងទ័ពនៅសមរភូមិក្នុងមួយសប្តាហ៍ម្តង ខ្ញុំត្រូវជួយមើលថែអ្នកជំងឺនៅជំរំពេទ្យទាហាន និងដាំបន្លែបង្ការផ្សេងៗ។ នៅពេលនោះ មានអ្នកជំងឺច្រើនដែលរងរបួសដោយសារការវាយប្រយុទ្ធគ្នាជាមួយកងទ័ពវៀតណាម។

អ្នករងរបួសទាំងនោះ ត្រូវបានសែងមកជំរំពេទ្យនៅសមរភូមិក្រោយ ដោយមានពេទ្យឯកទេសចាំព្យាបាល ប៉ុន្តែការព្យាបាលមិនបានដិតដល់ឡើយ ព្រោះពេទ្យគ្មានបច្ចេកទេស និងគ្មានសម្ភារគ្រប់គ្រាន់។ ពេលខ្លះ ពេទ្យដេររបួសឱ្យអ្នកជំងឺដោយមិនប្រើថ្នាំសណ្តំឡើយ។ នៅខាងជំរំពេទ្យទាហាន ការហូបចុកគឺមិនលំបាកទេ គឺមានអង្ករ ម្ហូបអាហារ និងបន្លែបង្ការគ្រប់គ្រាន់។ ខ្ញុំធ្វើការនៅកងដឹកជញ្ជូនរហូតដល់របបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ទើបខ្ញុំត្រឡប់ទៅភូមិកំណើតវិញ។ ពេលទៅដល់ផ្ទះ បងប្អូនរបស់ខ្ញុំភ្ញាក់ផ្អើលយ៉ាងខ្លាំង ព្រោះគិតថាខ្ញុំបានស្លាប់បាត់ទៅហើយ ហើយថែមទាំងបានធ្វើបុណ្យខួបទិសកុសលឱ្យខ្ញុំទៀតផង។

## ព្រួន កើង ៖ កងកុមារ

អត្ថបទ៖ យ៉ម ស្រីមុំ អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តឧត្តរមានជ័យ



ខ្ញុំឈ្មោះ ព្រួន កើង អាយុ៦០ឆ្នាំ កើតនៅភូមិលាងដៃ ឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប។ ខ្ញុំមានឪពុកឈ្មោះ ឌី ព្រួន និងម្តាយឈ្មោះ យាយ យាន ស្លាប់នៅក្នុងរបបខ្មែរក្រហម។ ខ្ញុំមានបងប្អូនចំនួន ៩ នាក់ ក្នុងនោះស្លាប់អស់៣នាក់។

កាលពីខ្ញុំនៅក្មេង ខ្ញុំឃើញកងទ័ពវៀតណាមខាងជើង និងកងទ័ព លន់ នល់ វាយប្រយុទ្ធគ្នានិងមានការទម្លាក់គ្រាប់បែក។ ដោយមានការភ័យខ្លាច ខ្ញុំនិងប្រជាជនក្នុងភូមិនាំគ្នារត់គេចទៅលាក់ខ្លួនតាមប្រាសាទរយៈពេលមួយឆ្នាំទើបនាំគ្នាត្រឡប់មកក្នុងភូមិវិញ។ ក្រោយមកទើបខ្មែរក្រហមបានចូលមកគ្រប់គ្រងនៅក្នុងភូមិរបស់ខ្ញុំ។ នៅពេលខ្ញុំអាយុ១០ឆ្នាំ ខ្មែរក្រហមចាត់តាំងឱ្យខ្ញុំចូលកងកុមារ និងស្ទូងដកនៅភូមិតាប្រុករួចរាល់ ទើបមករស់នៅភូមិលាងដៃវិញ។ ក្រោយមក ប្រធានកងកុមារចាត់តាំងខ្ញុំនិងកុមារទាំងអស់ដើររើសលាមកមនុស្ស កាត់ដើមទន្ទ្រានខេត្រ និងដឹកដីដំបូកមកលាយគ្នាធ្វើជីដាក់ស្រែ។

នៅពេលខ្ញុំអាយុ១៣ឆ្នាំ ខ្មែរក្រហមបានប្រើខ្ញុំឱ្យទៅលើកភ្លឺស្រែ ដោយកំណត់ក្នុងម្នាក់លើកឱ្យបាន១០ម៉ែត្រ។ នៅពេលខ្ញុំអាយុ១៤ឆ្នាំ ខ្មែរក្រហមបានបញ្ចូលខ្ញុំទៅកងចល័ត។ ដំបូង ប្រធានកងប្រើខ្ញុំឱ្យទៅដេញសត្វចាបតាមវាលស្រែពេលស្រូវទុំ រហូតដល់ប្រមូលផលស្រូវរួចទើបខ្ញុំវិលមកភូមិវិញ។ បន្ទាប់មក ប្រធានកងចាត់តាំងខ្ញុំឱ្យដកនិងស្ទូងនៅស្រះស្រង់។ បន្ទាប់មក ខ្ញុំទៅដកស្ទូងនិងជញ្ជូនកណ្តាប់ឱ្យកងនារីស្ទូងនៅតាត្រៃ។ តមកទៀតទើប ខ្ញុំទៅដកស្ទូង និងច្រូតស្រូវជាមួយកងនារីធំៗ នៅបាក់ខែង។ រាល់ថ្ងៃ ខ្ញុំត្រូវគោរព និងធ្វើការតាមផែនការប្រធានកងដាក់ឱ្យ។ មិនយូរប៉ុន្មានប្រធានកងបានបញ្ជូនខ្ញុំទៅដេញចាប ដកស្ទូង ច្រូតកាត់ និងដើររើសកួរស្រូវ នៅបារាយណ៍។

ពេលប្តូរពីការដ្ឋានមួយទៀត ខ្ញុំត្រូវធ្វើដំណើរដោយដើរជើងទទេ ហើយពេលខ្លះត្រូវធ្វើដំណើរទាំងយប់ក៏មាន។ ពេលខ្លះខ្ញុំត្រូវដេកក្រោមដើមឈើ និងតាមវាលស្រែ ហើយកាន់តែពិបាកគឺនៅរដូវវស្សាដែលមានភ្លៀងធ្លាក់នៅពេលយប់។ ខ្ញុំរស់នៅបែកពីគ្រួសារពេលចេញទៅធ្វើការនៅតាមការដ្ឋាន។ រហូតដល់របបខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩ ទើបខ្ញុំត្រឡប់មកជួបជុំបងប្អូន និងគ្រួសារវិញ។

## គៀប អែម ៖ ពេទ្យផ្នែកស្លថ្នាំ

អត្ថបទ៖ សាត់ ស្រីនិត អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តឧត្តរមានជ័យ



ខ្ញុំឈ្មោះ កៀប អែម អាយុ៦៨ឆ្នាំ សព្វថ្ងៃរស់នៅភូមិតាប្រុក ឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប។ ខ្ញុំមានបងប្អូនចំនួន៨នាក់ ហើយខ្ញុំគឺជាកូនទី២។ កាលពីក្មេងខ្ញុំបានរៀនតិចតួច ព្រោះគ្រួសារខ្ញុំក្រីក្រ។

នៅក្នុងសម័យខ្មែរក្រហម ខ្ញុំរែកដី លើកទំនប់ និងធ្វើស្រែ។ ពេលខ្លះប្រធានកងបានចាត់តាំងខ្ញុំឱ្យឡើងភ្នំដើម្បីចៀរជ័រ ដោយចែកអង្ករឱ្យខ្ញុំមួយកំប៉ុងសម្រាប់មនុស្សពីរនាក់។ ខ្ញុំចាំថា ថ្ងៃមួយខ្មែរក្រហមបានបើករថយន្តមកដឹកខ្ញុំនិងកងចល័តផ្សេងទៀតពីស្រែណូយទៅប្រូតស្រូវនៅប៉ុសល្ហុង។ នៅទីនោះគឺជាទីវាល និងគ្មានដើមឈើឡើយ។ ខ្ញុំនិងសមាជិកកងចល័តបានដឹកជញ្ជូនឈើទៅធ្វើជាបង្គោលដើម្បីបង់អង្រឹងដេក។ តំបន់នោះ គឺខ្វះខាតទឹកប្រើប្រាស់ និងក្តៅខ្លាំងណាស់។ ខ្ញុំបានឈឺគ្រុនចាញ់រយៈពេល៣ខែ បណ្តាលឱ្យខ្ញុំស្គមស្គាំង។ ពេលនោះ ខ្ញុំបានយកបាវស្រូវចំនួន៧ មកកាត់ដើម្បីធ្វើខោអាវស្លៀកពាក់ ព្រោះខ្មែរក្រហមមិនបើកខោអាវឱ្យខ្ញុំ។

ក្រោយមក ប្រធានកងបានចាត់តាំងឱ្យខ្ញុំលើកទំនប់អូរបុស្សី អូរអាកុក រលំរុន និងទំនប់ស្រែណូយ។ ខ្ញុំនៅចាំបានថា ពេលទៅលើកទំនប់ស្រែណូយ ប្រធានកងដាក់ពិន័យខ្ញុំ ដោយសារឃើញខ្ញុំឈប់សម្រាក។ កងចល័តធ្វើការនៅការដ្ឋានទំនប់ស្រែណូយរយៈពេលរាប់ឆ្នាំទើបហើយរួចរាល់។ នៅទីនោះយើងអាចរកត្រីមកហូបបាន ដោយមិនចាំបាច់យកទៅដាក់រួមនោះទេ ហើយពេលខ្លះខាងសេដ្ឋកិច្ចបើកត្រីងៀតឱ្យម្តងម្កាលដែរ។

មួយរយៈក្រោយមក ប្រធានកងក៏បញ្ជូនខ្ញុំទៅដាំបាយនៅសហករណ៍ភូមិលាងដៃ ហើយអំឡុងពេលនោះខ្ញុំបានហូបចុកគ្រប់គ្រាន់។ បន្ទាប់មក ទើបខ្មែរក្រហមជ្រើសរើសខ្ញុំឱ្យធ្វើពេទ្យ នៅផ្នែកស្លថ្នាំ។ ពេលនោះម្តាយខ្ញុំបានស្លាប់ ប៉ុន្តែប្រធានកងមិនអនុញ្ញាតឱ្យខ្ញុំមកមើលម្តាយឡើយ។

ក្រោយរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ អាជ្ញាធរបានចោទខ្ញុំថា ជាអ្នកស៊ើបការណ៍ឱ្យខ្មែរក្រហម ហើយចាប់ខ្ញុំយកទៅឃុំនិងសួរចម្លើយរយៈពេលមួយខែទើបដោះលែងខ្ញុំវិញ។

## សួស សឿង ៖ កងចល័ត

អត្ថបទ៖ ស៊ុយ គីមសួរ អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តឧត្តរមានជ័យ



ខ្ញុំឈ្មោះ សួស សឿង អាយុ៧០ឆ្នាំ កើតនៅភូមិដូនឪ ឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិឃុំដដែល។ ខ្ញុំមានបងប្អូនចំនួន៧នាក់ ហើយសព្វថ្ងៃនៅរស់តែ៤នាក់ប៉ុណ្ណោះ។ ខ្ញុំរៀនដល់ថ្នាក់ទី១០ពីសង្គមចាស់។ សម័យនោះមិនមានសាលារៀនត្រឹមត្រូវទេ គឺខ្ញុំរៀននៅសាលាប្រក់ស្លឹក។ ខ្ញុំត្រូវដើរទៅរៀនដោយខ្លួនឯង ព្រោះគ្រួសារខ្ញុំមានជីវភាពខ្វះខាត។ ឪពុកម្តាយខ្ញុំប្រកបរបរធ្វើស្រែ ហើយឆ្លៀតពេលគាត់ទៅដកដំឡូង និងត្បាញកន្ទេលយកទៅលក់នៅផ្សារដើម្បីបានប្រាក់។ នៅពេលខ្ញុំមានអាយុ១៥ឆ្នាំ ខ្មែរក្រហមបានជ្រើសខ្ញុំនិងយុវជន៣នាក់ ពីក្នុងភូមិឱ្យទៅធ្វើការងារបដិវត្តន៍។ ខ្មែរក្រហមបញ្ជូនខ្ញុំទៅធ្វើនៅរោងចក្រ ហើយឆ្លៀតពេលទំនេរត្រូវជួយការងារដកស្ទូង។ រហូតដល់ឆ្នាំ

១៩៧៩ ទើបខ្ញុំត្រឡប់មកជួបជុំគ្រួសារនៅស្រុក ហើយប្រកបរបរធ្វើស្រែចម្ការរហូតមកដល់សព្វថ្ងៃ។

## ណុប សួន ៖ កងចល័តនារី

*អត្ថបទ៖ សុខ រ៉ាន់ណែត អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តឧត្តរមានជ័យ*



ខ្ញុំឈ្មោះ ណុប សួន អាយុ៦៣ឆ្នាំ កើតនៅភូមិស្រែកណ្តាល ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិវត្ត ឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប។ នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសគ្រួសារខ្ញុំចេញពីភូមិស្រែកណ្តាលឱ្យទៅនៅស្រែណូយ ខេត្តឧត្តរមានជ័យ។ ខ្មែរក្រហមបានប្រើខ្ញុំឱ្យធ្វើការគ្មានពេលសម្រាកឡើយ។ ខ្ញុំនៅកងនារីរែកដីលើកទំនប់ ស្ទូងដក និងច្រូតស្រូវ ប៉ុន្តែមិនដែលទទួលបានអាហារហូបគ្រប់គ្រាន់ឡើយ។ ពេលខ្លះប្រធានកងដាស់ឱ្យខ្ញុំងើបទៅធ្វើការតាំងពីម៉ោង៣ទៀបភ្លឺ។ ប្រធានកងប្រើខ្ញុំឱ្យធ្វើការងារច្រើន ប៉ុន្តែផ្តល់តែបបរតិចតួចប៉ុណ្ណោះឱ្យខ្ញុំហូប។ ដោយសារស្រេកឃ្លានខ្លាំងពេលប្រជាជនខ្លះបានដើរលួចអាហារហូបបន្ថែម។ នៅពេលឈ្លបខ្មែរក្រហមតាមទាន់ បានចាប់ប្រជាជនទាំងនោះយកទៅធ្វើទារុណកម្ម និងអប់រំ។ ប្រជាជនរស់នៅរងទុក្ខវេទនា។ ចំណែកកងចល័តរបស់ខ្ញុំ ត្រូវខ្មែរក្រហមបញ្ជូនទៅធ្វើការងារនៅតាមការដ្ឋានផ្សេងៗក្នុងខេត្តសៀមរាប និងនៅអង្គរជុំ។ ពេលខ្ញុំចេញទៅធ្វើការនៅតាមការដ្ឋានម្តងៗ ខ្ញុំនឹកឪពុកម្តាយរបស់ខ្ញុំខ្លាំងណាស់។ រហូតដល់ឆ្នាំ១៩៧៩ ពេលកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាម ចូលមករំដោះប្រជាជនកម្ពុជាពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម ទើបខ្ញុំវិលត្រឡប់មកជួបជុំឪពុកម្តាយ និងបងប្អូនវិញ។

## យូ បឿន ៖ ទាហាន

*អត្ថបទ៖ ណែម ចាន់រ៉ា អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តឧត្តរមានជ័យ*



ខ្ញុំឈ្មោះ យូ បឿន មានអាយុ៧៨ឆ្នាំ មានទីកន្លែងកំណើតនៅភូមិតាសែង ឃុំតាសែង ស្រុករវៀង ខេត្តព្រះវិហារ។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិអូររំដួល ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។

កាលពីក្មេងខ្ញុំបានរៀនសូត្រតិចតួចណាស់ ព្រោះភូមិរបស់ខ្ញុំពុំមានសាលារៀនទេ។ បន្ទាប់ពី លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ សង្គ្រាមក៏ចាប់ផ្តើមកើតឡើងដែរ។ នៅតាមផ្ទះរបស់ប្រជាជនសុទ្ធតែមានលេណដ្ឋានសម្រាប់លាក់ខ្លួន និងមិនហ៊ានដុតភ្លើង ឬធ្វើឱ្យមានផ្សែងឡើយ ព្រោះខ្លាចយន្តហោះមកទម្លាក់គ្រាប់បែក។ ការវាយប្រយុទ្ធគ្នានៅពេលនោះ បានបង្កឱ្យខូចខាតដល់ផ្ទះសម្បែង បាត់បង់អាយុជីវិតមនុស្សជាទីស្រឡាញ់ និងបង្កឱ្យរងរបួសជាច្រើននាក់។

នៅឆ្នាំ១៩៧២ ខ្មែរក្រហមបានចូលមកបណ្តុះបណ្តាល និងឃោសនាអូសទាញយុវជនឱ្យស្រឡាញ់ជាតិ និងចូលបម្រើកងទ័ពដើម្បីការពារជាតិមាតុភូមិ។ ខ្ញុំមិនបានគិតអ្វីច្រើនទេ គឺខ្ញុំចូលបម្រើ

កងខ្មែរក្រហមដើម្បីការពារជាតិប៉ុណ្ណោះ។ ខ្ញុំនៅកងពិសេស ប្រចាំខេត្តព្រះវិហារ។ ខ្ញុំមាននាទីជាប្រធានក្រុម ដែលមានសមាជិកចំនួន១២នាក់។ បន្ទាប់មក អង្គភាពទ័ពបានដំឡើងខ្ញុំទៅជាប្រធានកងអនុសេនាតូច ដែលមានសមាជិកក្រុមជាង៣០នាក់។ មេបញ្ជាការរបស់ខ្ញុំមានឈ្មោះ ម៉ី និង ម៉ាន ព្រមទាំងឈ្មោះ ស៊ី និងជនជាតិបរទេសទៀត។ ពេលនោះម្ហូបអាហារ ខ្ញុំទៅបើកពីអង្គភាពទ័ព ជូនកាលសមាជិកកងរបស់ខ្ញុំបានដើររកដោយខ្លួនឯង។ នៅពេលខ្ញុំឈឺថ្កាត់ម្តងៗគឺមានថ្នាំព្យាបាល និងថ្នាំខ្មែរសម្រាប់ផឹកព្យាបាលជំងឺ។ ក្រោយមកប្រធានអង្គភាពបានរៀបចំការប្រពន្ធឱ្យខ្ញុំ ហើយខ្ញុំក៏មិនហ៊ានប្រកែកដែរ។ ខ្ញុំចាំថាបុរសម្នាក់ឈ្មោះ ខេម ប្រកែកជាមួយប្រធានកងថា ស្លុងស្រូវស្រែជម្រៅ ហើយទឹកលិចគឺពិបាកប្រូតកាត់ណាស់ ក្រោយកងឈ្លបយក ខេម ទៅបាត់ ដោយខ្ញុំមិនដឹងជាយកទៅទីណាឡើយ។

ខ្ញុំតែងតែចែករំលែករឿងរ៉ាវរបស់ខ្ញុំទៅក្មេង និងយុវជនជំនាន់ក្រោយៗឱ្យបានដឹងអំពីទុក្ខលំបាកកន្លងមក។

## យង់ យឹន ៖ កងឡើងត្នោត និង នេសាទ

អត្ថបទ៖ ណែម ចាន់រ៉ា អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តឧត្តរមានជ័យ



ខ្ញុំឈ្មោះ យង់ យឹន មានអាយុ៧៨ឆ្នាំ កើតនៅភូមិក្រពះជ្រូក ឃុំសម្បូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ។ បច្ចុប្បន្ន ខ្ញុំរស់នៅឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ កាលពីក្មេងខ្ញុំបួសរៀននៅវត្តស្រីទេព ស្ថិតនៅឃុំសម្បូរ រយៈពេល៣ព្រះវស្សា។ ក្រោយមកខ្ញុំក៏សឹកនៅឆ្នាំ១៩៦៣ ព្រោះអាណិតម្តាយនៅផ្ទះតែម្នាក់ឯង។ បន្ទាប់ពីសឹករួច ខ្ញុំធ្វើជាគ្រូបង្រៀនអក្ខរកម្ម។ នៅឆ្នាំ១៩៧០ មានការទម្លាក់គ្រាប់បែកយ៉ាងច្រើន ដែលធ្វើឱ្យអ្នកភូមិស្លាប់និងរងរបួសជាច្រើននាក់។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលមកក្នុងភូមិ និងបានចាត់ឱ្យខ្ញុំទៅកាប់ឆ្ការព្រៃនៅក្បាលដំរី រយៈពេល៣ខែ។ បន្ទាប់មកខ្មែរក្រហមចាត់តាំងខ្ញុំឱ្យឡើងត្នោតគឺក្នុងម្នាក់ត្រូវឡើងត្នោតចំនួន៣០ដើម ហើយក្នុងមួយថ្ងៃខ្ញុំត្រូវធ្វើស្ករត្នោតឱ្យបាន១ខ្នះ ត្នោតក្នុងរដូវប្រមូលផលស្ករត្នោត។ ចំណែកការហូបចុកវិញ ខ្មែរក្រហមបើកអង្ករឱ្យចំនួន៣កំប៉ុងក្នុង១ថ្ងៃ។ ពេលនោះខ្ញុំក៏អាចដើររកម្ហូបអាហារដោយខ្លួនឯងបានដែរ និងអាចស្នើប្រធានសហករណ៍សុំមាន់៣ទៅ៤ក្បាលមកចិញ្ចឹមថែមទៀត។ ក្រៅពីការងារឡើងត្នោត ប្រធានកងបានចាត់តាំងឱ្យទៅនេសាទដោយប្រើអួន។ ត្រីធំៗដែលនេសាទបាន គឺខាងសេដ្ឋកិច្ចយកធ្វើងៀត ចំណែកត្រីតូចៗយកទៅធ្វើផ្អក និងប្រហុក។ កងនេសាទក៏អាចយកត្រីទាំងនោះទៅហូបបានដែរ។ នៅពេលយប់មានសត្វមូសរាប់លានក្បាលនៅកន្លែងកងនេសាទស្នាក់នៅ ដែលធ្វើឱ្យយើងពិបាកដេក។ នៅពេលខ្ញុំឈឺថ្កាត់មិនមានថ្នាំព្យាបាលគ្រប់គ្រាន់នោះទេ គឺមានតែគ្រូខ្មែរក្នុងឃុំលាយ និងផ្សំថ្នាំឱ្យខ្ញុំផឹក។ នៅភូមិរបស់ខ្ញុំមានមន្ទីរសន្តិសុខមួយ សម្រាប់ដាក់អ្នកដែលធ្លាប់ធ្វើការរកាលពីសង្គមចាស់។ ខ្ញុំបានឃើញកងឈ្លបខ្មែរក្រហមចាប់ចងភៅដែលធ្លាប់ធ្វើទាហាន លន់ នល់ ឈ្មោះ វ៉ាត់ យកទៅបាត់ ប៉ុន្តែខ្ញុំមិនដឹងយកទៅណាឡើយ។ ខ្មែរក្រហមយកទីតាំងវត្តសម្បូរ ធ្វើជាកន្លែងបញ្ចូនស្រូវ ចំណែករូបពុទ្ធបដិមាករខ្មែរក្រហមប្រមូលទុកដោយឡែក ចំណែកវត្តស្រីទេព ខ្មែរក្រហមរុះរើ

ធ្វើជាផ្ទះបាយរួម។ ខ្មែរក្រហមប្រកាន់ភ្ជាប់សីលធម៌តឹងតែងណាស់ រីឯការរៀបការគឺអង្គភាពជាអ្នកសម្រេច ដោយរៀបការម្ដង១ចាប់ពីរគូឡើងទៅ។

បន្ទាប់ពីសម័យ ប៉ុល ពត បានដួលរលំនៅឆ្នាំ១៩៧៩ ខ្ញុំធ្វើគ្រូបង្រៀនដោយដំបូងទទួលបានរបបអង្ករ ពោត និងស្រូវសាលី។ ក្រោយមក ទើបខ្ញុំទទួលបានប្រាក់ខែ២០០រៀលក្នុងមួយខែ។ សព្វថ្ងៃខ្ញុំគឺជាកសិករ។ ខ្ញុំចង់ឱ្យកូនចៅជំនាន់ក្រោយខិតខំរៀនសូត្រ ដើម្បីការពារកុំឱ្យរបបខ្មែរក្រហមវិលត្រឡប់មកវិញម្ដងទៀត។

## សេង កែវ ៖ ឆាហាន

អត្ថបទ៖ អឿន អូជី អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តឧត្តរមានជ័យ



ខ្ញុំឈ្មោះ សេង កែវ មានអាយុ៦៨ឆ្នាំ កើតនៅភូមិសំរោង ឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប។ បច្ចុប្បន្នខ្ញុំរស់នៅភូមិឃុំដដែល។ កាលពីដើមឪពុកម្ដាយរបស់ខ្ញុំប្រកបមុខរបរធ្វើស្រែចម្ការដើម្បីចិញ្ចឹមកូននិងគ្រួសារ។ ពេលនោះ ខ្ញុំបានចូលរៀននៅសាលាតាប្រុក ដោយមានគ្រូមកពីក្រុងសៀមរាប គឺជាអ្នកបង្រៀន។ បន្ទាប់ពី លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ប្រទេសជាតិចាប់ផ្ដើមច្របូកច្របល់ និងមានសង្គ្រាម ហើយខ្ញុំក៏ឈប់រៀនមករស់នៅជាមួយឪពុកម្ដាយវិញ។

នៅឆ្នាំ១៩៧៣ ខ្ញុំចូលបម្រើកងទ័ពរំដោះខ្មែរក្រហម។ ពេលនោះខ្ញុំមិនចង់ធ្វើកងទ័ពប៉ុន្មានទេ ប៉ុន្តែខ្ញុំគេចមិនរួច។ ដំបូងអង្គភាពទ័ពបានបញ្ជូនខ្ញុំឱ្យទៅប្រាសាទអង្គរវត្ត បន្ទាប់មកទើបបញ្ជូនបន្តទៅហ្វឹកហាត់រៀននៅដំដែក។ ខ្ញុំហ្វឹកហាត់ពេញម៉ោងរយៈពេល៣ខែអំពីវិធី លូន, ក្រាប និងវាយ។ បន្ទាប់ពីហ្វឹកហាត់រួច អង្គភាពទ័ពបានបញ្ជូនខ្ញុំទៅខេត្តកំពង់ចាម។ ពេលខ្ញុំធ្វើដំណើរមកដល់ស្ទោង យន្តហោះ ចំនួន២គ្រឿងរបស់ លន់ នល់ បានស្ទាក់បាញ់ក្រុមរបស់ខ្ញុំបណ្ដាលឱ្យស្លាប់និងរបួស ចំណែកខ្ញុំបានរត់គេចខ្លួនចូលក្នុងភូមិ។ ខ្ញុំលាក់ខ្លួននៅក្នុងភូមិបានរយៈពេល៣ថ្ងៃ ក៏ដើរកាត់តាមព្រៃសំដៅទៅខាងកើតភ្នំសន្ទុក និងបន្តទៅបុសខ្នុរ ក្នុងខេត្តកំពង់ចាម។ អង្គភាពរបស់ខ្ញុំបានបោះទីតាំងនៅបុសខ្នុរ ហើយក្នុងរយៈពេលបីខែ ខ្ញុំហូបតែបបរពោតប៉ុណ្ណោះ។ ក្រោយមក មេបញ្ជាការបានបញ្ជូនខ្ញុំទៅសមរភូមិនៅព្រែក ហើយដោយសារឃើញមនុស្សស្លាប់ច្រើន ខ្ញុំនិងសមាជិកនៅអង្គភាព៦នាក់បានរត់ចេញពីសមរភូមិសំដៅទៅខេត្តកំពង់ធំ ប៉ុន្តែកងទ័ពខ្មែរក្រហមចាប់ខ្លួនបាន។

នៅឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមវាយយកបានទីក្រុងភ្នំពេញ ហើយខ្មែរក្រហមក៏បញ្ជូនខ្ញុំទៅនៅខេត្តសៀមរាបវិញ។ នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបានផ្លាស់ខ្ញុំទៅនៅ ទន្សាយរាក់។ ខ្ញុំភ្ជួររាស់ធ្វើចម្ការនៅទី ទន្សាយរាក់ រហូតដល់កងទ័ពវៀតណាមវាយចូលមកនៅឆ្នាំ១៩៧៩។

## ថី ប្រោង ៖ កងចល័ត

អត្ថបទ៖ អឿន អូជី អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តឧត្តរមានជ័យ



ខ្ញុំឈ្មោះ ថី ប្រោង អាយុ៦១ឆ្នាំ កើតនៅភូមិសំរោង ឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិឃុំដដែល។ កាលពីដើមឪពុកម្តាយខ្ញុំប្រកបមុខរបរធ្វើស្រែចម្ការ ដើម្បីចិញ្ចឹមគ្រួសារ។ ខ្ញុំចូលរៀនបានមួយឆ្នាំក៏ឈប់រៀន ដូច្នេះខ្ញុំមិនចេះអក្សរទេ។ ក្រោយមក ខ្ញុំចូលធ្វើការនៅកងចល័តក្នុងស្រុកបន្ទាយស្រី។ ខ្ញុំបានដេករួមគ្នាជាមួយកងកុមារផ្សេងទៀត។ បន្ទាប់មក ប្រធានកងបានបញ្ជូនខ្ញុំឱ្យទៅធ្វើការនៅកងចល័តនៅភ្នំដីនៅពេលថ្ងៃ ហើយពេលយប់ត្រូវយាម។ ខ្ញុំធ្វើការនៅភ្នំដីបានមួយរយៈ ប្រធានកងក៏បញ្ជូនខ្ញុំមកភ្នំត្បែង និងស្នាក់នៅទីនោះតែម្តង។ នៅទីនោះ ចុងភៅបានចែកបបរឱ្យខ្ញុំមួយថ្ងៃ៣ពេល ក្នុងមួយពេលទទួលបានបបរមួយការ។ មួយរយៈក្រោយមក ប្រធានកងបានផ្លាស់ឱ្យខ្ញុំមកច្រូតស្រូវនៅបារាយណ៍វិញ។ រាល់ថ្ងៃខ្ញុំត្រូវហែលទឹកទៅច្រូតស្រូវ ហើយល្ងាចត្រូវហែលទឹកត្រឡប់មកវិញ។ ខ្ញុំធ្វើការនៅបារាយណ៍រហូតដល់ឆ្នាំ១៩៧៩ ទើបត្រឡប់មករស់នៅជួបជុំគ្រួសារវិញ។

### គន់ វេត ៖ កងកុមារ

*អត្ថបទ ៖ ខៀវ សុខា អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តឧត្តរមានជ័យ*



ខ្ញុំឈ្មោះ គន់ វេត មានអាយុ៧៥ឆ្នាំ កើតនៅភូមិតាប្រុក ឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប។ ខ្ញុំមានកូនប្រុសចំនួន២នាក់ឈ្មោះ លុយ សួរ និង លុយ សេ។ នៅពេលខ្មែរក្រហមចូលមកក្នុងភូមិ ខ្មែរក្រហមមិនបានជម្លៀសគ្រួសារខ្ញុំទៅណាឡើយ គឺឱ្យខ្ញុំធ្វើការនៅក្នុងសហករណ៍។ ខ្មែរក្រហមបានចាត់តាំងខ្ញុំរែកដីជីកដីដំបូកយកមកលាយធ្វើជីដាក់ស្រែ។ ចំណែកប្តីរបស់ខ្ញុំដែលចូលធ្វើជាកងទ័ពរំដោះមិនបានមកលេងផ្ទះទេ ព្រោះអង្គភាពទ័ពមិនអនុញ្ញាត។ នៅសម័យនោះ ខ្ញុំមិនសូវបានហូបគ្រប់គ្រាន់នោះទេ គឺហូបតែបបរបន្តិចបន្តួចប៉ុណ្ណោះ។ រាល់ថ្ងៃខ្ញុំដើរប្រមូលលាមកមនុស្សនៅតាមផ្ទះអ្នកភូមិ ដើម្បីយកធ្វើជីដាក់ស្រែនិងដាំដំណាំ។ ក្រៅពីការងារនេះ ខ្ញុំត្រូវរែកទឹកដាក់ស្រែដែលនៅជិតៗភូមិ។ ខ្ញុំធ្វើការរហូតដល់ម៉ោងកំណត់ ទើបអាចឈប់សម្រាកបាន។ បន្ទាប់មក ខ្ញុំត្រូវទៅបែនស្រូវរហូតដល់ម៉ោង១០យប់ ទើបឈប់សម្រាក។ លុះដល់ម៉ោង៧ព្រឹក ខ្ញុំត្រូវចេញទៅធ្វើការងារបន្តទៀត។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ទើបខ្ញុំជួបជុំគ្រួសារវិញ។

### សំ លួស ៖ កងកុមារ

*អត្ថបទ ៖ ហាប់ នៀត អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តឧត្តរមានជ័យ*



ខ្ញុំឈ្មោះ សំ លួស អាយុ៦១ឆ្នាំ កើតនៅភូមិរំដេញ ស្រុកស្រីស្នំ ខេត្តសៀមរាប។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិអន្លង់វែង សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តមានជ័យ។ ពេលខ្មែរក្រហមចូលមកគ្រប់គ្រង ខ្ញុំនៅក្មេងនៅឡើយ ហើយខ្មែរក្រហមបានចាត់តាំងខ្ញុំឱ្យដើរកាត់ដើមទន្ទ្រានខែត្រជាមួយកុមារផ្សេងទៀតនៅក្នុងភូមិ។ ចំណែកម្តាយខ្ញុំស្លាប់ចោលខ្ញុំតាំងពីរបប លន់ នល់។ ក្រោយមក ខ្មែរក្រហមបានជម្លៀសខ្ញុំចេញពីភូមិរំដេញ ឱ្យទៅរស់នៅផ្សេងៗ។ នៅទីនោះ ប្រធានកងបែងចែកកុមារតូចៗ

ទៅដើរកាត់ដើមទន្ទ្រានខែត្រ និងប្រមូលកំប្លោកយកមកចិញ្ច្រាំធ្វើជី ហើយយុវជនពេញកម្លាំងទៅកងចល័ត។ ខ្ញុំឃើញឈ្លបខ្មែរក្រហមដឹកប្រជាជនដែលជម្លៀសមកពីឆ្ងាយតាមរទេះមួយចំនួនយកទៅទុកនៅសហករណ៍ ហើយយប់ឡើងស្រាប់តែបាត់អ្នកទាំងនោះ នៅសល់តែខោអាវប៉ុណ្ណោះ។ ខ្ញុំទទួលរបបអាហារក្នុងមួយថ្ងៃពីរដង គឺពេលព្រឹកម៉ោង១១ និងពេលល្ងាច។ ប្រធានកងចាត់តាំងកងចល័តលើកភ្លឺស្រែ ដកស្ទូង ច្រូតស្រូវ និងកាប់ជញ្ជូនដីដំបូកទៅដាក់ពង្រាយតាមវាលស្រែធ្វើជី។ នៅពេលសមាជិកកងចល័តណាឈឺល្មមៗ ប្រធានកងមិនឱ្យឈប់សម្រាកទេ។ ក្រោយមក ខ្មែរក្រហមចាត់ប្រជាជនជីករណ្តៅ និងជីកស្រះនៅតាមភូមិដោយប្រាប់ថាទុកដាក់ជី។ នៅពេលកងទ័ពវៀតណាមចូលមករំដោះនៅឆ្នាំ១៩៧៩ ទើបខ្ញុំរត់រកម៉ែឪនិងបងប្អូននៅក្នុងភូមិវិញ។ នៅឆ្នាំ១៩៨២ ខ្ញុំចូលធ្វើទាហានប៉ារ៉ា ហើយនៅឆ្នាំ១៩៨៨ ខ្ញុំបានជាន់មីនផ្ទុះដាច់ជើងម្ខាង ហើយពិការរហូតមកដល់សព្វថ្ងៃ។

## ទស សុផេន ៖ អ្នកគ្រប់គ្រងរោងចក្រកប្បាស

*អត្ថបទ៖ ហាប់ នៀត អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តឧត្តរមានជ័យ*



ខ្ញុំឈ្មោះ ទស សុដេន អាយុ៧៥ឆ្នាំ កើតនៅឃុំមោងឫស្សី ស្រុកមោងឫស្សី ខេត្តបាត់ដំបង។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិអន្លង់វែង សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ ក្រោយពេលខ្មែរក្រហមឡើងគ្រប់គ្រងអំណាច ខ្មែរក្រហមជ្រើសរើសខ្ញុំឱ្យធ្វើការនៅរោងចក្រកប្បាសនៅអណ្តើកហែប ដំណាក់ស្តៅ (បច្ចុប្បន្នហៅស្រុករតនមណ្ឌល) ខេត្តបាត់ដំបង។ ខ្ញុំនៅផ្នែកបច្ចេកទេសដំណាំកប្បាសផង និងផ្នែកសេដ្ឋកិច្ចដឹកជញ្ជូនស្បៀងម្ហូបអាហារផង។ ពេលខ្លះខ្ញុំដឹកជញ្ជូនស្បៀងឆ្លងទៅខេត្តសៀមរាប។ ខ្មែរក្រហមចាប់ខ្ញុំឃុំឃាំងនៅសៀមរាបម្តង ព្រោះខ្ញុំកាន់លិខិតអនុញ្ញាតិឱ្យធ្វើដំណើរដែលស៊ីញ៉េរបស់ រស់ ញឹម លេខាភូមិភាគពាយ័ព្យ ព្រោះកាលនោះអង្គការតាមចាប់ រស់ ញឹម។ ខ្មែរក្រហមឃុំខ្ញុំរហូតគណៈភូមិភាគពាយ័ព្យទៅធានាទើបខ្មែរក្រហមដោះលែងខ្ញុំឱ្យត្រឡប់មកវិញ។

ខ្ញុំនៅបន្តគ្រប់គ្រងរោងចក្រកប្បាស និងដឹកជញ្ជូនចូលរោងចក្រតម្បាញ ដែលមានកម្មករ ១៥,០០០នាក់។ ខ្ញុំធ្វើការនៅរោងចក្របានប្រមាណពីរឆ្នាំ កម្មាភិបាលខាងភូមិភាគនិរតីចូលមក ហើយបានបញ្ជូនខ្ញុំឱ្យទៅស្ទឹង ដើម្បីកាស់គល់ឈើ ភ្លួរស្រែ និងធ្វើស្រែ។ នៅពេលកងទ័ពវៀតណាមវាយចូលមកនៅឆ្នាំ១៩៧៩ ខ្ញុំរត់មកសហករណ៍ និងបានដឹកនាំប្រជាជនធ្វើការ។ ខ្ញុំឱ្យប្រជាជនហូបឆ្អែត។ បន្ទាប់មកខ្ញុំបានរត់ទៅនៅជំរំសាយប៊ី និងបានចូលធ្វើទាហានប៉ារ៉ា។ ក្រោយមក មេបញ្ជារបស់ខ្ញុំបានចាត់តាំងខ្ញុំឱ្យទៅប្រយុទ្ធនៅសមរភូមិអន្លង់វែង ប៉ុន្តែខ្ញុំបដិសេធព្រោះកងទ័ពវៀតណាមដកចេញពីប្រទេសកម្ពុជាអស់។ ក្រោយមក ទើបខ្ញុំមករស់នៅភូមិអន្លង់វែងរហូតមកដល់សព្វថ្ងៃ។

## ប៊ូ ផុន ៖ កងទ័ពអាកាស បច្ចេកទេសរ៉ាដា

*អត្ថបទ៖ សុង សេងហ៊ាង អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តឧត្តរមានជ័យ*



ខ្ញុំឈ្មោះ ប៊ូ ផុន អាយុ៧៥ឆ្នាំ កើតនៅឃុំលាយបូ ស្រុកត្រាំកក់ ខេត្តតាកែវ។ បច្ចុប្បន្នខ្ញុំរស់នៅភូមិទួលប្រសើរ ឃុំបាក់អន្លង់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ ខ្ញុំមានបងប្អូន ចំនួន៧ នាក់។ កាលពីក្មេងខ្ញុំរៀននៅវត្ត ហើយបន្ទាប់មកខ្ញុំចូលរៀននៅសាលាចំបក់ដល់ថ្នាក់ទី៥។ នៅឆ្នាំ១៩៧០ សភាពការណ៍នៅក្នុងភូមិរបស់ខ្ញុំច្របូកច្របល់ ដូច្នេះខ្ញុំក៏ទៅបួស។ មិនបានប៉ុន្មាន កងកម្លាំងរំដោះខ្មែរក្រហមចូលមកក្នុងភូមិ និងមានការវាយប្រយុទ្ធគ្នាបណ្ដាលឱ្យមានអ្នករងរបួសជាច្រើន។ នៅឆ្នាំ១៩៧៥ ខ្ញុំសឹកពីសង្ឃមកចូលបម្រើកងទ័ពនៅកងវរលេខ៣១ ភូមិភាគនិរតី។ ប្រធានអង្គភាពទ័ពរបស់ខ្ញុំឈ្មោះ តា ពន្លក។ បន្ទាប់មក ខ្ញុំបានផ្លាស់មកនៅកងវរសេនាធំលេខ៥០២ ផ្នែកបច្ចេកទេសរ៉ាដា កងទ័ពជើងអាកាស ។ ខ្ញុំបានចេញទៅរៀនពីបច្ចេកទេសរ៉ាដានៅប្រទេសចិនអស់រយៈពេល៦ខែ ដោយធ្វើដំណើរតាមយន្តហោះអស់រយៈពេល៦ម៉ោង។ ក្រោយពីចប់ ខ្ញុំបានធ្វើដំណើរត្រឡប់មកប្រទេសកម្ពុជាវិញតាមកប៉ាល់អស់រយៈពេល១សប្ដាហ៍ ដោយក្នុងកប៉ាល់នោះមានដឹករថយន្តកាំភ្លើង និងរថក្រោះមកជាមួយផង។ នៅឆ្នាំ១៩៧៧ ខ្ញុំបានបង្រៀនកូនសិស្សចំនួន៦នាក់ អំពីបច្ចេកទេសប្រើប្រាស់រ៉ាដា។ នៅឆ្នាំ១៩៧៩ ខ្ញុំទៅដំឡើងរ៉ាដានៅសៀមរាប ខណៈនោះកងទ័ពវៀតណាមបានវាយចូលមកធ្វើឱ្យផែនការរបស់ខ្ញុំមិនបានជោគជ័យឡើយ។ ក្រោយមក ខ្ញុំមកធ្វើជាប្រធានអនុសេនាធំនៅខេត្តក្រចេះរបស់ខ្មែរក្រហម។ បច្ចុប្បន្ន ខ្ញុំពិការដៃឆ្វេង ប៉ុន្តែខ្ញុំនៅធ្វើស្រែចម្ការបានដូចប្រជាជនទូទៅដែរ។

## ឈឹម សឿន ៖ កងទ័ព

*អត្ថបទ៖ យ៉ិម ស្រីមុំ អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តឧត្តរមានជ័យ*

ខ្ញុំឈ្មោះ ឈឹម សឿន អាយុ៧៥ឆ្នាំ កើតនៅភូមិត្រពាំងស្នួល ឃុំញ៉ែងញ៉ង ស្រុកត្រាំកក់ ខេត្តតាកែវ។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិលាងដៃ ឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប។ ខ្ញុំមានឪពុកឈ្មោះ ឈឹម ស៊ូ និងម្ដាយឈ្មោះ ឃឿន ស៊ុច។ ឪពុកម្ដាយខ្ញុំស្លាប់តាំងពីឆ្នាំ១៩៧៣។ ខ្ញុំមានបងប្អូនប្រុសស្រីចំនួន៨នាក់។ ខ្ញុំបានចូលរៀនដល់ថ្នាក់ទី៧ពីសង្គមចាស់។



ជំនាន់មុន ឪពុកម្ដាយខ្ញុំប្រកបរបរដាំ បន្លែ ផ្លែឈើ ដំឡូង ដើម្បីចិញ្ចឹមជីវិត ព្រោះសម័យនោះគ្មានការលក់ដូរទេ។ នៅឆ្នាំ១៩៧១ ខ្ញុំចូលបម្រើកងទ័ពខ្មែរក្រហមនៅវាលស្រែចែង ហើយមិនយូរប៉ុន្មានមេបញ្ជាការកងទ័ពប្រមូលកងទ័ពខ្មែរក្រហមមកបោះទីតាំងនៅក្នុងខេត្តតាកែវវិញ។ មេបញ្ជាការកងទ័ពពេលនោះ ឈ្មោះ តាសោម និង តាមុត។ ក្នុងអង្គភាពទ័ពរបស់ខ្ញុំមានសមាជិកចំនួន១៣០នាក់ ដែលជាទ័ពពិសេសប្រចាំខេត្តតាកែវ។ បន្ទាប់មក អង្គភាពទ័ពរបស់ខ្ញុំត្រូវបានបញ្ជូនទៅ ល្បាត នៅតាមឆ្នេរនិងសមុទ្រ នៅស្រុកដងទង់ ខេត្តកោះកុង។ ពេលចុះល្បាតម្ដងៗ ខ្ញុំជួបការលំបាកណាស់គឺ ខ្ញុំត្រូវដើរទាំងយប់និងថ្ងៃ ពេលខ្លះមិនមានបាយ ហូបក៏មាន។ នៅឆ្នាំ១៩៧៤ មានការវាយប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លារវាងកងទ័ពខ្មែរក្រហម និងកងទ័ព លន់ នល់ បណ្ដាលឱ្យមានស្លាប់ និងពិការច្រើន។

នៅឆ្នាំ១៩៧៥ អង្គភាពទ័ពបានបញ្ជូនខ្ញុំឱ្យទៅធ្វើស្រែ ចម្ការ និងដាំបន្លែនៅជិតព្រំដែនវៀតណាម។ មួយឆ្នាំក្រោយមក គឺនៅឆ្នាំ១៩៧៦ ខ្ញុំបានផ្លាស់ទៅឈរជើងនៅភ្នំដងរែក ក្នុងខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ។ នៅទីនោះខ្ញុំ

មានតួនាទីជាប្រធានវរសេនាតូច ហើយមិនយូរប៉ុន្មានអង្គភាពបានដំឡើងខ្ញុំទៅជាប្រធានវរសេនាធំដើម្បីដឹកនាំកងទ័ពការពារទឹកដីតាមបណ្ដោយព្រំដែនរហូតដល់ទន្លេរពៅ និងកំពង់ស្រឡៅ ក្នុងខេត្តព្រះវិហារ។

នៅឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានចូលមកប្រទេសកម្ពុជា ពេលនោះខ្ញុំឈរជើងការពារនៅតាមបណ្ដោយព្រំដែនដដែល។ នៅឆ្នាំ១៩៨០ ខ្ញុំបានទៅជួប តាម៉ុក ដើម្បីរៀនសូត្រពីទីតាំងភូមិសាស្ត្រ និងវាយបណ្ដេញកងទ័ពវៀតណាមចេញពីតំបន់អន្លង់វែង។ នៅឆ្នាំ១៩៨១ ខ្មែរក្រហមបញ្ជូនខ្ញុំទៅឈរជើងនៅខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ស្ពឺ។ នៅឆ្នាំ១៩៨២ ខ្ញុំបានស្នើសុំមេបញ្ជាការទៅនៅខេត្តកោះកុងវិញ។ នៅក្នុងឆ្នាំ១៩៨២ ដដែល ខ្ញុំបានរៀបការជាមួយប្រពន្ធឈ្មោះ ពេជ្រ និងមានកូនប្រុសស្រីសរុបទាំងអស់ចំនួន ៩នាក់។ សព្វថ្ងៃ ខ្ញុំប្រកបរបរធ្វើស្រែចម្ការ និងចិញ្ចឹមសត្វ។

## ឈុំ ញ៉ឹយ ៖ កងកុមារ

អត្ថបទ៖ ឡា សុឃឿយ អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តឧត្តរមានជ័យ



ខ្ញុំឈ្មោះ ឈុំ ញ៉ឹយ អាយុ៦២ឆ្នាំ កើតនៅភូមិតាម៉ាន សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិឈើក្រំ សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ ខ្ញុំមានបងប្អូនចំនួន៤នាក់ ហើយខ្ញុំគឺជាកូនទី៣នៅក្នុងគ្រួសារ។

កាលពីក្មេងខ្ញុំបានរៀនសូត្រតិចតួចប៉ុណ្ណោះ។ បន្ទាប់ពីរបបខ្មែរក្រហមឡើងគ្រប់គ្រងអំណាច ឆ្នាំ១៩៧៥ ខ្មែរក្រហមចាប់ផ្ដើមប្រមូលប្រជាជនទាំងអស់ឱ្យធ្វើការងាររួមគ្នា ដេករួម និងហូបរួម។ ពេលនោះខ្មែរក្រហមចាត់តាំងខ្ញុំឱ្យនៅកងកុមារ ដើរកាត់ដើមទន្រ្ទានខែ្ទត្រយកមកធ្វើជី។ រយៈពេល២ឆ្នាំក្រោយមក ខ្មែរក្រហមផ្លាស់ខ្ញុំឱ្យទៅនៅកងចល័ត និងទៅលើកទំនប់នៅប្រាសាទល្បើក។ នៅទីនោះ ខ្ញុំឃើញឈ្លបខ្មែរក្រហមចាប់មនុស្សយកទៅសម្លាប់ដោយសារកាប់ដីបណ្ដាលឱ្យបាក់ដងចប។ ចំណែកការហូបចុករបស់ខ្ញុំមានការខ្វះខាតយ៉ាងខ្លាំង ហើយភាគច្រើនខ្ញុំហូបតែបបរលាយជាមួយអំបិល។ យូរៗម្ដង ទើបខ្ញុំបានបាយ ហូបជាមួយសម្លម្ជូរត្រកួនប្រហើត? ព្រលិត។ ថ្ងៃមួយ ខ្ញុំឃ្លានខ្លាំងពេកក៏សម្រេចចិត្តទៅកាប់ចេកឃាយរបស់ខ្ញុំដាំយកមកហូប ហើយត្រូវឈ្លបចាប់ខ្ញុំយកទៅកសាង។ ឈ្លបខ្មែរក្រហមបានប្រមាថមើលងាយខ្ញុំ ហើយគំរាមថាបើមានលើកក្រោយទៀតនឹងយកទៅសម្លាប់ចោលមិនខាន។ ខ្ញុំលើកទំនប់នៅត្រពាំងវែង និងទំនប់អន្លង់ថ្ម បន្ទាប់មកក៏ផ្លាស់ខ្ញុំឱ្យទៅចិញ្ចឹមទា៣០០ក្បាល នៅជិតប្រាសាទល្បើកពីរនាក់មិត្តភក្តិរបស់ខ្ញុំឈ្មោះ ម៉ា អួង។ ពេលនោះ ខ្ញុំមានខោអាវតែ២សម្រាប់ ក្រមា១ និងស្បែកជើងកង់ឡានមួយគូ។

ថ្ងៃមួយ ពេលខ្ញុំកំពុងគៀងទាស្រាប់តែឮព័ត៌មានកងទ័ពវៀតណាមវាយចូលមក។ ខ្ញុំរត់ចេញពីរោងចិញ្ចឹមទាសំដៅទៅការដ្ឋានថ្នល់ស្វាយ ដើម្បីជួបបងប្អូន និងឪពុកម្ដាយ។ នៅឆ្នាំ១៩៨០ ខ្ញុំបានចូលធ្វើជាកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ហើយឆ្នាំ១៩៨៦ ខ្ញុំបានរៀបការប្រពន្ធ ដោយឪពុកម្ដាយជាអ្នកផ្សំផ្គុំ។ ក្រោយមក ខ្ញុំក៏លាឈប់ពីកងទ័ព ហើយរកស៊ីទិញកន្ទេលទៅលក់នៅជីវំ។ ពេលនោះទាហានបានចាប់ឃុំខ្ញុំទុកនៅជីវំរយៈពេល៣ខែ ទើបដោះលែងឱ្យខ្ញុំត្រឡប់មកផ្ទះវិញ។ ក្រោយមក ខ្ញុំក៏ចូលធ្វើការជាកងឈ្លបការពារតំបន់ដែលខ្ញុំរស់នៅ។ នៅឆ្នាំ២០០៦ ខ្ញុំក៏បានធ្វើជាមេភូមិឈើក្រំរហូតដល់សព្វថ្ងៃនេះ។

# មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងរៀបចំវេទិកា ថ្នាក់រៀនស្ដីពី «ជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនក្រោមរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» សម្រាប់យុវជនមកពីឃុំត្រពាំងតាវ

ស្ងួត វិចិត្រ



បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រតំបន់អន្លង់វែងដល់យុវជនមកពីឃុំ ត្រពាំងតាវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៤ វេទិកាថ្នាក់រៀនស្ដីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ត្រូវបានរៀបចំឡើងនៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដោយមានការចូលរួមពីយុវជនចំនួន២០នាក់មកពីឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ វេទិកាថ្នាក់រៀននេះមានគោលបំណងលើកកម្ពស់ការយល់ដឹងដល់យុវជនអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» និងទប់ស្កាត់អំពើប្រល័យពូជសាសន៍នាពេលអនាគត តាមរយៈការមិនគាំទ្រអំពើហិង្សាគ្រប់រូបភាព ការមិនប្រកាន់ បុរើសអើង ពូជសាសន៍ ពណ៌សម្បុរ ជនជាតិ ជាតិពន្ធុ និងនិន្នាការនយោបាយ។

បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានធ្វើបទបង្ហាញដោយផ្ដោតសំខាន់ទៅលើ «ជីវិតរស់នៅប្រចាំថ្ងៃនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)»។ របបកម្ពុជាប្រជាធិបតេយ្យកាន់អំណាចពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ត្រូវបានស្គាល់ថា ជារបបផ្ដាច់ការ និងឃោរឃៅបំផុតក្នុងប្រវត្តិសាស្ត្រកម្ពុជា។ មេដឹកនាំខ្មែរក្រហមបានប្រែក្លាយប្រព័ន្ធដឹកនាំនយោបាយ និងដាក់ស្ថានភាពរស់នៅរបស់ប្រជាជនទៅក្នុងភាព

រឹតត្បិតបំផុតនៃជីវិតរស់នៅប្រចាំថ្ងៃ។ ប្រជាជនម្នាក់ៗរស់នៅក្នុងស្ថានភាពនៃការរំលោភសិទ្ធិ និងជាទាសករនៃបដិវត្តន៍។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហមបានរកឃើញថា របបកម្ពុជាប្រជាធិបតេយ្យបង្ខំមនុស្សឱ្យធ្វើការងារហួសកម្លាំងលើសពី១២ម៉ោងក្នុងមួយថ្ងៃ, ការបង្ខំប្រជាជនឱ្យរៀបការ, ការរំលោភសិទ្ធិ និងពលកម្មកុមារ, ការហូបចុកមិនគ្រប់គ្រាន់, ការសម្លាប់រង្គាលទៅលើក្រុមគោលដៅជាក់លាក់ (ជនជាតិចាម ជនជាតិវៀតណាម អ្នកកាន់ព្រះពុទ្ធសាសនា និងអតីតមន្ត្រីរដ្ឋការ លន់ នល់), ការធ្វើឱ្យមនុស្សទៅជាទាសករ, ការនិរទេស ឬការផ្លាស់ប្តូរទីលំនៅដោយបង្ខំ, ការដាក់ក្នុងមន្ទីរឃុំឃាំង, ការធ្វើទារុណកម្ម, ការធ្វើទុក្ខបុកម្នេញក្រោមហេតុផលនយោបាយ សាសនា និងពូជសាសន៍ និងការប្រព្រឹត្តអំពើអមនុស្សធម៌ដទៃទៀតប្រឆាំងនឹងសេចក្តីថ្លៃថ្នូរបស់មនុស្ស។ របបកម្ពុជាប្រជាធិបតេយ្យគ្រប់ដណ្តប់ដោយមនោគមវិជ្ជា និងអនុវត្តតាមលទ្ធិម៉ៅនិយម និងម៉ាក្សលេនីនជ្រុលហួសហេតុ ព្រមទាំងមានចរិតរើសអើងយ៉ាងធ្ងន់ធ្ងរ។

នៅពេលទទួលបានជ័យជម្នះទូទាំងប្រទេស នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យបានដាក់ចេញនូវគោលនយោបាយជម្លៀសប្រជាជនចេញពីរាជធានីភ្នំពេញ ដែលមានមនុស្សរស់នៅប្រហែល២លាននាក់ និងនៅតាមទីប្រជុំជននានាឱ្យធ្វើដំណើរទៅកាន់ទីជនបទដាច់ស្រយាល ដោយមិនមានការរៀបចំត្រឹមត្រូវ។ ក្នុងពេលនោះ ខ្មែរក្រហមបានបែងចែកប្រជាជនជាពីរ គឺប្រជាជនចាស់ (ប្រជាជនមូលដ្ឋាន) និងប្រជាជនថ្មី (ប្រជាជន១៧មេសា) ព្រមទាំងកំណត់គោលដៅទៅលើក្រុមជាក់លាក់ក្នុងការសម្លាប់ភ្លាមៗតែម្តង។ មនុស្សជិត២លាននាក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានសម្លាប់ ហើយ៥លាននាក់ទៀតទទួលការបាក់ស្បាត បញ្ហាសុខភាពដោយសារការងារធ្ងន់ធ្ងរ បាក់កម្លាំង និងរងរបួសដោយសារសង្គ្រាម។

នៅក្នុងវេទិកាថ្នាក់រៀននេះក៏មានការលើកជាសំណួរ និងការពិភាក្សាដូចខាងក្រោម ៖

**១) ហេតុអ្វីបានកើតមានរបបកម្ពុជាប្រជាធិបតេយ្យ?**

**២) ហេតុអ្វីប្រទេសមួយអាចមានសង្គ្រាមទៅបាន?**

**៣) ហេតុអ្វីប្រទេសមួយចំនួនឈ្លោះគ្នា?**

**៤) ហេតុអ្វីយើងមិនកសាងសន្តិភាព?**

ជីវិតរស់នៅប្រជាជនក្នុងរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានពិភាក្សាតាមរយៈឧទាហរណ៍សាមញ្ញៗ ប៉ុន្តែបានបង្ហាញនូវអត្ថន័យ និងទុក្ខលំបាកវេទនាយ៉ាងទូលំទូលាយ។ យុវជនអាចពិនិត្យទៅលើជីវិតរស់នៅប្រចាំថ្ងៃរបស់ខ្លួន និងធ្វើការប្រៀបធៀបជាមួយប្រជាជនដែលរស់នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ដែលមិនមានអាហារហូបចុកគ្រប់គ្រាន់, ធ្វើការវែកដី, គ្មានស្បែកជើងពាក់, គ្មានថ្នាំដុសធ្មេញ, គ្មានសាប៊ូកក់សក់, គ្មានសម្លៀកបំពាក់ស្អាតបាត និងបង្ខំឱ្យរៀបការ។ នៅផ្នែកចុងក្រោយនៃវេទិកាថ្នាក់រៀន យុវជនរៀនពីវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍នាពេលអនាគត។





# ការិយាល័យព័ត៌មានសាធារណៈ













«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង រស់ សំពៅ អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៨៨២ ៥០៥ ឬ

អ៊ីម៉ែល ៖ truthsampeou.r@dccam.org

សូមអរគុណ!














# ជីវិតកូនប្រុសពុកក្នុងគុកខ្មែរក្រហម (តចប់)

ហង្ស ឆាំឆាន

ក្មេងមុខ ក្មេងក្រោយ ដូចជាគ្មានប្រលឹងនៅក្នុងខ្លួនតែខំប្រឹងកាត់ចិត្តថា មានគេជាច្រើននាក់វេទនាជាងខ្ញុំព្រាត់ប្រាស់គ្នាច្រើនជាងគ្រួសារខ្ញុំទៅទៀតៗ ស្រាប់តែនៅពាក់កណ្ដាលខែឧសភា ១៩៧៩ ឮដំណឹងគេប្រាប់ថា នឹងមានកាណូតដឹកអ្នកពោធិ៍សាត់មកវិញៗ ព្រលឹមឡើងខ្ញុំទៅរង់ចាំមើលនៅមាត់ទន្លេភូមិព្រែកខ្សាយខ ពេលកាណូតមកអន្តុយចាំមើលៗ ស្រាប់តែឃើញលោកបងយ៉ែន ឪពុកម៉ៅ វុឌ្ឍី ត្រូវគេលើកពីកាណូតចុះមកមុនគេ ស្រែហៅខ្ញុំ ខ្ញុំមើលគាត់មិនស្គាល់ព្រោះគាត់ឈឺហើមខ្លួនតែស្គាល់សំឡេងស្គាល់ទើបដឹងថាលោកឪពុកអ្នកម្ដាយខ្ញុំមកជាមួយដែរៗ បង ហាក់ ជូ ប្រពន្ធបង ជាម យៀប និងបងប្អូនជាច្រើននាក់ទៀតត្រូវធ្វើដំណើរមកតាមក្រោយៗ តែដឹងថាមានស្លាប់គ្នាច្រើន ដោយគេយកទៅសម្លាប់និងអត់អាហារៗ រហូតដល់ពាក់កណ្ដាលខែកញ្ញា ឆ្នាំ១៩៧៩ ទើបជួបជុំគ្នា និងដឹងច្បាស់ថា អ្នកណាបាត់ខ្លួនអ្នកណានៅ គ្រួសារខ្ញុំ ១០នាក់មកវិញទាំងអស់ ខាងដន្ទង់ឪពុកខ្ញុំបាត់៨នាក់ បង ជាម យៀប បាត់កូន២នាក់ៗ



ព្រះសង្ឃនៅខេត្តស្វាយរៀងបង្សុកូលឧទ្ទិសកុសលជូនវិញ្ញាណក្ខន្ធជនរងគ្រោះបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩ៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របមុខ ៖
កងទ័ពខ្មែរក្រហមកំពុងលើកប្រព័ន្ធភ្លឺស្រែ។
( បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា )

រូបក្របក្រោយ ៖
យុទ្ធនារីខ្មែរក្រហមកំពុងស្ទូងនៅវាលស្រែ។
( បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា )



**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ៧៨ ៦៩៨ ៣៣៣*

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 298, October 2024 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.